# ចូឡន្តរទុកៈ

## មាន ៧ ទុកៈ ១៤ ធម្មា

**១-សប្បច្ចយា ធម្មា**: ពួកធមិមានបច្ច័យ បានដល់ចិត្ត ១២១ ចេតសិក ៥២ រូប ២៨ ។

***អត្ថកថា***: ធមិដែលឈ្មោះថា សប្បច្ចយៈ ព្រោះប្រព្រឹត្តទៅព្រមជាមួយបច្ច័យដែលឱ្យសំរេចដល់ខ្លួន ។

ᦂᦂᦂᦂᦂ

## សតិប្បដ្ឋាន

ធមិដែលមានបច្ច័យ គឺធមិនៅក្នុងជីវិតប្រចាំថ្ងៃ គឺជាធមិដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ដឹងមុនគេ ។

ពពួកមនុស្សមុនការត្រាស់ដឹងនៃព្រះពុទ្ធ តែងតែប្រកាន់នូវធមិទាំងនេះថា ជាសត្វបុគ្គល ថាជាខ្លួន ឬថាជារបស់ខ្លួន ហើយរមែងយល់ខុសដោយប្រការផ្សេងៗទៀត ថាមានព្រះព្រហ្មឬព្រះអាទិទេពជាអ្នកសាងលោក ជាអ្នកបង្កើតសត្វលោក ខ្លះទៀតយល់ថា សត្វលោកកើតឡើងឯងៗដោយអត់ហេតុ ។

ក្រោយការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ សាវ័ករបស់ព្រះពុទ្ធ បានសិក្សានូវធម្មៈពិតៗក្នុងជីវិតប្រចាំថ្ងៃ ហើយក៏បានត្រាស់ដឹងតាមព្រះពុទ្ធ នូវធមិដែលជាសប្បច្ចយៈ លះបង់នូវការយល់ខុសក្នុងធម្មៈ និង ជាអ្នកឃើញព្រះពុទ្ធដោយបញ្ញាចក្ខុ ។

ᦂសត្វលោករមែងប្រកាន់ថា ខ្លួនជាអ្នកបានលាភ បានយស បានមាស បានប្រាក់ បានទ្រព្យសម្បត្តិ ប៉ុន្តែបើមិនមានវិញ្ញាណទេនោះ តើមានអ្នកបាននូវលាភយសជាដើមដែរឬទេ? តើមានសេចក្តីដឹងខ្លួនថា អញក្នុងសាកសពដែរឬទេ?

វិញ្ញាណក៏ជាធមិ មានបច្ច័យប្រព្រឹត្តទៅតាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយនិងផ្លូវចិត្តដឹងនូវអារម្មណ៍តាមទ្វារនោះៗ រួចហើយក៏រលត់ទៅបាត់អស់ជាធម្មៈពិតៗ ពុំមែនជាសត្វបុគ្គលណាឡើយ ។

αការបដិបត្តិធម៌ចំរើនសតិបញ្ញា គឺការសិក្សាសង្កេត ពិនិត្យដោយស្មារតី ដោយសេចក្តីដឹងខ្លួនដ៏ប្រពៃ មិនវង្វេង ច្រឡំក្នុងសភាវធម៌ដែលកំពុងប្រាកដជាប្រក្រតីរឿយៗ នេះ គឺការចំរើនស្មារតី សេចក្តីមិនប្រមាទកំចាត់បង់នូវមោហៈ ដែលជាផ្ទាំងងងឹតបិទបាំងនូវសភាវធម៌ ។

αជីវិតនេះកើតមកសំរាប់តែដោះស្រាយនូវបញ្ហាដែល ជាប់តាមជីវិតខ្លួនឯងមកតែប៉ុណ្ណោះ ជីវិតគឺជាទុក្ខ ព្រោះជីវិត ប្រកបដោយខន្ធ ៥ ។

# ព្រះគាថាអធិមុត្តត្ថេរ

≈α≈α≈α≈α≈α≈

ព្រះថេរអង្គនេះ បានបំពេញនូវបុញ្ញាធិការទុកក្នុង ព្រះសាសនានៃព្រះពុទ្ធជាម្ចាស់អង្គមុនៗ សន្សំបុណ្យទុកក្នុង ភពនោះៗក្នុងកាលនៃព្រះពុទ្ធ **អត្ថទស្សី** លោកបានកើតក្នុង ត្រកូលអ្នកមានទ្រព្យសម្បត្តិច្រើន កាលព្រះសាស្តាបរិនិព្វាន ទៅ លោកបានឧបដ្ឋាកភិក្ខុសង្ឃញ៉ាំងមហាទានឱ្យប្រព្រឹត្ត ទៅ ។

ដោយបុញ្ញកម្មនោះ លោកបដិសន្ធិជាទេវតា និង មនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទកាលនេះ លោកកើតក្នុងផ្ទៃ របស់ប្អូនស្រីនៃព្រះសង្កិច្ចថេរៈ មានឈ្មោះថា **អធិមុត្តៈ** កាលចំរើនវ័យហើយ ក៏បានបួសក្នុងសំណាក់ព្រះថេរៈដែល ជាលោកអ៊ំ បំពេញវិបស្សនាកម្មដ្ឋានទាំងដែលនៅជាសាម ណេរ ក៏បានជាព្រះអរហន្ត ។

លោកបានព្រះអរហត្តហើយ ញ៉ាំងកាលវេលាឱ្យកន្លង

ទៅដោយសេចក្ដីសុខក្នុងសមាបត្តិ ហើយមានព្រះបំណងនឹងឧបសម្បទាជាភិក្ខុ ក៏និមន្តទៅលាព្រះមាតា ក្នុងរវាងផ្លូវបានជួបនឹងចោរ ៥០០នាក់ ដែលកំពុងស្វែងរកសាច់ ដើម្បីធ្វើពលីកម្មដល់ទេវតា ។ ពួកចោរបានចាប់លោកដោយមានបំណងថា នឹងធ្វើពលីបូជាទេវតា ។ អធិមុត្តៈ កាលត្រូវពួកចោរចាប់ក៏មិនតក់ស្លុតខ្លាចអ្វីឡើយ មានព្រះភ័ក្ត្រស្រស់ថ្លាផូរផង់ ។ មេចោរបានឃើញដូចនោះ ក៏កើតសេចក្ដីអស្ចារ្យក្នុងចិត្ត ដោយមិនធ្លាប់មានមកអំពីមុនឡើយ ទើបពោលសរសើរដល់ព្រះអធិមុត្តៈដូច្នេះថា :

ក្នុងកាលមុន យើងខ្ញុំទាំងឡាយសម្លាប់សត្វពួកណាដើម្បីយញ្ញ ឬ ដើម្បីប្លន់ទ្រព្យសម្បត្តិ ភ័យក៏កើតមានដល់ពួកសត្វនោះឥតមានសេសសល់ឡើយ សត្វទាំងនោះរមែងញាប់ញ័រផង សោកសៅផង ។ សេចក្ដីភិតភ័យនៃលោកមិនមាន ទាំងសម្បុរមុខលោកក៏ស្រស់បស់ក្រៃពេក ហេតុអ្វីក៏លោកមិនខ្សឹកខ្សួល ព្រោះភ័យធំដែលមានសភាពយ៉ាងនេះ ។

ព្រះអធិមុត្តៈពោលថា ម្នាលមេចោរ សេចក្ដីទុក្ខប្រព្រឹត្តទៅក្នុងចិត្តនៃបុគ្គលអ្នកមិនមានសេចក្ដីអាឡោះអាល័យមិនមានទេ បុគ្គលអ្នកមានសំយោជនៈអស់ហើយបានកន្លងផុតនូវភ័យទាំងពួង ។

កាលបើតណ្ហាជាគ្រឿងនាំសត្វលោកទៅកាន់ភពក្នុងបច្ចុប្បន្នអស់ហើយដោយហេតុណាមួយ ភ័យចំពោះសេចក្ដីស្លាប់ក៏មិនមានឡើយ ដូចការមិនមានភ័យក្នុងកិរិយាដាក់ចុះនូវភារៈចេញអំពីក្បាល ។

ព្រហ្មចរិយធម៌ អាត្មាបានសន្សំល្អហើយ ទាំងមគ្គអាត្មាក៏បានចំរើនល្អហើយ ភ័យចំពោះសេចក្ដីស្លាប់នៃអាត្មាមិនមានទេ ដូចការមិនមានភ័យក្នុងកិរិយាអស់ទៅនៃរោគទាំងឡាយ ។

ព្រហ្មចរិយធម៌ អាត្មាបានសន្សំល្អហើយ ទាំងមគ្គអាត្មាក៏បានចំរើនល្អហើយ ភពទាំងឡាយដែលមិនមានសេចក្ដីត្រេកអរ អាត្មាក៏បានឃើញហើយ ដូចបុគ្គលផឹកនូវថ្នាំពិស ហើយខ្ជាក់ចោលចេញវិញនូវថ្នាំពិសនោះ ។

បុគ្គលអ្នកដល់នូវត្រើយគឺ ព្រះនិព្វានមិនមាន សេចក្ដី

ប្រកាន់មានសោឡសកិច្ច( កិច្ច១៦) បានធ្វើហើយ មិនមានអាសវៈ រមែងជាអ្នកត្រេកអរក្នុងកិរិយាអស់ទៅនៃអាយុដូចបុគ្គលរួចហើយចាកការសម្លាប់ ។

បុគ្គលបានដល់នូវធម៌ដ៏ឧត្តម ជាអ្នកមិនត្រូវការក្នុងលោកទាំងអស់ រមែងមិនសោកសៅព្រោះសេចក្តីស្លាប់ ដូចបុគ្គលស្ទុះផុតចាកផ្ទះដែលត្រូវភ្លើងឆេះ ។

ការជួបជុំដោយសត្វ និង សង្ខារឯណានីមួយក្តី ការកើតមានក្នុងពួកសត្វឯណាក្តី ទាំងអស់នោះមិនមែនជាធំឡើយ ពាក្យនេះព្រះសម្មាសម្ពុទ្ធ អ្នកស្វែងរកនូវគុណដ៏ធំបានសំដែងហើយ ។ បុគ្គលណាបានដឹងច្បាស់នូវព្រះពុទ្ធដីកាតាមដែលព្រះពុទ្ធទ្រង់សំដែងហើយនោះ បុគ្គលនោះមិនប្រកាន់នូវភពណានីមួយឡើយ ដូចបុគ្គលមិនចាប់កាន់នូវដុំដែកដែលក្តៅក្រហមឆ្អិនឆ្អៅដូច្នោះដែរ ។

អាត្មាមិនមានសេចក្តីត្រិះរិះថា ខ្លួនអញបានមានហើយទេ អាត្មាមិនមានគិតថា ខ្លួនអញនឹងមានតទៅទេ ព្រោះថាសង្ខារទាំងឡាយទៀងតែវិនាសទៅវិញ ហេតុនោះសេចក្តីខ្សឹកខ្សួលក្នុងសង្ខារទាំងនោះដូចម្តេចកើត ។

ម្នាលមេចោរ បុគ្គលដែលឃើញច្បាស់តាមសេចក្តីពិតនូវការប្រជុំកើតឡើងនៃធម៌ដ៏បរិសុទ្ធ នឹងដំណៃនៃសង្ខារដ៏បរិសុទ្ធ ភ័យមិនមានឡើយ ។

បុគ្គលដែលឃើញច្បាស់ ដោយបញ្ញានូវលោកប្រាកដស្មើដោយស្មៅ និង កំណាត់ឈើក្នុងកាលណា ក្នុងកាលនោះបុគ្គលនោះ ក៏មិនបាននូវសេចក្តីប្រកាន់ថារបស់អញរមែងមិនសោកសៅថា របស់យើងវិនាសហើយ ។

អាត្មាធុញទ្រាន់នឹងសរីរៈ ជាអ្នកមិនត្រូវការដោយភពព្រោះថា កាយនេះនឹងបែកធ្លាយទៅទាំងកាយដទៃទៀតក៏នឹងមិនមានដែរ ។ កិច្ចណាដោយសរីរៈមានដល់ពួកអ្នក ពួកអ្នកប្រាថ្នានូវកិច្ចណា ចូរធ្វើនូវកិច្ចនោះចុះ សេចក្តីទោមនស្សក្តី សេចក្តីស្រឡាញ់ក្តីនៃអាត្មា នឹងមិនមានក្នុងអំពើទាំងនោះព្រោះបច្ច័យនៃកិច្ចនោះ ។

ពួកចោរបានស្តាប់ពាក្យនៃព្រះអធិមុត្តត្ថេរនោះ ជាពាក្យចំឡែកអស្ចារ្យគួរឱ្យព្រឺរោម ហើយក៏ទម្លាក់ចោល

នូវគ្រឿងសស្ត្រាទាំងឡាយ បានពោលពាក្យនេះថា បពិត្រលោកដ៏ចំរើន លោកបានធ្វើតបោកម្មដូចម្ដេច ឬអ្នកណាជាអាចារ្យរបស់លោក សេចក្ដីមិនសោកសៅ លោកបានព្រោះអាស្រ័យពាក្យប្រដៅរបស់អ្នកណា ។

ព្រះថេរះឆ្លើយថា ព្រះជិនស្រីព្រះអង្គជាសព្វញ្ញូទ្រង់ឃើញនូវធម៌ទាំងពួង ជាសាស្ដាប្រកបដោយករុណាដ៏ធំ ទ្រង់រក្សានូវសត្វលោកទាំងអស់ ជាអាចារ្យរបស់អាត្មា ។ ព្រះធម៌នេះ ជាធម៌ដល់នូវកិរិយាអស់ទៅនៃកិលេស ជាធម៌ដ៏ប្រសើរ ព្រះជិនស្រីនោះ បានសំដែងហើយ សេចក្ដីមិនសោកសៅ ដែលអាត្មាបាន ព្រោះអាស្រ័យនូវធម៌ជាពាក្យប្រៀនប្រដៅរបស់ព្រះជិនស្រីនោះ ។

ចោរទាំងឡាយបានស្ដាប់នូវសុភាសិតនៃឥសី គឺព្រះវាចារបស់ព្រះ**អធិមុត្តត្ថេរ**ហើយ ក៏ទម្លាក់ចោលនូវគ្រឿងសស្ត្រាទាំងឡាយផង នូវអាវុធទាំងឡាយផង ពួកខ្លះក៏វៀរចាកចោរកម្មនោះ ពួកខ្លះក៏ពេញចិត្តនឹងបព្វជ្ជា ។ ចោរទាំងនោះក៏ចូលទៅបួសក្នុងសាសនានៃព្រះសុគត ចំរើននូវពោជ្ឈង្គ និងពលៈទាំងឡាយ ជាបណ្ឌិតមានចិត្តខ្ពស់ឡើង មានចិត្តល្អ មានឥន្ទ្រិយចំរើនហើយ ក៏បានពាល់ត្រូវនូវនិព្វានបទជាអសង្ខតធម៌ ។

ដោយសេចក្ដីថា ព្រះអធិមុត្តត្ថេរ ធ្វើពួកចោរឱ្យអស់ចិត្តកំណាច ហើយទុកពួកចោរឱ្យនៅទីនោះឯង លោកក៏និមន្តទៅរកមាតា ជំរាបលាមាតាហើយ ទើបត្រឡប់មកនាំចោរទាំងនោះទៅកាន់សំណាក់ព្រះឧបជ្ឈាយ៍ ឱ្យបានបព្វជ្ជាឧបសម្បទា ដោយអាស្រ័យកម្មដ្ឋាន មិនយូរប៉ុន្មាន លោកទាំងអស់នោះ ក៏តាំងនៅក្នុងព្រះអរហត្ត ។

**ចប់អធិមុត្តត្ថេរគាថា**

# សប្បច្ចយា ធម្មា

≈α≈α≈α≈α≈α≈

ពួកធម៌ដែលមានបច្ច័យបានដល់ រូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ និង វិញ្ញាណក្ខន្ធ ។

ម្យ៉ាងទៀត បានដល់កុសលធម៌ទាំងអស់ អកុសលធម៌ទាំងអស់ វិបាកធម៌ទាំងអស់ កិរិយាធម៌ទាំងអស់ ព្រមទាំងរូបទាំងអស់ ។

**២~អប្បច្ចយា ធម្មា** : ពួកធម៌មិនមានបច្ច័យបានដល់និព្វាន ដែលផុតចាកខន្ធ ៥ ។

αការមិនប្រកាន់ថា មានតួខ្លួននៅក្នុងខន្ធ មិនប្រកាន់ថា មានតួខ្លួននៅក្រៅអំពីខន្ធ មិនប្រកាន់រូបក្ខន្ធថាជាខ្លួន មិនប្រកាន់វេទនាខន្ធថាជាខ្លួន មិនប្រកាន់សញ្ញាខន្ធថាជាខ្លួន មិនប្រកាន់សង្ខារក្ខន្ធថាជាខ្លួន មិនប្រកាន់វិញ្ញាណក្ខន្ធថាជាខ្លួន ការមិនប្រកាន់យ៉ាងនេះ គឺជាទីពឹងជាទីពួនអំពីជរានិងមរណៈឈ្មោះថា បានដល់នូវព្រះនិព្វាន។

αការមិនប្រកាន់ខន្ធ ហើយនិងការទៅកាន់ព្រះនិព្វានពីរយ៉ាងនេះ គឺដូចគ្នា ។

α ផ្លូវដែលចេញអំពីខន្ធ គឺទៅកាន់ព្រះនិព្វាន ។

# ភទ្ទេករត្តសូត្រ

## ភាពនៃបុគ្គលមានរាត្រីមួយដ៏ចំរើន

## មជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ

បុគ្គលមិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធជាអតីត មិនគប្បីប្រាថ្នានូវបញ្ចក្ខន្ធជាអនាគតទេ ព្រោះថា បញ្ចក្ខន្ធណាជាអតីត បញ្ចក្ខន្ធនោះ កន្លងហួសទៅហើយ បញ្ចក្ខន្ធណាជាអនាគត បញ្ចក្ខន្ធនោះ ក៏មិនទាន់មកដល់ មួយទៀត បុគ្គលណាឃើញច្បាស់នូវធម៌ជាបច្ចុប្បន្នក្នុងទីនោះៗ បុគ្គលនោះលុះដឹងច្បាស់នូវព្រះនិព្វាន ដែលមិនរសេមរសាម មិនកំរើកហើយគប្បីចំរើនឱ្យរឿយៗនូវផលសមាបត្តិ ដែលមានអារម្មណ៍ជាព្រះនិព្វាននោះចុះ ។

ការព្យាយាមជាគ្រឿងដុតកិលេស បុគ្គលគួរតែធ្វើក្នុងថ្ងៃនេះឯង អ្នកណានឹងដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថា ការតទល់របស់យើង ចំពោះមច្ចុដែលមានសេនាដ៏ច្រើននោះ មិនមានសោះឡើយ ។

មុនីដែលជាអ្នកស្ងប់ទុក្ខហើយ តែងហៅបុគ្គលដែលមានវិហារធម៌យ៉ាងនេះ មានសេចក្តីព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស ជាអ្នកមិនខ្ជិលច្រអូស អស់ថ្ងៃ និង យប់នោះឯងថា ជាអ្នកមានរាត្រីមួយដ៏ចំរើន ។

# បបញ្ចសូទនី

## *អដ្ឋកថា ភទ្ទេករត្តសូត្រ*

បទថា **ភទ្ទេករត្តស្ស** ដោយសេចក្តីថា ឈ្មោះថា បុគ្គលមានរាត្រីមួយដ៏ចំរើន ព្រោះសេចក្តីដែលជាអ្នកដល់ព្រមដោយការប្រកបវិបស្សនា ។ **អតីតំ** បានដល់ខន្ធ ៥ ដែលកន្លងទៅហើយ ។

បទថា **នាន្វាគមេយ្យ** សេចក្តីថា មិនគួរនឹកដល់ដោយតណ្ហា និង ទិដ្ឋិទាំងឡាយ ។

បទថា **នប្បដិកង្ខេ អនាគតំ** សេចក្តីថា មិនគប្បីប្រាថ្នាដោយតណ្ហា និង ទិដ្ឋិទាំងឡាយនូវខន្ធ ៥ ជាអនាគត ។

បទថា **យទតីតំ** ក្នុងគាថានេះ ជាការពោលដល់ហេតុ ។

ព្រោះរបស់ណាកន្លងទៅហើយ របស់នោះក៏លះទៅហើយ រលត់ទៅហើយ ដល់នូវសេចក្តីតាំងនៅមិនបាន ឡើយ ព្រោះដូច្នោះ បុគ្គលមិនគួររំពឹងនឹកអាឡោះអាល័យដល់របស់ដែលកន្លងទៅហើយ នោះទៀតទេ ។

ម្យ៉ាងទៀត ព្រោះរបស់ណាដែលនៅមិនទាន់មក ដល់ របស់នោះក៏នៅមិនដល់ នៅមិនទាន់កើត នៅមិនទាន់ បង្កើត ព្រោះដូច្នោះ បុគ្គលមិនគប្បីប្រាថ្នារបស់ដែលមិនទាន់មកដល់ឡើយ ។

បទថា **តត្ថ តត្ថ** សេចក្តីថា បុគ្គលជាអ្នកដល់ធម៌ជាបច្ចុប្បន្ន ក្នុងធម៌ណាៗ ឃើញច្បាស់នូវធម៌នោះៗ ដោយអនុបស្សនា ៧ យ៉ាង មានអនិច្ចានុបស្សនាជាដើម ។

បទថា **អសំហីរំ អសង្កុប្បំ** នេះព្រះដ៏មានព្រះ-ភាគជាម្ចាស់ត្រាស់ ដើម្បីទ្រង់សំដែងវិបស្សនា ។

ពិតណាស់ វិបស្សនារមែងមិនរសេមរសាម រមែងមិនកំរើកដោយកិលេសទាំងឡាយ មានរាគៈជាដើម ព្រោះ

ដូច្នោះ វិបស្សនានោះ ឈ្មោះថា **អសំហីរំ** មិនរសេមរសាម ឈ្មោះថា **អសង្កុប្បំ** មិនកំរើក ។

លោកពោលអធិប្បាយថា បុគ្គលគប្បី អប់រំ ចំរើន គប្បី ឃើញច្បាស់ ចំពោះវិបស្សនានោះឯង ។

ប្រការមួយទៀត **និព្វាន** រមែងមិនរសេមរសាម រមែងមិនកំរើកដោយកិលេសទាំងឡាយ មានរាគៈជាដើម ព្រោះដូច្នោះ និព្វាននោះទើបឈ្មោះថា **អសំហីរំ** មិនរសេមរសាម **អសង្កុប្បំ** មិនកំរើក ។

អធិប្បាយថា បណ្ឌិតដឹងច្បាស់ហើយ គប្បីចំរើនរឿយៗនូវផលសមាបត្តិ ដែលមាននិព្វាននោះជាអារម្មណ៍ ។ ក៏ដើម្បីប្រយោជន៍ដល់ភិក្ខុអ្នកអប់រំចំរើននោះ ។

បទថា **អជ្ជេវ កិច្ចំ អាតប្បំ** សេចក្ដីថា ការព្យាយាម ដែលមានឈ្មោះថា **អាតប្ប** ព្រោះដុតនូវកិលេសទាំងឡាយ ឬញុំាងកិលេសទាំងឡាយឱ្យឆេះខ្លោច សុសសព្វ គប្បីធ្វើក្នុងថ្ងៃនេះឯង ។

បាទគាថា ថា **កោ ជញ្ញា មរណំ សុវេ** សេចក្ដីថា អ្នកណាទៅនឹងអាចដឹងបានថា ក្នុងថ្ងៃស្អែកអាត្មាអញនៅរស់ ឬក៏ ស្លាប់ ។

ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់សំដែងថា គប្បីធ្វើនូវសេចក្ដីព្យាយាមយ៉ាងនេះថា ការឃើតយូររមែងមានសូម្បីគ្រាន់តែក្នុងថ្ងៃនេះប៉ុណ្ណោះ ដោយគិតថា យើងនឹងធ្វើទានឬយើងនឹងរក្សាសីល ឬ យើងនឹងធ្វើនូវកុសលយ៉ាងណាមួយក្នុងថ្ងៃនេះឯង ។ យើងមិនញុំាងចិត្តឱ្យកើតឡើងថា ចាំស្អែកឬខានស្អែកទើបបានដឹងឬទើបបំពេញនូវកុសលទេ ប៉ុន្តែយើងគប្បីធ្វើក្នុងថ្ងៃនេះឯង ។

បទថា **មហាសេនេន** សេចក្ដីថា ហេតុការណ៍នៃសេចក្ដីស្លាប់ មានច្រើនយ៉ាងណាស់ មានភ្លើង ថ្នាំពិស និងសស្ត្រាវុធជាដើមនេះ គឺជាសេនារបស់មច្ចុរាជ ។

ការធ្វើនូវមេត្រីភាពយ៉ាងនេះថា អ្នកចូររង់ចាំពីរ បីថ្ងៃសិនចុះ ទំរាំខ្ញុំបានធ្វើនូវទីពឹងចំពោះខ្លួន មានការបូជាព្រះពុទ្ធជាម្ចាស់ជាដើមហើយស្រេច ឬគប្បីថា អ្នកចូរយក

ថ្លៃឈ្នួលមួយរយ ឬ មួយសែននេះហើយ សូមរង់ចាំពីរបីថ្ងៃសិន ឬថាយើងនឹងតទល់ដោយកងពលយ៉ាងនេះៗ ដូចនេះ ជាមួយមច្ចុរាជដែលមានសេនាដ៏ធំ ដោយអំណាចនៃសេនាធំនោះ រមែងមិនមាន ។

បទថា **អតន្ទិតំ** បានដល់បុគ្គលដែលមិនខ្ជិលច្រអូស គឺជាអ្នកព្យាយាម ។

សេចក្តីដែលបុគ្គលនោះជាអ្នកបដិបត្តិយ៉ាងនេះ ព្រោះដូច្នោះ បុគ្គលនោះឈ្មោះថា **ភទ្ទេករត្តោ** អ្នកមានរាត្រីមួយដ៏ចំរើន ។

ព្រះមុនីគឺព្រះពុទ្ធជាម្ចាស់ទ្រង់ស្ងប់ហើយ ព្រោះសេចក្តីដែលកិលេសទាំងឡាយ មានរាគៈជាដើមស្ងប់ហើយ ទ្រង់ត្រាស់ហៅបុគ្គលអ្នកបដិបត្តិយ៉ាងនេះនោះថា បុគ្គលនេះជាអ្នកមានរាត្រីមួយដ៏ចំរើន ដោយប្រការដូចនេះឯង ។

**ឥន្ទ្រិយនៃភទ្ទេករត្តសូត្រ និង អត្ថកថា**

**ចប់តែប៉ុណ្ណោះ**

αបញ្ចក្ខន្ធជាបច្ចុប្បន្ន បានលះបង់នូវបញ្ចក្ខន្ធជាអតីតៈអស់ទៅហើយ ម្យ៉ាងទៀត បញ្ចក្ខន្ធជាបច្ចុប្បន្នមិនអាចទៅដល់ ឬទៅជួប ខន្ធជាអនាគតបានឡើយ ។

α ព្រះនិព្វានផុតចាកកាលទាំងបី ។

αមានមនុស្សមួយចំនួនបានអស់សង្ឃឹម ហើយតក់ស្លុតក្នុងចិត្ត ដោយមកអំពីបានស្តាប់ធម៌ដែលសំដែង អំពីមិនមានតួខ្លួន និងមិនមានអ្វីជារបស់ខ្លួន គេមានសេចក្តីសោកតានតឹង ចង្អៀតចង្អល់ចិត្ត មិនជ្រះថ្លាក្នុងព្រះសទ្ធម្ម ។

មនុស្សដូចនេះ ត្រូវនឹងសេចក្តីឧបមាដូចតទៅ :

១-បុគ្គលត្រូវព្រួញពិសមុតដោតជាប់នឹងសាច់ ស្ទុះទៅគ្រប់ទិសទាំងពួង ដល់នូវសេចក្តីទុក្ខលំបាកពន់ពេក ។ កាលបានទៅជួបនឹងគ្រូបន្សាបពិស និង ជំនាញក្នុងការដកព្រួញ លោកគ្រូក៏បានពោលរៀបរាប់អំពីការដកព្រួញ និងដាក់ថ្នាំបន្សាបពិស បុគ្គលនោះក៏បែរជាភ័យតក់ស្លុត ខ្លាចបាត់ព្រួញពិសដែលដោតជាប់ក្នុងសាច់នោះទៅវិញ ហើយខំចាប់ទប់នូវព្រួញពិសរត់គេចចេញអំពីលោកគ្រូយ៉ាងប្រញាប់ ។

២-បុគ្គលជាប់គុក កាលមានអ្នកដទៃនាំចេញ អំពីគុក បែរជាប្រកែកមិនព្រមចេញ ដោយបានប្រកាន់ថា មិនមែនគុកទេ កន្លែងនេះជាផ្ទះរបស់ខ្ញុំទេតើ ឱ្យខ្ញុំទៅណា ខ្ញុំពេញចិត្តនឹងផ្ទះរបស់ខ្ញុំណាស់ ។

៣-បុគ្គលនៅរួមជាមួយសត្រូវ កាលមានអ្នកដទៃនិយាយប្រាប់ឱ្យរត់គេចចេញអំពីសត្រូវ បែរជាខឹងប្រទូស្តដល់អ្នកដែលមានបំណងល្អបាននិយាយប្រាប់នោះថា បំបែកបំបាក់គេ ដែលគេកំពុងតែស្រឡាញ់ស្និទ្ធស្នាលនឹងគ្នា ។

៤-បុគ្គលសំគាល់ពស់វែកថា ជាគ្រឿងអលង្ការ ព្រោះហេតុថាជាអ្នកល្ងង់ កាលមានអ្នកដទៃនិយាយប្រាប់ឱ្យលែងចោលហើយរត់ចេញ ក៏បែរជាចោទថា អ្នកប្រាប់នោះជាមនុស្សបោកប្រាស់ ចង់បានទ្រព្យសម្បត្តិគ្រឿងអលង្ការរបស់គេទៅវិញ ។

៥- បុរសបានប្រពន្ធជាយក្ខិនីក្លែងខ្លួន ដោយស្មានតែមនុស្សធម្មតា ព្រោះហេតុតែមិនដឹង និង ព្រោះសេចក្តីស្រឡាញ់ខ្លាំងពេកទៅ សូម្បីមានអ្នកដទៃនិយាយប្រាប់យ៉ាងណាក៏ដោយ ក៏មិនអាចលះបង់ប្រពន្ធនោះចោលបាន ដែរទោះទុក្ខលំបាកដោយសារយក្ខិនីប៉ុណ្ណា១ ក៏ចេះតែស៊ូទ្រាំហើយថែមទាំងមិនចង់ឮពាក្យអ្នកណាដែលនិយាយថា ប្រពន្ធរបស់ខ្លួនជាយក្ខិនីទៀតផង ។

៚ព្រួញពិស សត្រូវ គុក យក្ខិនី ពស់វែក ជាឈ្មោះនៃឧបាទានក្ខន្ធ ៥ ។

៚ការមុតជាប់នូវព្រួញពិស ការនៅរួមជាមួយសត្រូវ ការជាប់គុក ការបានយក្ខិនីជាប្រពន្ធ ការប្រដាប់តាក់តែងគ្រឿងអលង្ការដោយពស់វែក គឺជាឈ្មោះសក្កាយទិដ្ឋិ ។

៚បុរសបុគ្គលដែលមុតព្រួញពិសជាដើម គឺជាឈ្មោះបុថុជ្ជន អាស្រ័យវដ្តៈ ។

៚ព្រះធម៌ទេសនារបស់ព្រះសម្មាសម្ពុទ្ធ បង្ហាញហេតុនៃប្រយោជន៍៣យ៉ាង គឺប្រយោជន៍បច្ចុប្បន្នប្រយោជន៍បរលោក ប្រយោជន៍និព្វាន ព្រះនិព្វានជាប្រយោជន៍ដ៏ខ្ពង់ខ្ពស់គឺជាទីបញ្ចប់នៃព្រហ្មចរិយធម៌ ការបានសំរេចនូវប្រយោជន៍ដ៏ក្រៃលែង រមែងជាអ្នកលះបង់សម្បត្តិក្នុងលោក ព្រោះ

ព្រះនិព្វានជាសម្បត្តិប្រសើរលើស លោក ។

៙ទេវតាមិនអាល័យកាមគុណជារបស់មនុស្ស ព្រហ្ម មិនអាល័យកាមគុណជាទិព្វរបស់ទេវតា អ្នកបានសម្បត្តិ ព្រះនិព្វានរមែងមិនអាល័យភព ជាអ្នកប្រាសចាកការត្រេក-អរចំពោះបញ្ចាក្ខន្ធ ។

៙ពាក្យដែលថា **"មិនមានអ្វីជារបស់ខ្លួន"** មិនមែនបានសេចក្តីថាខ្លួនឯងមាន គ្រាន់តែខ្លួនឯងមិនមាន អ្វីៗនោះទេ តាមពិតក៏គឺសត្វបុគ្គលតួខ្លួនមិនមានហ្នឹងឯង ព្រោះតែខ្លួនឯងមិនមាន ទើបមិនមានអ្វីជារបស់ខ្លួន ប៉ុន្តែ នេះត្រូវតែជាបញ្ញាពិតៗរបស់ខ្លួនឯង ដែលបានឃើញនូវរូប ធម៌ និង នាមធម៌ មិនមែនបញ្ញារបស់អ្នកដទៃឃើញជំនួស បានឡើយ ។

៙តាមពិតការឃើញត្រូវ ចាក់ធ្លុះ យល់ច្បាស់ដោយ បញ្ញាថា លោកនេះសូន្យ គឺសូន្យចាកខ្លួនជាអ្នកឃើញរូបសូន្យ ចាកខ្លួនជាអ្នកឮសំលេង ដោយត្រឹមតែជាចិត្តដឹងអារម្មណ៍ ផ្សេងៗជាដើមប៉ុណ្ណោះ ឈ្មោះថាជាអ្នកបានដល់នូវទីបំផុតទុក្ខ គឺព្រះនិព្វានដែលមិនមានបច្ច័យ តាក់តែង ។

៙មានមនុស្សមួយចំនួនតែងតែឆ្ងល់ថា បើមិនមាន ខ្លួនទេ តើអ្នកណាជាអ្នកធ្វើបុណ្យ ហើយអ្នកណាជាអ្នកធ្វើ បាប សូមអ្នកឆ្ងល់ទាំងឡាយ ពិចារណាតទៅទៀតមើល ចំពោះហេតុដែលនាំឱ្យកើត ចេតនាជាតួកម្មគ្រប់យ៉ាង ។

តើសមគួរនឹងយល់ឃើញថា ហេតុបច្ច័យដែលនាំឱ្យ កើតកម្ម បុណ្យ ឬបាបនោះ ជាសត្វបុគ្គលពិតឬ ? តើនរណា ចង់ធ្វើកិលេស គ្រឿងសៅហ្មងឱ្យខ្លួនឯង តើអ្នកណាចង់សាង អំពើអាក្រក់ឱ្យខ្លួនឯង ដូចម្តេចក៏មិនសាងតែចិត្តល្អ អំពើល្អ តែម្យ៉ាងទៅ ។

ទារកកើតមកចេះខឹង ចេះស្រឡាញ់ ។ល។ តើទារក ហ្នឹងចេះធ្វើចិត្តអីចឹងដោយខ្លួនឯង ឬ ? ដូច្នេះពាក្យដែលអ្នក សួរថា បើមិនមានខ្លួនទេ តើអ្នកណាជាអ្នកធ្វើបុណ្យ ហើយ អ្នកណាជាអ្នកធ្វើបាបនោះ សំនួរនេះមិនត្រូវទេ គឺសួរខុសចាក ប្រធានហើយ ព្រោះប្រធានបានប្រាប់ហើយថា **"ធម៌ទាំង ឡាយជាអនត្តា "** តែគប្បីសួរដូច្នេះវិញថា បើមិនមាន

ខ្លួនទេនោះ តើបុណ្យឬបាប កើតមានព្រោះអ្វីជាបច្ច័យ ? ឯចំឡើយត្រូវឆ្លើយ ថា បុណ្យឬបាបកើតមាន ព្រោះឧបាទាន គឺការប្រកាន់មាំនូវនាមរូបជាបច្ច័យ ព្រោះថា កាលបើប្រកាន់មាំនូវនាមរូបហើយ សកម្មភាពជាខាងក្នុង មានបុណ្យ មានបាប ដើម្បីការពារហួងហែងនូវនាមរូបនោះឯង រមែងកើតឡើង បើការប្រកាន់មាំមិនមាន ពោលគឺរលត់អស់ទៅហើយនោះ សកម្មភាពនៃការហួងហែងនាមរូបក៏ពុំមាន នេះគឺការអស់ ទៅនៃកម្ម ស និង កម្ម ខ្មៅ ។

**សួរ:** បើមិនមានខ្លួនទេនោះ ចាំបាច់ខំប្រឹងធ្វើបុណ្យបាន ប្រយោជន៍អ្វី ?

**ឆ្លើយ:** ខំធ្វើបុណ្យឱ្យមានបញ្ញា មានបញ្ញាដើម្បីឃើញបញ្ចក្ខន្ធ សូន្យចាកសត្វបុគ្គលតួខ្លួនពិត១ ដោយមិនមានការសង្ស័យ ។ បុណ្យជាគ្រឿងប្រដាប់ចិត្ត ជាអលង្ការរបស់ចិត្ត បុណ្យមានឧបការៈដល់បញ្ញា បើបញ្ញាចាក់ធ្លុះដោយខ្លួនឯងពិត១ ឃើញថាមិនមានតួខ្លួន ជាសត្វ ជាបុគ្គលមែនប្រាកដនោះ ការសង្ស័យថា តើខំប្រឹងធ្វើបុណ្យបានប្រយោជន៍អ្វីមិនមានឡើយ ឬសង្ស័យថា តើអ្នកណាជាអ្នកធ្វើបុណ្យក៏មិនមានដែរ ។ ដូច្នេះ ព្រះសម្មា សម្ពុទ្ធសំដែង **សព្វេធម្មា អនត្តា " ធម៌ទាំងពួងមិន មែនខ្លួន "** ព្រះពុទ្ធវចនៈនេះ មិនមែនសំរាប់ឱ្យសង្ស័យ យ៉ាងនេះ សង្ស័យយ៉ាងនោះឡើយ តែសំរាប់អប់រំបញ្ញានៃពុទ្ធបរិស័ទ ដើម្បីពុទ្ធបរិស័ទមានស្មារតីមានសម្បជញ្ញៈ ស្រាវជ្រាវរាវរកសច្ចធម៌ ត្រាស់ដឹងដោយបញ្ញារបស់ខ្លួនឯងពិត១ មិនមែនបញ្ញាអ្នកដទៃឡើយ ។

αការរកឃើញ **អមតៈ** គឺសេចក្តីមិនស្លាប់នៅក្នុងព្រះពុទ្ធសាសនា តាមរយៈនៃបញ្ញាឃើញអនត្តាក្នុងបញ្ចក្ខន្ធនេះឯង ។

αផ្តើមដោយការមានសតិសង្កេតពិនិត្យនូវសភាវធម៌មួយលក្ខណៈមួយលក្ខណៈ ជាប្រក្រតីក្នុងជីវិតប្រចាំថ្ងៃសន្សឹម១ក្នុងការលះសេចក្តីមិនដឹង និង សេចក្តីប្រកាន់សភាវ-ធម៌ ថាជាតួខ្លួន ។

αត្រឹមតែចិត្តឃើញ ត្រឹមតែចិត្តឮ ត្រឹមតែចិត្ត ដឹងក្លិន ត្រឹមតែចិត្តដឹងរស ត្រឹមតែចិត្តដឹងផោដ្ឋព្វៈ ត្រឹមតែចិត្តជ្រាបនូវរឿង ជ្រាបនូវធម្មារម្មណ៍ កាលណាបើត្រឹមតែចិត្តប៉ុណ្ណោះ កាលនោះខ្លួនយើងមិនមានឡើយ ។

αមិនមែនគ្រប់គ្រាន់ត្រឹមតែស្តាប់យល់ គិតយល់នោះទេ ត្រូវអប់រំការរលឹករឿយៗនូវពេលសភាវធមិកំពុងប្រាកដ មានតែការរលឹករឿយៗនេះឯង ទើបញ៉ាំងទីពឹងឱ្យសំរេចបាន ។

αវៀរចាកព្រះពុទ្ធសាសនា ឬថាបើមិនមានការត្រាស់ដឹងនៃព្រះសម្មាសម្ពុទ្ធទេនោះ ការបដិបត្តិអប់រំសតិប្បដ្ឋានក្នុងជីវិតប្រចាំថ្ងៃ សិក្សានូវសភាវធមិ ពិតជាពុំកើតមានក្នុងបច្ចុប្បន្នសម័យនេះឡើយ ។

α បើមិនអប់រំរឿយៗ បដិបត្តិជាប្រក្រតីនូវសតិរលឹករូបធមិ នាមធមិទេនោះ មិនអាចឃើញព្រះពុទ្ធបានទេ ។

αជីវិតនេះកើតមក សំរាប់តែដោះស្រាយនូវបញ្ហាដែលជាប់តាមជីវិតខ្លួនឯងមកតែប៉ុណ្ណោះ ទាំងការដោះស្រាយនោះ បើវៀរចាកការចំរើនសតិប្បដ្ឋានហើយ ក៏មិនអាចបញ្ចប់បញ្ហាបានឡើយ ។ និព្វានជាទីបំផុតនៃបញ្ហាជាទីបំផុតទុក្ខ ។

**៣_សង្ខតា ធម្មា :** ធមិទាំងឡាយជាសង្ខតៈ ធមិដែលឈ្មោះថា **សង្ខត** ព្រោះបច្ច័យទាំងឡាយប្រជុំគ្នាតាក់តែង ។

បានដល់ខន្ធ ៥ ដូចពួកធមិជា **សប្បច្ចយា ធម្មា** ដែរ ។

αការអប់រំចិត្ត ការទូន្មានចិត្ត ជាការងារសំខាន់ជាងគេទាំងអស់ ព្រោះសេចក្តីស្រឡាញ់ ឬ ស្អប់ គាប់ចិត្ត ឬទាស់ចិត្ត ការត្រេកអររំជើបរំជួល ឬការភ័យព្រួយ ។ល។ ទាំងអស់នេះ ព្រោះតែមានចិត្ត ។ នៅក្នុងពេលណា ក៏មានចិត្តដែរ ហើយនៅក្នុងពេលណាក៏អាចអប់រំចិត្តបានដែរ ទាំងដែលជាចិត្តរបស់ខ្លួនឯង ដោយមិនចាំបាច់ខ្ចីឬសុំចិត្តអ្នកដទៃ ដើម្បីយកមកអប់រំទូន្មានឡើយ ។

## ការអប់រំទូន្មានចិត្តដោយវិធីដូចម្តេច ?

αការធ្វើទានជាការប្រដៅអប់រំទូន្មានចិត្ត ព្រោះថាចិត្តខូច ចិត្តអាក្រក់ គឺចិត្តជាបាបអកុសល ដូច្នេះត្រូវធ្វើទានឱ្យបានរឿយៗ ជាឧបនិស្ស័យនៃការលះបង់កិលេសឱ្យបានទៅជាទម្លាប់ក្នុងការឱ្យជានិច្ចជាកាល ទោះវត្ថុនោះតិចឬច្រើនក៏ដោយ រហូតដល់លះបង់បាននូវគំនិតដែលគិតថា មិនគួរឱ្យនូវរបស់ដែលគួរឱ្យ ។

αការឱ្យនូវទេយ្យវត្ថុសូម្បីបន្តិចបន្តួច ក៏អាចឱ្យអ្នកដទៃរស់រានមានជីវិតបានដែរ គួររីករាយនៅក្នុងកុសលធមិ គួរហ្វឹកហាត់ចិត្តឱ្យចេះមានមេត្តា ឱ្យចេះមានសេចក្តីថ្លៃថ្នូរ ហ្វឹកហាត់យ៉ាងណាឱ្យចិត្តទៅជាទន់ភ្លន់ ចេះរីករាយក្នុងការឱ្យសេចក្តីសុខទៅអ្នកដទៃ ។

αត្រូវដាស់តឿនចិត្តជារឿយៗថា សម្បត្តិអ្វីនៅក្នុងលោកនេះ មិនមែនជារបស់ចិត្តឯងទេ ចិត្តឯងកើតមកក៏មិនបានយកមក ចិត្តឯងរលត់ទៅវិញក៏មិនមែនយកទៅជាមួយឡើយ ។

αចិត្តកើតឡើងអាស្រ័យអារម្មណ៍ណា ចិត្តត្រូវព្រាត់ប្រាស់ចោលនូវអារម្មណ៍នោះទៅវិញជានិច្ច ដូច្នេះចិត្តឯងមិនត្រូវកំណាញ់ មិនត្រូវហួងហែង មិនត្រូវវង្វេងឆ្កួត ដោយសារ

អារម្មណ៍ក្នុងលោកឡើយ ។

⍺មនុស្សដែលល្អប្រសើរ តើមនុស្សដូចម្តេច ? គឺមនុស្សដែល ចេះទូន្មានខ្លួនឯង ប្រដៅខ្លួនឯង ។

⍺ក្នុងលោកមនុស្ស លោកទេវតា មារព្រហ្ម តើបុគ្គលប្រភេទណា ដែលទូន្មានបានដោយកម្រ ? គឺខ្លួនឯងហ្នឹងឯងដែលប្រដៅ ទូន្មានបានដោយកម្រ ។

⍺តើអ្វីទៅជាខ្លួនដែលត្រូវប្រដៅអប់រំទូន្មាន ? គឺចិត្តហ្នឹងឯង ។

⍺ការចែកបុណ្យកុសលឱ្យដល់អ្នកដទៃ គឺជាការប្រដៅចិត្តមួយផ្នែក ដើម្បីកុំឱ្យចិត្តគិតបានអ្វីៗតែខ្លួនឯង ត្រូវចេះបែងចែក របស់ប្រសើរឱ្យអ្នកដទៃ ទូន្មានចិត្តឱ្យចេះអើពើក្នុងអំពើល្អដោយយកចិត្តទុកដាក់ ការជូនបុណ្យគឺជូនដោយចិត្តមេត្តា ដោយចិត្តទន់ភ្លន់ ជូនដើម្បីឱ្យអ្នកដទៃបានបុណ្យពិតៗ ព្រោះអនុមោទនា ។

⍺ការអនុមោទនាបុណ្យកុសលដែលអ្នកដទៃបាន ធ្វើឬបានជូន ក៏ជាការប្រដៅចិត្តមួយផ្នែកទៀត កុំឱ្យចិត្តរឹងរូសប្រកាន់ទិដ្ឋិមានះលើកកំពស់ខ្លួន តែធ្វើឱ្យចិត្ត ទន់ភ្លន់ស្ងប់ស្ងាត់ កំចាត់ការប្រកាន់ខ្លួន ឃើញបុណ្យកុសលជាធំជាងទ្រព្យសម្បត្តិមាសប្រាក់ក្នុងលោក ប្រដៅទូន្មានចិត្តឱ្យស្គាល់គុណតំលៃនៃសេចក្តីល្អ ចេះជ្រះថ្លាក្នុងបុណ្យកុសលរបស់អ្នកដទៃ ឃើញអ្នកដទៃដែលមានសេចក្តីល្អផ្សេងៗ ថាជាអ្នកមានគុណ គឺមានគុណចំពោះខ្លួនយើងផង ចំពោះអ្នកដទៃច្រើនផង ចំពោះសាសនាផង កាលដែលអ្នកដទៃនោះជាអ្នកមានសទ្ធា មានសីល មានចាគៈជាដើម ត្រូវទូន្មានចិត្តឱ្យចេះដឹងគុណអ្នកដទៃ កុំបំភ្លេច កុំលុបបំបាត់ចោលនូវគុណ គឺសេចក្តីល្អរបស់អ្នកដទៃ ព្រោះហេតុនេះ ចិត្តត្រូវតែយល់ដល់អំពើល្អគ្រប់យ៉ាង ដោយមិនប្រកាន់ឬកពា ចើងម៉ើងឆ្មើងឆ្មៃ មើលងាយឬខឹងក្រោធជាមួយអ្នកដទៃឡើយ មនុស្សល្អម្នាក់អាចឱ្យការរស់នៅ និង សេចក្តីសុខដល់អ្នកដទៃច្រើនអ្នកណាស់ក្នុងមួយថ្ងៃៗ ដូច្នេះ គួរប្រមូលមនុស្សល្អទាំងនោះឱ្យមកជាខ្លួនយើងតែម្នាក់ ដោយការអនុមោទនាជ្រះថ្លាត្រេកអរនូវអំពើល្អដែលអ្នកដទៃមាន ជួនកាលអំពើល្អនោះ យើងមិន

អាចធ្វើបានផង តើគួររីងរូសខឹងប្រកែកឈ្លោះ ឬក៏ត្រូវប្រដៅចិត្តឱ្យស្ងួត ហើយជ្រះថ្លាទទួលយកនូវបុណ្យ ដោយការអនុមោទនាវិញ ? ម្យ៉ាងវិញទៀត បើយើងសំឡឹងមើលគុណគឺសេចក្ដីល្អរបស់អ្នកដទៃហើយ ឱ្យតម្លៃយ៉ាងថ្លៃពិត១ រមែងកំចាត់នូវចិត្តអាក្រក់របស់យើង មានការមើលងាយអ្នកដទៃ ដោយអាងទ្រព្យសម្បត្តិវង្សត្រកូល ជាដើមទៀតផង ។

αការមានសីល៥ ជាដើម សុទ្ធតែជាការប្រដៅអប់រំចិត្ត ជាម្លប់ត្រជាក់របស់ចិត្ត ជាគ្រឿងអលង្ការរបស់ចិត្ត ចិត្តមានសេចក្ដីសុខច្រើនព្រោះមានសីល ។

អ្នកមានសីលបានឱ្យសេចក្ដីសុខដល់អ្នកដទៃច្រើនណាស់ ព្រោះតែខ្លួនឯងជាអ្នកសម្បូរសេចក្ដីសុខ ។

αអ្នកមានសីល បានឱ្យជីវិតគឺការរស់នៅដល់មនុស្សសត្វទាំងឡាយពេញពិភពលោក ព្រោះចេតនាវៀរចាកការសំលាប់ជីវិតសត្វ ។

ជីវិតរបស់សត្វលោក មានតម្លៃសំរាប់សត្វលោកណាស់ មិនមានអ្នកណាចង់ស្លាប់ទេ លើកលែងតែអ្នកមានវិបត្តិផ្លូវចិត្ត ទាំងវិបត្តិផ្លូវចិត្តនេះទៀតសោត ក៏ព្រោះមកអំពីការស្រឡាញ់ជីវិតហ្នឹងឯង ដើម្បីពិចារណាឱ្យឃើញគុណតម្លៃនៃសីលទី១ គឺការឱ្យជីវិតដល់អ្នកដទៃនោះប្រសើរប៉ុណ្ណា ត្រូវពិចារណាដល់ការសម្លាប់វិញ តើអ្នកសម្លាប់ជីវិតគេបានឱ្យសេចក្ដីទុក្ខយ៉ាងម៉េចខ្លះដល់អ្នក ដទៃ ?

ព្រោះហេតុមិនដឹងខ្លួនឯងត្រឹមតែបញ្ចកូន្ទ ដែលបញ្ចកូន្ទនេះ គឺជាអ្នកសំលាប់ខ្លួនឯងនោះ ក៏រមែងគាំទ្រលើកតំកើងយ៉ាងសំខាន់ ដោយការប្រកាន់មាំរហូតដល់ទៅហ៊ានសម្លាប់អ្នកដទៃ ។

អ្នកដទៃកាលត្រូវគេសម្លាប់ហើយ ក៏រមែងព្រាត់ប្រាសចោល នូវរបស់ដែលជាទីស្រឡាញ់ ស្លាប់ទៅទាំងការតក់ស្លុត ...។

ញាតិមិត្តបងប្អូន ភរិយា ឬ ស្វាមី កូនចៅ យំស្រែកជ្រួលច្របល់ សោយសោកបោកខ្លួន ព្រោះហេតុតែបុគ្គលជាទីស្រឡាញ់ត្រូវបាត់បង់ជីវិតដោយសារការសម្លាប់ ដូច្នេះ

យើងម្នាក់ឯងមិនត្រូវផ្តល់ នូវសេចក្តីទុក្ខតូចធំឱ្យដល់អ្នកដទៃសូម្បីតែម្នាក់ឡើយ ត្រឡប់មកវិញ ត្រូវផ្តល់ឱ្យនូវសេចក្តីសុខ ការជួបជុំ ការមិនភ័យខ្លាច ដោយមេត្តាចិត្តដ៏ត្រជាក់ក្នុងចេតនាសីល វៀរចាកការសម្លាប់ជីវិតសត្វ ។

ការវៀរចាកអំពើកាប់សម្លាប់ សូម្បីតែសត្វតិរច្ឆានក៏មិនត្រូវសម្លាប់ដែរ ត្រូវឱ្យការរស់នៅដល់សព្វសត្វទាំងអស់ សូមឱ្យចិត្តជ្រកនូវក្រោមម្លប់មេត្តាធម៌ និង ករុណាធម៌ជាដរាប ។

αចេតនាសីលទី២ គឺជាអ្នកឱ្យនូវទ្រព្យសម្បត្តិដល់អ្នកដទៃ ឱ្យអ្នកដទៃមិនភ័យ មិនខ្លាច មិនព្រួយបារម្ភ ឱ្យអ្នកដទៃមានទឹកមុខ ស្រស់បស់រីករាយសុខុមក្សេមក្សាន្តនៅក្នុងគ្រួសារ ។ អ្នករស់នៅមានទ្រព្យសម្បត្តិចង់បានអ្វីៗក៏សំរេចបានតាមបំណងប៉ងប្រាថ្នា ប៉ុន្តែកុំភ្លេចថា ដោយសារអ្នកមានសីលហ្នឹងឯង ទើបអ្នកមិនវិនាសបាត់បង់នូវទ្រព្យសម្បត្តិ អ្នកមានសីលគឺជាអ្នកមានគុណចំពោះសព្វសត្វក្នុងលោក ។

αមិនគប្បីជ្រុបមុខនៅក្នុងទ្រព្យសម្បត្តិឡើយ ព្រោះថា បើវិញ្ញាណរលត់បាត់ក្នុងពេលណា សេចក្តីដឹងថាជាទ្រព្យសម្បត្តិច្រើនឬតិច ពុំមាននៅក្នុងសាកសពឡើយដូច្នេះជីវិតរាល់ថ្ងៃដែលអាចដឹងអ្វីៗបាន គឺវិញ្ញាណប៉ុណ្ណោះ មិនមានសត្វបុគ្គលជាតួខ្លួន ។

αការបានទ្រព្យសម្បត្តិច្រើនប៉ុណ្ណា ក៏នៅតែដឹងខ្លួនថាមិនទាន់គ្រប់ ប៉ុន្តែការបាននូវធម៌គឺបញ្ញា ដោយដឹងច្បាស់ថាអ្នកបាននូវទ្រព្យសម្បត្តិនោះពុំមានទេ គឺមានត្រឹមតែចិត្តវិញ្ញាណប៉ុណ្ណោះ ដែលកើតមកដឹងនូវអារម្មណ៍ ក្នុងលោកចិត្តវិញ្ញាណពុំអាចស្ថិតនៅក្នុងលោកបានទេ ត្រូវរលត់សូន្យទៅវិញ ចិត្តវិញ្ញាណដទៃកើតមកបន្តជាប់ជានិច្ច ការបានឃើញធម៌ពិតៗ រមែងរីករាយហើយស្ងប់រំងាប់ចិត្ត លះបង់ចោលនូវសម្បត្តិក្នុងលោក ព្រោះឃើញត្រឹមតែជាអារម្មណ៍របស់វិញ្ញាណប៉ុណ្ណោះ តាមទ្វារទាំង៦ នោះឯង ។

αពាក្យពោលថាលះបង់ចោលនូវសម្បត្តិក្នុងលោក គឺលះការត្រេកអរពេញចិត្តក្នុងសម្បត្តិនោះៗ ព្រោះវិញ្ញាណត្រូវបានទូន្មានហ្វឹកហាត់ឱ្យចេះដឹងនៅក្នុងអារម្មណ៍ ឱ្យឃើញ

ច្បាស់ អារម្មណ៍ក្នុងលោក គឺជាចំណងអន្ទាក់របស់មារ ។

៚មារចងសត្វលោកតាមរយៈចិត្តវិញ្ញាណដឹងអារម្មណ៍ក្នុងទ្វារ៦ សត្វលោកវង្វេងស្មារតី ប្រកាន់វិញ្ញាណនោះៗថាជាខ្លួនទើបជាប់ចំណង ។

៚សត្វជាប់អន្ទាក់នាយព្រាន ព្រោះមិនបានដឹងថា ជាអន្ទាក់ សត្វណាដឹងជាក់មិនជាប់អន្ទាក់ឡើយ ។

៚អារម្មណ៍ជាទីប្រាថ្នាក្នុងលោក ប្រៀបបីដូចទឹកឃ្មុំលាយដោយថ្នាំពិសពុល ឬទឹកឃ្មុំដែលជាប់នៅនឹងមុខដាវដ៏សែនមុត មិនគួរដល់ការលិទ្ធភ្លក្សឡើយ ។

៚ធម្មជាតិដែលឈ្មោះថាចិត្តសែនល្អិត មានប្រក្រតីធ្លាក់ចុះក្នុងអារម្មណ៍ដែលខ្លួនធ្លាប់ត្រូវការ ធ្លាប់សន្សំនូវចំណូល ចូលចិត្តក្នុងកាមារម្មណ៍ទាំងឡាយ ដូច្នេះ អ្នកមានសីលទី៣ កាលដែលវៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយហើយ គួរតែគ្រប់គ្រងចិត្តក្នុងការដែលកាន់យកនូវនិមិត្តមកទុកទំពាអៀងដូចសត្វគោ ពោលគឺកាមវិតក្កៈប្រែថាការត្រិះរិះនៅក្នុងវត្ថុកាម និង កិលេសកាម ។

៚ត្រូវទូន្មានចិត្តឱ្យរឿយៗដោយសតិបញ្ញា ត្រូវឱ្យចិត្តដឹងថា ការទទួលដឹងនូវកាមារម្មណ៍តាមបញ្ចទ្វារត្រឹមតែចិត្តវិញ្ញាណប៉ុណ្ណោះ ។

៚កាលណាបុគ្គលមិនលេបនូវកាមារម្មណ៍ យកមកសន្សំទុកក្នុងចិត្តទេនោះ ចិត្តវាមិនទំពាអៀង គឺត្រិះរិះក្នុងកាមទាំងឡាយឡើយ ។

៚ដើម្បីមិនលេបចូលនូវកាមារម្មណ៍ ត្រូវតែបញ្ញាឃើញនូវអារម្មណ៍នោះៗ វារលត់គ្រប់គ្រា គ្រប់ពេលវេលាដែលវាបានកើតឡើង ព្រមទាំងវិញ្ញាណដែលបានកើតឡើងដឹងនូវអារម្មណ៍នោះៗ ក៏ឃើញការរលត់ទៅវិញនៃវិញ្ញាណនោះៗ។

៚ការមិនប្រព្រឹត្តខុសក្នុងកាម គឺជាការឱ្យភរិយា ស្វាមីក្រុមគ្រួសារ បងប្អូន កូនចៅនៃអ្នកដទៃបាននូវសេចក្តីសុខ ឱ្យកិត្តិយស ឱ្យនូវការមិនឈ្លោះទាស់ទែងដល់អ្នកដទៃ ។

៚បុគ្គលណាឱ្យអ្វីៗដល់អ្នកដទៃ ចេតនារមែងជាគ្រាប់

ពូជនៃអ្វីនោះ មានឱកាសនឹងដុះជាពុំខាន ។

αគួរសប្បាយចិត្តក្នុងជីវិតនេះដែលកើតមក អាចមានឱកាសឱ្យសេចក្ដីសុខដល់អ្នកដទៃ ។

αសីលទី៤ គឺឱ្យការពិតប្រាកដដល់អ្នកដទៃ ឱ្យការមិនវង្វេងមិនច្រឡំ អ្នកដែលនិយាយតាមពិត គឺមានសំដីជាផ្កាក្លិនក្រអូប និយាយពីរោះ មានប្រយោជន៏ដល់អ្នកស្ដាប់ គឺវាចាទឹកឃ្មុំ ប៉ុន្តែផ្ទុយមកវិញ បុគ្គលពោលមុសា គឺមានវាចាលាមក ។

αឈើពុកអណ្ដែតទឹក ប្រសើរជាងមនុស្សនិយាយកុហក ។

αគួរព្យាយាមលះបង់ការនិយាយកុហក គ្រាន់ដើម្បីសើចលេងជាដើម ។

αត្រូវហ្វឹកហាត់ចិត្តឱ្យគិតនិយាយតែពាក្យល្អៗ ពាក្យមានប្រយោជន៏ ។

# វាចាល្អ ៥យ៉ាង ក្នុង មជ្ឈិមនិកាយ មូលបណ្ណាសកៈ

១-និយាយក្នុងកាលពេលវេលាដែលគួរនិយាយ ត្រូវស្គាល់កាលជាសំខាន់ ។

២-និយាយពាក្យពិតតាមដែលបានដឹង ជាពិសេសទោសកំហុសរបស់ខ្លួនឯង ទោសកំហុសប្រៀបបីដូចជាចោរដែលត្រូវចាប់យកមកបើកមុខ ប៉ុន្តែត្រូវស្គាល់កាល ស្គាល់បុគ្គល ស្គាល់បរិស័ទដែលត្រូវនិយាយ ។

៣-និយាយពាក្យពីរោះ សុភាពរាបសារ មិនទ្រគោះបោះបោក មិនលើកឡើងនូវពាក្យបញ្ឈឺចិត្តស្ងប់ស្ងាត់តាមផ្លូវគំនិត មិនគិតបៀតបៀនអ្នកណា ដោយវាចាឡើយ ។

៤-និយាយពាក្យមានប្រយោជន៏ ធ្វើឱ្យអ្នកស្ដាប់ស្ងប់រំងាប់ចិត្ត សូម្បីនិយាយតែបន្តិចបន្តួចក៏ដោយ កុំចេះតែនិយាយឱ្យតែឮសូរដូចលាជផ្ទុះ មុននឹងនិយាយត្រូវគិតជានិច្ច

បើដឹងច្បាស់ថា មានប្រយោជន៏សុំនិយាយ បើបានយ៉ាងនេះ មែននោះ គ្រាន់តែគ្រហែមក៏គេចង់ស្តាប់ដែរ ។

αត្រូវសន្សំសំចៃពាក្យសំដីទុកនិយាយតែពាក្យមាន ប្រយោជន៏ ពាក្យមានប្រយោជន៏មានតម្លៃជាងពេជ្រ ។

៥-និយាយដោយចិត្តប្រកបដោយមេត្តាពិត។ ចិត្តមាន មេត្តាជាចិត្តសប្បុរស តែងអនុគ្រោះនូវប្រយោជន៏ដល់ពពួក ជនសព្វសត្វទាំងអស់មិនរើសមុខ ព្រោះបានជ្រាបដោយបញ្ញា ថា សត្វណា បុគ្គលណាក៏ដោយ សុទ្ធស៊ីងតែប្រាថ្នាសេចក្តីសុខ ភ័យខ្លាចទុក្ខលំបាក ។

αសត្វលោកកើតមកមាន ចិត្ត វិញ្ញាណ ចេះស្រឡាញ់ ជីវិតរបស់ខ្លួន ប្រាថ្នាសេចក្តីសុខ និង ការជួបជុំក្រុមគ្រួសារ ដូច្នេះមនុស្សលោកគួរតែមានមេត្រីភាពដល់គ្នានិងគ្នា ព្រម ទាំងសត្វលោកទាំងអស់ទៀតផង ។

αសូមមនុស្សលោកកុំគប្បីមានគំនិតថា មានតែអាត្មា អញប៉ុណ្ណោះទេដែលចេះចង់បានសុខ ចេះភ័យខ្លាចការព្រាត់ ប្រាសក្រុមគ្រួសារ ប៉ុន្តែសូមឱ្យមនុស្សលោកចេះឃើញចិត្ត នៃគ្នានិងគ្នា ហើយព្រមឱ្យសេចក្តីសុខ ឬឱ្យការមិនមានភ័យ ដល់អ្នកដទៃ ដូចការឱ្យមកដល់ខ្លួនឯងអញ្ចឹងឃើញអ្នក ដទៃអស់ភ័យ ដូចខ្លួនឯងជាអ្នកអស់ភ័យ ឃើញអ្នកដទៃបាន សុខ ដូចខ្លួនឯងជាអ្នកបានសុខ ព្រោះចិត្តជាធម្មជាតិមិនមែន យើង ហើយក៏មិនមែនអ្នកដទៃដែរ ប៉ុន្តែកាលដែលសន្មតគ្នា ថា ជាសត្វលោកយ៉ាងណា។នោះ ក៏មិនចាំបាច់ប្រកាន់ខ្លួនឯង ឱ្យផ្សេងគ្នាអំពីអ្នកដទៃឡើយ បើដកឈ្មោះសន្មតិចេញ ហើយ គឺវាមានត្រឹមតែចិត្ត ចេតសិក និង រូបតែប៉ុណ្ណោះ ដែលត្រូវតែស្មើគ្នា ដូច្នេះសុខទុក្ខរោគភ័យរបស់អ្នកដទៃ ដូច ជារបស់យើងដែរ ឬថាសុខទុក្ខរបស់យើងក៏ដូចជារបស់អ្នក ដទៃ គឺវាមិនមានអ្វីពិតប្រាកដជាយើង ឬអ្នកដទៃឡើយ ពិតបានត្រឹមតែការសន្មតិ ប៉ុណ្ណោះឯង។

αគេច្របាច់ដុំដីមួយដុំឱ្យមានរូបរាងជាសត្វគោ ឬសត្វ ទន្សាយ ច្រើនដុំទៀតធ្វើជាសត្វផ្សេង។ ដុំខ្លះគេច្របាច់ធ្វើ ជាមនុស្ស ដោយសាររូបរាងគេអាចស្គាល់បានថា ជាមនុស្ស ប្រុស មនុស្សស្រី គោ ក្របី ដំរី សេះ ។ល។ ប៉ុន្តែ

វាត្រឹមត្រូវណាស់ ដែលមនុស្សសត្វទាំងអស់នោះធាតុពិតគឺដុំដី យ៉ាងណាមិញ ចិត្តចេតសិករូប គឺជាធាតុពិតនៃសព្វ សត្វទោះជាផ្សេងប្រភេទលក្ខណៈ ឬទ្រង់ទ្រាយសណ្ឋានគ្នាយ៉ាងណាក៏ដោយ ដូចជាដុំដីដែលគេច្របាច់ឱ្យមានរាងផ្សេងៗ យ៉ាងនោះដែរ ។

αព្រះអរិយបុគ្គលកាលត្រាស់ដឹងនូវខន្ធ៥ ហើយ រមែងមិនប្រកាន់ខន្ធ៥ ថាជាខ្លួន មិនប្រកាន់ខ្លួនថាមាននៅក្នុងខន្ធ៥ មិនប្រកាន់ខ្លួនថាផ្សេងអំពីខន្ធ៥ ព្រះអរិយបុគ្គលលោកធ្វើដំណើរទៅកាន់និរោធតាមអរិយមគ្គដ៏ប្រសើរ ។

αសីលទី៥ គឺជាការទូន្មានចិត្តកុំឱ្យភ្លើតភ្លើននៅក្នុងកាមារម្មណ៍ ត្រូវឱ្យចិត្តតាំងនៅក្នុងការមានស្មារតី ដូច្នេះទើបត្រូវវៀរចាកការបរិភោគទឹកស្រវឹងផ្សេងៗ ។

αសតិគឺជាសារថីដ៏ប្រសើរ ហ្វឹកហាត់នូវចិត្ត នាំផ្លូវចិត្តមិនឱ្យវង្វេងទៅតាមផ្លូវបាបកម្មផ្សេងៗ ។

αសតិគឺជាថ្នាំព្យាបាលរោគផ្លូវចិត្ត ជាថ្នាំពូកែស័ក្តិ សិទ្ធិ ។

αមនុស្សអត់ស្មារតីដូចដំរីអត់ហ្ម មនុស្សអត់ធមិល្អ ដូចផ្គរអត់ភ្លៀង មិនគួរបំផ្លាញស្មារតីខ្លួនឯងដោយការបរិ-ភោគនូវទឹកស្រវឹងឡើយ គួរតែវៀរចាកសូម្បីបន្តិចបន្តួច ឬ ម្តងម្កាល ។

αសតិមានគុណរាប់មិនអស់ មានតម្លៃដ៏ខ្ពង់ខ្ពស់ ត្រូវតែថែទាំរក្សាជាងសម្បត្តិទ្រព្យដែលមានតម្លៃទៅទៀត ។

αម្តាយរក្សាកូនប្រុសតែមួយមិនឱ្យមានខ្ចោះ សូម្បីស្រមោចតូចមួយក៏ចាប់បេះចេញ ។ល។ យ៉ាងណាបុគ្គលគួររក្សាស្មារតីរបស់ខ្លួនឯងក៏យ៉ាងនោះដែរ មិនត្រូវបរិភោគទឹកស្រវឹងឡើយ ។

αបុរសមានភ្នែកតែម្ខាង ខិតខំរក្សាភ្នែកម្ខាងនោះយ៉ាងណា បុគ្គលត្រូវរក្សានូវសតិរបស់ខ្លួនឯងឱ្យយ៉ាងហ្មត់ចត់ជាងភ្នែកទៅទៀត ។

αសតិមាននៅក្នុងបុគ្គលណា បុគ្គលនោះមិនឆ្កួតទេ កុំបំផ្លាញសតិខ្លួនឯង ត្រូវសាងសន្សំបុណ្យកុសលឱ្យច្រើន ដើម្បីបណ្តុះពូជស្មារតី និងរក្សាស្មារតីឱ្យចំរើនជាភិយ្យោភាព ។

α សូមកុំស្លាប់មុនដល់ថ្ងៃស្លាប់ ។

αចិត្តនៃបុគ្គលណាដែលមានសតិជាគ្រឿងរក្សា ចិត្តនៃបុគ្គលនោះមានសេចក្តីសុខ ត្រជាក់ក្សេមក្សាន្ត ។

αសីលជាសំលៀកបំពាក់របស់ចិត្ត ជាគ្រឿងអលង្ការទាំងចិត្តទាំងកាយ បុគ្គលណាជាអ្នកមានសីល បុគ្គលនោះមានរូបកាយសមរម្យល្អ ។

αសីលគឺជាទីពឹងរបស់បុរសស្ត្រីក្នុងលោកនេះ រូបកាយតែងតែចាស់ជរាព្យាធិគ្រាំគ្រា ហើយរមែងបែកធ្លាយ ប៉ុន្តែចំណែកសីលជាធម៌របស់សប្បុរស មិនចូលដល់ការចាស់ជរា មិនគ្រាំគ្រាដូចរូបកាយ កាលខន្ធបែកធ្លាយហើយ សីលមិនស្លាប់ឡើយ គឺនៅមានតួនាទីយ៉ាងសំខាន់ ដោយធ្វើជាអ្នកជូនដំណើរបដិសន្ធិវិញ្ញាណ ទៅកាន់សុគតិភព *(បដិសន្ធិចិត្តដោយកម្លាំង សីលជាបច្ច័យ)* មិនត្រឹមតែប៉ុណ្ណោះ សីលនៅជាប់តាមការពារវិបត្តិអន្តរាយក្នុង កំណើតនោះៗជួយរៀបចំរូបកាយឱ្យល្អ សំលេងនិយាយពីរោះ វង្សត្រកូលខ្ពង់ខ្ពស់ មានសក្តិ មានយស មានអ្នក ដទៃរាប់អាន ។ល។ ជាពិសេសណាស់ទៅទៀត សីលជា កម្លាំងជំរុញឱ្យមានស្មារតី សូម្បីកើតជាមនុស្ស ឬទេវតា ដោយសារមានសីលជាឧបនិស្ស័យ ត្រូវបានសំរេចអរិយមគ្គអង្គ៨ ដោយមានសីលនៅក្នុងនោះដែរ ដូច្នេះ សីលនាំអ្នករក្សាសីលឱ្យរីករាយនៅក្នុងភពល្អៗ រួចហើយញ៉ាំងបញ្ញាឱ្យនឿយណាយចាកភពនោះៗ នាំដំណើរទៅកាន់ទុក្ខនិរោធ ទីកន្លែងដែលអត់ជាតិ អត់ជរាមរណៈ ។

αសូមពុទ្ធបរិស័ទហ្មត់ចត់ប្រាកដឱ្យច្បាស់លាស់ ត្រឹមត្រូវនៅក្នុងសីលរបស់ខ្លួន ព្រោះរូបកាយក្តី ទ្រព្យសម្បត្តិមាសប្រាក់កែវកងក្តី មិនគប្បីបានជាទីពឹងក្នុងបរលោកឡើយ ។

αតើពុទ្ធបរិស័ទច្បាស់នៅក្នុងចិត្តហើយឬថា អាត្មាអញមានសីល៥ ជានិច្ចរាល់ថ្ងៃនេះ ហើយសីលនេះទៀតសោត ថាតើស្ថិតស្រពោន ឬក៏ស្រស់បំព្រងដែរ ។

αពុទ្ធបរិស័ទគួរហ្វឹកហាត់ចិត្តឱ្យចេះមានការគោរពដល់បុគ្គលដែលគួរគោរព ហ្វឹកហាត់ចិត្តឱ្យស្លូត ហើយចូលទៅជិតព្រះត្រៃរតន៍ ។

αពុទ្ធបរិស័ទ នៅពេលដែលធ្វើដំណើរឆ្លងកាត់ព្រះសក្យមុនីចេតិយ គួរធ្វើការគោរពយ៉ាងណាមួយដែលអាចធ្វើទៅបាន មានការសំពះតម្រង់ឆ្ពោះទៅរកជាដើម ម្យ៉ាងទៀត ទោះជាវត្តអារាមក្តី ព្រះពុទ្ធបដិមាក្តី ដែលបានជួបតាមផ្លូវជាដើម ក៏គួរដល់ការគោរព នេះគឺជាការហ្វឹក ហាត់ចិត្តឱ្យទន់ភ្លន់ សន្សំសន្តានល្អ ។

αបុគ្គលមិនគួររឹងត្អឹងប្រកាន់មានះ មិនសំពះមាតា មិនសំពះបិតា មិនសំពះលោកគ្រូអាចារ្យ មិនសំពះរៀមច្បងឡើយ ព្រោះមានះក្តី ការរឹងត្អឹងក្តី វាជាមេរោគបំផ្លាញសុខភាពរបស់ចិត្ត ។

αពុទ្ធបរិស័ទគួរមានសតិសង្រួមខ្លួនឱ្យតូច ជ្រកពួននៅក្នុងកុសលចិត្ត ផ្ទាក់ការគោរពឱនលំទោន ដោយសេចក្តីសុខស្ងប់ស្ងាត់ល្អ ។

αបើបុគ្គលខ្វះការគោរពទន់ភ្លន់ ដោយសំគាល់ថា ខ្លួនអញជាអ្នកធំ តាមពិតមិនមែនខ្លួនធំទេ ព្រោះក្នុងខន្ធ៥ ពុំមានខ្លួនឡើយ ប៉ុន្តែគឺវាធំកិលេស ដូច្នេះបុគ្គលគ្រប់រូបត្រូវចេះគោរព ឱនលំទោនដល់បុគ្គលដែលគួរគោរព ។

αការអប់រំចិត្តឱ្យមានឆន្ទះនៅក្នុងកិច្ចការងារ ដើម្បីទំនុកបំរុងអ្នកដទៃជាការល្អ ប្រការមួយទៀត ដែលកិច្ចការនោះប្រាសចាកទោស ។

αការបំរើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាការបំរើដ៏ប្រសើរខ្ពង់ខ្ពស់បំផុត ការបំរើព្រះពុទ្ធ គឺបដិបត្តិតាមឱវាទព្រះអង្គ លះបង់កិលេសក្នុងសន្តានចិត្តនៃខ្លួនឯង សំអាតព្រះពុទ្ធបដិមា ថែរក្សាព្រះចេតិយដាក់ព្រះសារីរិកធាតុ សំអាតទីវត្តអារាម និងជួសជុលទីសេនាសនៈក្នុងវត្តជាដើម ។

αបំរើព្រះធម៌ គឺសិក្សារៀនសូត្រ ព្រះបរិយត្តិធម៌ ដោយគោរពទ្រទ្រង់ចាំ និង សំដែងផ្សព្វផ្សាយដោយសេចក្តីគោរព ព្រមដោយការប្រព្រឹត្តិបដិបត្តិដោយសេចក្តីគោរព នេះជាការបំរើព្រះធម៌ គោរពព្រះធម៌ ហើយម្យ៉ាងទៀត ការទំនុកបំរុងបុគ្គលអ្នកសំដែងធម៌ ជួយខ្វល់ខ្វាយក្នុងកិច្ចការផ្សព្វផ្សាយព្រះធម៌ បោះពុម្ពសៀវភៅធម៌ ចែកផ្សាយជាធម្មទាន និមន្តព្រះធម្មកថិកឱ្យទេសនា ។ល។ ទាំង

អស់នេះសុទ្ធតែជាការបំរើព្រះធម៌ ឬបំរើព្រះពុទ្ធសាសនា ដោយការបំរើដ៏ឧត្តម ។

αបំរើព្រះសង្ឃ គឺព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះ-ភាគ បំរើគឺជួយធ្វើការក្នុងកិច្ចការងាររបស់សង្ឃ ក្នុងកិច្ចការងាររបស់ភិក្ខុសាមណេរ ដោយឧទ្ទិសខ្លួនជាអ្នកបំរើពិត១ ខ្វល់ខ្វាយដោយយកចិត្តទុកដាក់ ទំនុកបំរុងថែទាំលោកក្នុងកិច្ចការផ្សេងៗ ។

αការប្រគេនបច្ច័យ៤ ចំពោះព្រះសង្ឃតាមកាលពេលវេលាដែលលោកត្រូវការ គឺជាការគាំទ្រព្រះពុទ្ធសាសនា ព្រោះបច្ច័យ៤ សំរាប់ញ៉ាំងជីវិតរបស់បព្វជិត ឱ្យរស់នៅបាន កាលបព្វជិតមានជីវិតរស់នៅ លោកសិក្សារៀនសូត្រព្រះពុទ្ធ-វចនៈ ហើយប្រកាសផ្សព្វផ្សាយទូលំទូលាយ ។

αសូមអនុមោទនាចំពោះ បុណ្យកុសលដែលកូនប្រុសស្រីចិញ្ចឹមបីបាច់ថែទាំរក្សា និង បំរើព្រះ គឺ មាតា បិតា ។

**αបុគ្គលមកដើម្បីប្រយោជន៍ណា គួរគប្បីបំពេញធ្វើនូវប្រយោជន៍នោះ** ការបដិសន្ធិជាមនុស្ស បាននាំយកមកនូវឱបនិស្ស័យនៃបុណ្យកុសលដ៏ច្រើន ដែលអាចបំពេញធ្វើបន្ថែមបានក្នុងកំណើតជាមនុស្សបច្ចុប្បន្ននេះ គឺជាកំណើតដែលកើតមកដើម្បីប្រយោជន៍ មិនមែនដូចកំណើតសត្វក្នុងអបាយភូមិ ដែលត្រូវបិទនូវឧបនិស្ស័យនៃបុណ្យកុសល គឺពុំអាចបំពេញឱ្យសម្បូរបានក្នុងកំណើតដូច្នេះឡើយ ។ បុគ្គលគួរពិចារណាអំពីជាតិកំណើតនៅត្រង់កន្លែងដែលសំខាន់ពិសេសជាងសត្វក្នុងអបាយភូមិ គឺអាចមានស្មារតី និង ឱកាសពេលវេលាធ្វើប្រយោជន៍បាន ។ **សូមកុំឱ្យឱកាសពេលវេលានេះ កន្លងហួសទៅទទេឡើយ** គួរគប្បីបំពេញធ្វើនូវប្រយោជន៍ គឺបុណ្យកុសលគ្រប់យ៉ាងដែលអាចធ្វើបាន ដោយសេចក្តីព្យាយាម **សូមឱ្យកុសលធម៌រស់នៅជានិច្ចក្នុងសន្តានចិត្ត ដោយសារការស្រោចទឹក គឺស្តាប់នូវព្រះសទ្ធម្មជានិច្ច ជាកាល ។**

αការស្តាប់នូវព្រះធម៌ គឺជាការទូន្មានចិត្តឱ្យចេះទទួល

យកនូវបញ្ញាតាមរយៈនៃការស្តាប់ បញ្ញាជាប្រទីបធំ ជាប្រទីបពិសេសសំរាប់បំភ្លឺលោក កំចាត់នូវភាពងងឹតគឺអវិជ្ជា ដូច្នេះ ពុទ្ធបរិស័ទគួរយកចិត្តទុកដាក់ស្តាប់នូវព្រះធម៌ដោយសេចក្តីគោរព យកការស្តាប់ និង ការបដិបត្តិនូវព្រះធម៌ជាអធិបតីក្នុងជីវិត ។

αបុគ្គលក្នុងលោកនេះ សូម្បីប្រព្រឹត្តអាក្រក់មកលើយើងប៉ុណ្ណាៗក៏ដោយ ក៏មិនមែនអាចនាំយកនូវជាតិកំណើតមកប្រគល់ឱ្យយើងបានឡើយ ប៉ុន្តែខ្លួនយើងដែលល្ងង់មានអវិជ្ជានេះឯង ដែលតែងតែនាំយកនូវជាតិទុក្ខមកសំរាប់ឱ្យខ្លួនឯង ប្រគល់ឱ្យខ្លួនឯង ដូច្នេះខ្លួនឯងដែលល្ងង់មានអវិជ្ជាហ្នឹងឯង ដែលជាកំពូលសត្រូវរបស់ខ្លួនឯង នាំមកនូវទុក្ខសព្វគ្រប់ប្រការ កាលដែលមានជាតិកំណើតហើយនោះ ។

αត្រូវទូន្មានចិត្តឱ្យតាំងនៅក្នុងការស្តាប់ព្រះធម៌ដោយគោរព ត្រូវចាំជានិច្ចថា ទាល់តែមានព្រះសម្មាសម្ពុទ្ធបានត្រាស់ទើបមាននូវព្រះធម៌ ដូច្នេះព្រះធម៌ជារបស់ក្រហៅពេញសែនក្រ ប៉ុន្តែនេះគឺជាភ័ព្វសំណាងណាស់ ដែលបុគ្គលមានសទ្ធា ទទួលយករស្មីនៃព្រះធម៌ក្នុងសម័យកាលនេះ ។

αភ្លៀងមាសភ្លៀងប្រាក់ធ្លាក់គរលើផែនដី មិនស្មើនឹងការសំដែងព្រះធម៌របស់ព្រះអរិយឡើយ ភ្លៀងព្រះធម៌ទើបបុគ្គលអាចសាបព្រោះពូជសទ្ធា ធ្វើស្រែដែលមាន **អមតៈ** ជាផលបាន ។

α ការសំដែងព្រះធម៌ គឺជាការប្រដៅចិត្តមួយផ្នែកទៀតយ៉ាងសំខាន់ ព្រោះអាចប្រគល់ឱ្យនូវការចេះការដឹងដល់អ្នកដទៃ ទាំងការចេះការដឹងនេះជារបស់មានតម្លៃកាត់ថ្លៃពុំបាន ដូច្នេះអ្នកសំដែងធម៌ក៏មិនត្រូវតាំងចេតនាលក់ព្រះធម៌ឡើយ ប៉ុន្តែត្រូវតាំងចេតនាដោយមេត្តាពិតៗ ដើម្បីឱ្យអ្នកស្តាប់បាននូវប្រយោជន៍ បាននូវព្រះធម៌ជាមរតក ។

αការសំដែងព្រះធម៌ គឺឱ្យទានដ៏ប្រសើរខ្ពង់ខ្ពស់ ព្រោះជាការឱ្យនូវកុសលធម៌ដល់អ្នកស្តាប់ អ្នកស្តាប់ធម៌ បានបុណ្យចំរើនកុសលព្រោះជ្រះថ្លានឹងព្រះធម៌ ដោយជំនឿដ៏ត្រឹមត្រូវក្នុងព្រះធម៌ថា អាចដឹកនាំសត្វលោកឱ្យរួចផុតចាកទុក្ខបាន ហើយធ្វើឱ្យអ្នកស្តាប់ធម៌រលឹកឃើញព្រះគុណនៃព្រះ-

សម្មាសម្ពុទ្ធរឿយៗទៀតផង ។

αអ្នកស្តាប់ធម៌ រមែងមានការយល់ដឹងយ៉ាងត្រឹមត្រូវចំពោះព្រះសង្ឃសាវ័ករបស់ព្រះដ៏មានព្រះភាគ រួចហើយក៏មានការរលឹកដល់គុណព្រះសង្ឃ ។

αអ្នកសំដែងធម៌ រមែងបាននូវការទូន្មានខ្លួនឯង រួមផ្សំជាមួយនឹងការទូន្មានអ្នកដទៃ ពាក្យសំដីមានតម្លៃ ឬគ្មានតម្លៃ អាស្រ័យការប្រព្រឹត្តិបដិបត្តិរបស់អ្នកនិយាយផងដែរ ។

❋ ការសំដែងធម៌ និងការស្តាប់ធម៌ដោយគោរព នាំឱ្យបាននូវសមាធិដ៏ប្រសើរ ហើយសមាធិនេះអាចធ្វើឧបការៈដល់បញ្ញាត្រាស់ដឹងអរិយសច្ចធម៌បានទៀតផង មនុស្ស ទេវតា ព្រះឥន្ទ្រ ព្រះព្រហ្ម បានឃើញព្រះនិព្វាន ដោយការស្តាប់ព្រះធម៌មានចំនួនច្រើនជាអនេក ។

❋ ការចំរើនសេចក្តីស្ងប់ចិត្ត គឺជាការចំរើនកុសល បានដល់ការទូន្មានចិត្តឱ្យនៅក្នុងសេចក្តីសុខស្ងប់រឿយៗ ។

❋ មិនគិតដោយអកុសលវិតក្កៈ គឺមិនគិតក្នុងកាម មិនគិតក្នុងការព្យាបាទ មិនគិតក្នុងការបៀតបៀន ប៉ុន្តែមានការគិតជាកុសលមកជំនួស ។

αការស្តាប់ធម៌ ការមើលសៀវភៅធម៌ ការសំដែងធម៌ សុខកាយសប្បាយចិត្តក្នុងកុសលធម៌ ចិត្តស្ងប់ត្រជាក់ព្រោះមិនបានគិតជាអកុសល ។

αត្រូវប្រដៅចិត្តដោយស្មារតីម៉ឺងម៉ាត់ កុំឱ្យចិត្តនៅកណ្តាលវាលក្រោមកំដៅកិលេស ព្រោះកំដៅកិលេសវាក្តៅខ្លាំងណាស់ គឺត្រូវឱ្យចិត្តជ្រកនៅក្រោមម្លប់នៃព្រះសទ្ធម្ម ទើបចិត្តមិនក្តៅដោយកំដៅនៃកិលេស ។

❋ គួរតែអាស្រ័យនូវព្រះសទ្ធម្មជាយាន ដើម្បីចេញចាកអំពីរឿងរ៉ាវក្នុងលោកនេះ និង លោកដទៃ ព្រោះរឿងរ៉ាវក្នុងលោក វានាំឱ្យតែចិត្តសៅហ្មងដោយប្រការផ្សេងៗ ដូច្នេះត្រូវប្រគល់ឱ្យវិញ្ញាណត្រឹមតែដឹងទៅចុះ ព្រះគុណម្ចាស់ញាតិញោមឡើងកាន់យានព្រះសទ្ធម្ម ចេញចាកអំពីអារម្មណ៍ក្នុងលោក ។

❋ ត្រូវមានសតិជាសារថីទូន្មានចិត្ត ឱ្យចិត្តចេញចាកអំពីអារម្មណ៍ដែលមិននាំឱ្យស្ងប់ ហើយចងចិត្តឱ្យតាំងនៅក្នុង

អារម្មណ៍ណាដែលនាំឱ្យចិត្តស្ងប់ ។

αសូម្បីចិត្តស្ងប់ក៏ជាសង្ខតធម៌ ត្រូវបានតាក់តែងដោយហេតុបច្ច័យ មិនគប្បីយល់ចូលចិត្តដោយសេចក្តីប្រកាន់ថាតួខ្លួន អាត្មាអញជាអ្នកសាងធ្វើឱ្យបានសម្រេចនូវចិត្តស្ងប់នេះឡើយ ហើយត្រូវតែប្រច័ក្សឱ្យច្បាស់ថា ចិត្តស្ងប់គ្រប់ពេលពុំដែលមានម្ចាស់ជាសត្វបុគ្គលណាទាំងអស់ ។

✵ គេតែងគិតយល់ថា ខ្ញុំករុណាខ្ញុំបាទសំដែងធម៌មិនឱ្យគេធ្វើសមថកម្មដ្ឋាន មិនឱ្យធ្វើសមាធិ មិនឱ្យអង្គុយភាវនាឬដើរចង្រ្កមទេ ខ្ញុំព្រះករុណាខ្ញុំបាទ ពុំដែលមានពេលណាពោលហាមការចំរើនកុសលធម៌គ្រប់យ៉ាងឡើយ ប៉ុន្តែដោយសារមានការសំដែងក្នុងកិច្ចបដិបត្តិសតិប្បដ្ឋាន ជាពាក្យមានជំរៅជ្រៅ អ្នកស្តាប់ខ្លះយល់មិនដល់ ក៏ទៅជាយល់ខុសចាកខ្លឹមសារនៃព្រះធម៌ ។

✵ សតិជាគ្រឿងហាម ជាគ្រឿងបិទនូវខ្សែតណ្ហា សតិគឺការរលឹក ការសិក្សានូវសភាវធម៌ដែលកំពុងប្រាកដ ការចំរើនសតិប្បដ្ឋានមិនមែនហាមកុសលថ្នាក់សមថៈ ឬ ហាមឥរិយាបថណាមួយទេ តែជាការលះបង់នូវសេចក្តីប្រកាន់ថាតួខ្លួនជាអ្នកធ្វើកុសលធម៌ឱ្យកើតឡើង ព្រោះបានដឹងថាសង្ខតធម៌គ្រប់យ៉ាងកើតឡើង អាស្រ័យបច្ច័យយ៉ាងគ្រប់គ្រាន់ សូន្យចាកសត្វបុគ្គលក្នុងបច្ច័យនោះៗ ។

✵ បើវិញ្ញាណក្ខន្ធក៏ជាអនត្តា តើខំប្រឹងធ្វើចិត្តឱ្យស្ងប់ដើម្បីអ្នកណា ព្រោះថា សូម្បីចិត្តមិនស្ងប់ក៏មិនមែនជារបស់យើងដែរ ពាក្យនេះមិនមែនហាមការចំរើនកុសលថ្នាក់សមថៈទេ ព្រោះកុសលថ្នាក់សមថៈ ត្រូវបានចំរើនច្រើនឡើងៗដោយមានហេតុបច្ច័យនៃកុសលនោះៗ ប៉ុន្តែគឺជាពាក្យរំលឹកដាស់ស្មារតីឱ្យមានសតិរលឹកដឹងនូវចិត្ត ដែលកំពុងប្រាកដទោះជាចិត្តអ្វីក៏ដោយ គឺជាការចំរើនវិបស្សនាវិជ្ជាលះបង់នូវអវិជ្ជា តណ្ហា ឧបាទាន និង អភិ សង្ខារ គឺកម្ម ។

✵ ការដឹងរឿងរ៉ាវក្នុងលោក ដោយសារមានវិថីចិត្តកើតឡើង បើមិនរលឹករឿយៗ សិក្សាសង្កេតពិនិត្យរឿយៗទេ តើធ្វើម៉េចនឹងអាចជាក់ច្បាស់បានថា ត្រឹមតែចិត្តឃើញរូប ត្រឹមតែចិត្តឮសំលេង ត្រឹមតែចិត្តប៉ុណ្ណោះ ដែលដឹងនូវ

អារម្មណ៍ផ្សេងៗ រួចហើយចិត្តនោះក៏រមែងរលត់ទៅវិញ បើមិនបានដាក់ច្បាស់ថា ត្រឹមតែចិត្តដែលដឹងអារម្មណ៍ទេនោះ តើធ្វើដូចម្តេចអាចចេញផុតចាកលោកបាន ។

αមនុស្សយើងតែងធ្វើនូវអំពើអ្វីៗភ្លេចហេតុ ព្រោះលុះតាមអំណាចតណ្ហា ព្រះភិក្ខុអស្សជិបានសម្តែងប្រាប់ឧបតិស្សៈ គឺព្រះសារីបុត្រថា **ធម៌ទាំងឡាយណាកើតឡើងព្រោះហេតុ ព្រះតថាគតទ្រង់ត្រាស់សំដែងនូវហេតុនោះ** នេះជាពាក្យដាស់តឿនឱ្យមានសតិហាមរាំងនូវតណ្ហា គឺជាពាក្យហៅឱ្យមកមើលធម៌ពិតៗក្នុងជីវិតរាល់ថ្ងៃ បានដល់ធម៌ដែលកើតអំពីហេតុ កាលមានសតិរលឹក ក៏ជាការចំរើនមគ្គប្រកបដោយអង្គមគ្គ ជាលោកុត្តរ គឺជាផ្លូវដ៏ប្រសើរ នាំព្រះសារីបុត្រទៅកាន់ទីរំលត់ទុក្ខ **តាមដែលព្រះមហាសមណៈទ្រង់ត្រាស់សំដែង អំពីនិរោធ គឺព្រះនិព្វាននោះឯង ។**

α ព្រះសារីបុត្របានរកឃើញទីកន្លែងដែលមិនមានស្លាប់ ដោយសារបានត្រាស់ដឹងនូវធម៌ដែលកើតមានព្រោះហេតុហ្នឹងឯង បើគ្រាន់តែបានស្តាប់ឮថា ធម៌ទាំងឡាយកើតមានព្រោះហេតុ ប៉ុន្តែមិនមានសតិរលឹកដឹងនូវធម៌នោះទេ ក៏មិនមានផ្លូវដើរចេញអំពីទុក្ខបានឡើយ ពីព្រោះមិនមានអ្វីរំលត់នូវសក្កាយទិដ្ឋិ ។

**αសក្កាយទិដ្ឋិគឺប្រកាន់ថា ធម៌ទាំងឡាយ តួខ្លួនជាអ្នកធ្វើឱ្យកើតឡើង ទាំងប្រកាន់នូវធម៌ដែលកើតឡើងនោះថា ជាខ្លួនឬជារបស់ខ្លួន ។**

αបើបុរសនោះមិនកាន់យកនូវទ្រព្យសម្បត្តិរបស់អ្នកដទៃទេ ក៏ព្រះរាជាមិនបានដាក់ទោសឱ្យគេធ្វើទារុណកម្ម ឬក៏សម្លាប់ចោលដែរ ប៉ុន្តែដោយសារបុរសនោះជាចោរ ពិតមែនទើបត្រូវសម្លាប់ ឬត្រូវទទួលនូវទារុណកម្មដោយប្រការផ្សេងៗ យ៉ាងណាមិញ ព្រោះអវិជ្ជាមិនដឹងសង្ខតធម៌តាមពិត មិនដឹងថា ការកើតឡើងនៃធម៌ទាំងឡាយ សុទ្ធតែមាន**ហេតុ**

មានបច្ច័យ ដែលហេតុបច្ច័យនោះ មិនមែនជាសត្វបុគ្គលតួខ្លួនឡើយ ការមិនដឹងគឺអវិជ្ជានេះ នាំឱ្យមានសេចក្ដីប្រកាន់មាំនូវធម៌ទាំងឡាយដែលកើតអំពីហេតុ នោះថាជារបស់យើង សេចក្ដីនេះឯងដែលឧបមាប្រៀបបីដូចជាចោរ ដែលកាន់យកនូវទ្រព្យសម្បត្តិរបស់អ្នកដទៃ កាលដែលមានឧបាទានប្រកាន់មាំហើយ អភិសង្ខារគឺកម្មក៏មានដែរ **កម្ម** ប្រៀបបីដូចព្រះរាជាដែលដាក់អាជ្ញាឱ្យសម្លាប់ចោរ ឬធ្វើទារុណកម្មដល់ចោរ ព្រោះថា បើ **កម្ម** មានហើយ ជាតិជរាមរណៈ សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល ទុក្ខទោមនស្ស និង សេចក្ដីចង្អៀតចង្អល់ក៏មានដែរ ។

α រូប , វេទនា , សញ្ញា , សង្ខារ , វិញ្ញាណ , ជីវិតក្ដី , អត្តភាពក្ដី , សុខទុក្ខក្ដី ប្រៀបបីដូចទ្រព្យសម្បត្តិរបស់អ្នកដទៃ បុគ្គលឃើញដោយបញ្ញាដ៏ប្រពៃក៏មិនបានប្រកាន់ដោយតណ្ហាថា ជារបស់យើងឡើយ ជាអ្នកមានភារៈធ្ងន់ដាក់ចុះហើយក៏ទៅកាន់ទីដ៏ក្សេមក្សាន្ត ។

αបុគ្គលខ្លះពោលថា ធម៌ដែលខ្ញុំព្រះករុណាខ្ញុំបាទសំដែង អត់មានអង្គុយធ្វើសមាធិទេ ចំណែកធម៌លោកគ្រូខ្ញុំលោកដាក់ឱ្យធ្វើសមាធិកម្មដ្ឋាន តាមពិតខ្ញុំករុណាខ្ញុំបាទសំដែងធម៌បដិបត្តិសតិប្បដ្ឋាន គឺបញ្ជាក់លក្ខណៈនៃការមានសតិ ជាធម៌បដិបត្តិដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែង **បើសតិមិនមានការរលឹកដឹងជាលក្ខណៈទេនោះ តើមានលក្ខណៈដូចម្ដេចទៅវិញ ?**ម្យ៉ាងទៀត **បើមិនរលឹកដឹងសភាវធម៌ដែលកំពុងប្រាកដទេនោះ តើចំរើនសតិដោយវិធីដូចម្ដេចទៅវិញ ?** សតិថ្នាក់សតិប្បដ្ឋាន មិនមែនសមាធិកម្មដ្ឋាន មិនមែនមានរបៀបបង្កើតនូវអារម្មណ៍សំរាប់រលឹក មិនជ្រើសរើសអារម្មណ៍សំរាប់រលឹក តែសតិរលឹកដឹងនូវសភាវធម៌កំពុងប្រាកដ ទោះបីជា **មហគ្គត ធម៌ ឬ កាមាវចរធម៌** ក៏ដោយ ។

**αការសិក្សារៀនសូត្រនៅក្នុងគម្ពីរមហា–**

**សតិប្បដ្ឋានសូត្រ បើមិនសិក្សាដោយល្អទេ នោះ រមែងយល់ច្រឡំអារម្មណ៍របស់សតិដែល ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងច្រើនប្រការ ជាពួកៗរហូតគ្រប់បរមត្ថធម៌ទាំង៤ នោះថា ជាសតិដែលត្រូវចំរើនទៅវិញ ព្រោះការ យល់ច្រឡំយ៉ាងនេះ ទើបបានជាតាំងតួខ្លួនធ្វើ ធម៌យ៉ាងនេះ ធ្វើធម៌យ៉ាងនោះ ដោយយល់ ថា ចំរើនវិបស្សនា ។** ខ្ញុំករុណាខ្ញុំបាទ មិនបានពោល ហាមការចំរើនកុសលថ្នាក់សមថៈឡើយ តែបានពោលថា **មិនមែនទាល់តែធ្វើសមាធិ ឬសមថៈកម្មដ្ឋាន ឱ្យកើតសិន សុំចំរើនវិបស្សនានោះទេ ព្រោះ សភាវធម៌ដែលសតិត្រូវរលឹកដឹង កំពុង ប្រាកដតាមទ្វារទាំង៦ ទ្វារណាមួយកើតឡើង ព្រោះហេតុបច្ច័យ ។**

αការចំរើនសតិប្បដ្ឋាន **គឺផ្ដើមដោយការមាន សតិ ហើយក៏ជាការផ្ដើមលះបង់សេចក្ដីប្រកាន់តួខ្លួនផងដែរ** សតិរលឹកដឹងនូវសភាវធម៌ដែលកើត ព្រោះហេតុបច្ច័យជាប្រក្រតីក្នុងជីវិតប្រចាំថ្ងៃ ពុទ្ធបរិស័ទ ចំរើនភាវនា **ធ្វើសមាធិកម្មដ្ឋាន** ឱ្យតែច្បាស់ដោយ សតិសម្បជញ្ញៈថ្នាក់កុសលនោះៗ ហើយដឹងថា ជាកុសល ថ្នាក់ស្ងប់ គឺស្ងប់ជាងទាន ស្ងប់ជាងសីល នេះគឺជាប្រក្រតី នៃការធ្វើកុសលកម្ម ដូចការធ្វើទាន ការរក្សាសីល សីល៥ ឬ សីល៨ជាដើម គ្រាន់តែថា ពុទ្ធបរិស័ទ្ធមានឧបនិស្ស័យក្នុងការ ចំរើនកុសលថ្នាក់ភាវនាថែមបន្តទៅទៀត ខ្ពស់ជាងទានសីល តែប៉ុណ្ណោះ មានអ្នកណាហាមមិនឱ្យចំរើនសេចក្ដីស្ងប់ បើ ហាមមិនឱ្យចំរើនសេចក្ដីស្ងប់ ក៏គួរតែហាមការធ្វើទាន ការ រក្សាសីលផងដែរ ព្រោះពួកធម៌ជាកុសលដូចគ្នា ប៉ុន្តែបើ យល់ថា ទាល់តែធ្វើសមាធិចិត្តឱ្យស្ងប់សិនទើបអាចលើក វិបស្សនាពិចារណាត្រៃលក្ខណ៍ព្រោះ **សមាធិជាបទដ្ឋាន ជាបាទរបស់បញ្ញា** ការយល់នេះខុសហើយ ពិតមែនតែ

សមាធិជាបាទរបស់បញ្ញា តែបើមិនមានប្រក្រតីអប់រំរឿយៗនូវសតិរលឹកដឹងរូបធម៌ និង នាមធម៌តាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្ដាត ផ្លូវកាយ ផ្លូវចិត្តទេនោះ សូម្បីបានរូបជ្ឈាន ឬ អរូបជ្ឈានក៏ដោយ ក៏មិនអាចជាបាទនៃបញ្ញាវិបស្សនាបានដែរ ផ្ទុយមកវិញ ឱ្យតែស្ដាប់ព្រះធម៌យល់ផ្ដើមមានសតិរលឹកដឹងនូវសភាវធម៌តាមទ្វារទាំង៦ មិនចំពោះថា ពួកធម៌ជាកុសល ឬពួកធម៌ជាអកុសល ឬពួកធម៌ជាអព្យាកត ក៏ឃើញថា ជាធម៌ដែលកើតព្រោះហេតុ ទោះជាមិនមានកុសលថ្នាក់សមថកម្មដ្ឋានក៏ដោយ ក៏ខណិកសមាធិក្នុងខណៈមានសតិនោះជាបាទរបស់វិបស្សនាដែរ សេចក្ដីនេះសូមជ្រាបថា សូម្បីក្នុងខណៈមគ្គជាលោកុត្តរក៏មានសមាធិជាខណិកសមាធិត្រឹមតែមួយខណៈប៉ុណ្ណោះ អាចសំរេចការលះបង់កិលេសដាច់ជាសមុច្ឆេទបាន ដោយមិនចាំបាច់មានសមាធិថ្នាក់សមថកម្មដ្ឋានជាបាទឡើយ ។

**αកុសលធម៌គ្រប់យ៉ាងជាឧបការៈ ឬជាបទដ្ឋានរបស់វិបស្សនា លុះត្រាតែមានប្រក្រតីនៃសតិរលឹកដឹងសភាវធម៌នូវនៅ ដែលកើតព្រោះហេតុបច្ច័យក្នុងជីវិតប្រចាំថ្ងៃ ៗ**

αបើមិនមានប្រក្រតីចំរើនសតិរលឹករឿយៗទេនោះទិដ្ឋិរមែងប្រកាន់នូវកុសលធម៌ថា ខ្លួនជាអ្នកធ្វើឱ្យកើតឡើង ហើយប្រកាន់នូវកុសលធម៌នោះថា ជារបស់ខ្លួន ដូច្នេះជំនួសវិបស្សនាដែលត្រូវមានសមាធិជាបាទនោះ គឺ ទិដ្ឋិ ឬមានៈ ឬតណ្ហាទៅវិញទេ ។

αបុគ្គលខ្លះពោលថា ទោះជាធ្វើអ្វីក៏ដោយ ក៏ត្រូវតែមានរបៀបធ្វើ និង វិធីហ្វឹកហាត់សិនដែរ លុះដល់ចេះស្ទាត់ហើយទើបបញ្ឈប់ការហ្វឹកហាត់ ប្រៀបបីដូចគេរៀនបើកឡានមុនដំបូង ត្រូវទៅរកទីស្ងាត់មនុស្ស ឬទីវាលស្រឡះ សិនដល់រៀនចេះហើយគេអាចបើកក្នុងទីក្រុងក៏បាន យ៉ាងណាមិញ ការហ្វឹកហាត់អបរំសតិមុនដំបូង ត្រូវរកទីកន្លែងស្ងាត់ទីកន្លែងផុតចាកភាពអ៊ូអរ លុះចេះស្ទាត់ហើយ ទើបអាចមករស់នៅជាប្រក្រតីធម្មតា អាចប្រើសតិបានគ្រប់ពេលវេលា ។

α **ដំណោះស្រាយ** អំពីការបើកឡាន មិនចំពោះ

ថា ពេលដែលកំពុងរៀនបើក ឬចេះស្ទាត់ហើយទេ គឺវាត្រូវតែមានទីកន្លែង ឬ ផ្លូវសំរាប់បើកឡានបានយ៉ាងណា ចំពោះសតិប្បដ្ឋានក៏យ៉ាងនោះដែរ មិនចំពោះថា នៅក្នុងព្រៃ ឬ ផ្ទះស្ងាត់គល់ឈើ ឬក៏នៅក្នុងចំណោមមនុស្សរាប់រយពាន់នាក់ឡើយ គឺសតិរលឹកអារម្មណ៍ជាបរមត្ថ មិនមែនមនុស្សសត្វ មិនមែនព្រៃភ្នំ មិនមែនភូមិស្រុកឡើយ ទីកន្លែងរបស់សតិបានដល់អារម្មណ៍ណាដែលសតិរលឹកបាន ពួកកាយ ពួកវេទនា ពួកចិត្ត ពួកធម៌ ដូច្នេះតើគួរស្វែងរកទីកន្លែងសំរាប់ហ្វឹកហាត់សតិដែរឬទេ ?

**α លោកនៃបញ្ញត្តិគ្រប់ទីកន្លែងទាំងអស់ មិនមែនជាកន្លែងរបស់សតិថ្នាក់សតិប្បដ្ឋានឡើយ ។**

**α លោកក្នុងអរិយវិន័យជាលោកបរមត្ថៈ គ្រប់លោកទាំងអស់ សុទ្ធតែជាកន្លែងនៃការមានសតិថ្នាក់សតិប្បដ្ឋាន ការជ្រើសរើសលោកសំរាប់ហ្វឹកហាត់សតិ ពុំមែនវិធីសំរាប់ចំរើនសតិទេ គឺវាជាសត្តាយទិដ្ឋិ ។**

αបើត្រូវការដូរទីកន្លែងរស់នៅ ដើម្បីកុសលធម៌សំរាប់ទំនុកបំរុងសតិប្បដ្ឋាន គឺដូរបានហើយក៏ត្រូវតែដូរផងដែរបើនាំឱ្យកុសលធម៌ចំរើនព្រោះអ្វី ? ព្រោះកុសលធម៌ទាំងនេះ មានបញ្ញត្តិជាអារម្មណ៍ ។

**៤-អសទ្ធា ធម្មា**

បានដល់ព្រះនិព្វាន ដែលមិនមានការប្រជុំតាក់តែង

៱គំនរភ្នក់ភ្លើងជាធម្មជាតិតែងតែក្តៅ បុគ្គលដែលនៅក្នុងគំនរភ្នក់ភ្លើង ឬ នៅក្នុងផ្ទះដែលត្រូវភ្លើងឆេះ មិនគួរគប្បីអង្វរភ្លើង ឬគិតចង់ឱ្យភ្លើងត្រជាក់នោះទេ តែមធ្យោបាយមានតែម្យ៉ាងគត់គឺ រត់លោតចេញអំពីភ្លើង យ៉ាងណាមិញ រូបក្តី នាមធម៌ក្តី ឬក៏បានដល់ភពជាតិកំណើតនេះឯងហើយ ដែលជាគំនរភ្នក់ភ្លើងមានកំដៅដ៏ខ្លាំងក្លា យើងដាច់ខាតមិនត្រូវបន្ទោសភ្លើងថា ម៉េចក៏វាក្តៅម្ល៉េះ ម៉េចក៏វាមិនត្រជាក់ ប៉ុន្តែព្រោះសេចក្តីល្ងង់គឺ អវិជ្ជារបស់ ខ្លួនឯងទេតើ ដែលនាំឱ្យខ្លួនឯងដើរចូលភ្លើង គឺភពជាតិកំណើត ដូច្នេះរឿងសំខាន់គឺត្រូវចេញយ៉ាងប្រញាប់ប្រញាល់អំពីភ្នក់ភ្លើង មិនត្រូវរករឿងឈ្លោះស្តីបន្ទោសភ្លើងឡើយ គ្រាន់តែកំណត់ដឹងឱ្យបានច្បាស់លាស់ថា ធម្មតាភ្លើងវាត្រូវតែក្តៅ ។

៱រូបកាយតែងតែគ្រាំគ្រា ជាសំបុកនៃរោគ មានរូបមាន រោគ មានភ្លើង មានក្តៅ ពាក្យនេះសុទ្ធតែធ្លាប់ដឹងគ្រប់ៗ ប៉ុន្តែចំណុចខ្វះខាតរបស់សត្វលោក គឺមិនចង់ឱ្យរូបកាយរបស់ខ្លួនមានជម្ងឺ មិនចង់ឱ្យមានរោគអ្វីណាមួយឡើយ បើកាលណាឈឺអ្វីម្យ៉ាងៗហើយ តែងតែភ័យព្រួយ មុខក្រៀមក្រំ មានការតក់ស្លុត មានសេចក្តីសោក មិនចង់ឱ្យមានរោគធ្លាក់មកដល់ខ្លួន ឬក៏ញាតិមិត្ត ណាមួយឡើយ ។

៱**ត្រូវអាស្រ័យនូវព្រះសទ្ធម្ម ដើម្បីចេញពីភពជាតិ ឬដើម្បីចេញអំពីរូបដែលជាសំបុកនៃរោគ** ការចេញអំពីរូបកាយដោយព្រះសទ្ធម្ម គឺការលះបង់ នូវទិដ្ឋិមានះតណ្ហាក្នុងកាយ ដោយមិនប្រកាន់ថារូបកាយ ជាខ្លួន ជាសត្វ ជាបុគ្គល ហើយក៏មិនប្រកាន់ថាជាខ្លួនអញ ជាសត្វបុគ្គលនៅក្នុងរូបកាយឡើយ ។

៱**ត្រូវអាស្រ័យនូវព្រះសទ្ធម្ម ដើម្បីចេញអំពីរឿងរ៉ាវនៅក្នុងលោក** អារម្មណ៍តាមទ្វារទាំង៦ គឺជាអារម្មណ៍របស់វិញ្ញាណ ការចេញអំពីរឿងរ៉ាវនៅក្នុងលោកនេះបាន លុះត្រាតែមានសតិប្បដ្ឋានបដិបត្តិ ប្រគល់

អារម្មណ៍ឱ្យវិញ្ញាណ ហើយមិនប្រកាន់នូវវិញ្ញាណថា ជាសត្វបុគ្គលតួខ្លួន មានបញ្ញាឃើញវិញ្ញាណពិតជាវិញ្ញាណ ដោយលះបង់តណ្ហាមានះទិដ្ឋិក្នុងវិញ្ញាណនោះៗ រកសត្វជាអ្នកដឹងអារម្មណ៍ពុំមានឡើយ ។

៙**ខ្លួនឯងជាទីពឹងនៃខ្លួនឯង** បើខ្លួនយើងធ្វើខុសហើយ ប្រមាទហើយ វង្វេងភ្លេចសតិហើយ បណ្តោយតាមកិលេសហើយ អ្នកដទៃមិនអាចជួយ មិនអាចជាទីពឹងឱ្យយើងបានឡើយ ដូច្នេះដើម្បីឱ្យខ្លួនយើងអាចជាទីពឹងនៃខ្លួនឯងបាន គឺខ្លួនយើងត្រូវតែមានការគ្រប់គ្រងដោយសតិ ត្រូវតែស្អាតល្អដោយកុសលធម៌ និង បរិសុទ្ធដោយបញ្ញា ។

៙បុគ្គលល្ងង់ខ្លៅមានខ្លួនឯងជាសត្រូវ បុគ្គលស្អាតដោយបញ្ញា មានខ្លួនឯងជាទីពឹង ដូច្នេះបុគ្គលត្រូវមានធម៌ជាទីពឹងដើម្បីឱ្យខ្លួនបានស្អាតបរិសុទ្ធ កាលខ្លួនបានស្អាតបរិសុទ្ធហើយ ទើបបានជាទីពឹងនៃខ្លួនឯង ។

៙មិនចាំបាច់អង្វរអ្នកដទៃឱ្យជួយខ្លួនយើងឡើយ បើយើងមានខ្លួនឯងជាទីពឹងហើយនោះ ។

៙អ្នកដែលអង្វរគេព្រោះមានចំណុចខ្សោយ ចំណុចខ្សោយរបស់មនុស្សគ្រប់គ្នា នៅត្រង់ការស្រឡាញ់ខ្លួនឯង បុគ្គលដែលស្រឡាញ់ខ្លួនឯង គឺមិនអាចមានខ្លួនឯងជាទីពឹងបានឡើយ ។

៙បើមិនឱ្យស្រឡាញ់ខ្លួនឯង តើឱ្យស្រឡាញ់អ្នកណាទៅវិញ ?

ការស្រឡាញ់អ្វីៗនៅក្នុងលោក មិនមានអ្នកណាបង្គាប់ឱ្យឡើយ ដូចជាការស្រឡាញ់ខ្លួនឯងនេះក៏មិនអាចឈប់ស្រឡាញ់បានដោយងាយៗដែរ វាមិនមែននៅលើខ្លួនឯងចង់ស្រឡាញ់ក៏ស្រឡាញ់ទៅ ចង់ឈប់ស្រឡាញ់ពេលណាក៏ឈប់ទៅនោះឯណា ព្រោះថា ការស្រឡាញ់ខ្លួនឯងនេះកើតមកអំពីអវិជ្ជា ដែលមិនដឹងថា ខ្លួនឯងគឺជាបញ្ចក្ខន្ធ ជាមារ ជាឫសគល់នៃសេចក្តីលំបាក ជាប្រភពនៃបញ្ហាគ្រប់យ៉ាង ។

៙នៅក្នុង **ទានកថា** ការសំដែងអំពី **ទាន** **សីលកថា** ការសំដែងអំពី **សីល** គឺដើម្បីឱ្យអ្នកស្តាប់បាន

ដឹងអំពីគុណតម្លៃនៃសេចក្តីល្អ ចេះខ្មាស់ខ្លើមបាប ងើបចេញអំពីបាប លះបង់ចោលនូវបាប ប្រៀបបីដូចបុគ្គលដែលមិនស្គាល់ដុំមាស កាលដែលមានអ្នកដទៃនិយាយប្រាប់អំពីតម្លៃនៃដុំមាស ក៏លះបង់ចោលនូវដុំដី និង ដុំថ្ម ព្រមជាមួយគំនរលាមក ហើយចាប់រើសយកនូវដុំមាស សន្សំដុំមាសរហូតដល់បានជាសេដ្ឋី ព្រោះអាស្រ័យរើសយករបស់ដែលមានតម្លៃពិតៗក្នុងលោក ។

αកូនប្រុសស្រីដែលមិនដឹងគុណរបស់មាតាបិតា កាលដែលមានអ្នកសប្បុរសនិយាយពន្យល់ប្រាប់អំពីគុណ គឺសេចក្តីល្អសព្វគ្រប់ប្រការរបស់មាតាបិតាហើយ បុត្រធីតាបានដឹងគុណតាមពិត ក៏លះបង់ចោលនូវការលុបបំបាត់គុណ ការរមិលគុណ ហើយក៏កាន់យកនូវការដឹងគុណ បានតបស្នងសងគុណចំពោះមាតាបិតាដោយកុសលចេតនាតាមពិត យ៉ាងណាមិញ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សំដែង បើកបង្ហាញឱ្យសត្វលោកបានដឹងបានយល់អំពីគុណតម្លៃនៃកុសលធម៌ ហើយមានការប្រព្រឹត្តិលះបង់ចោលនូវបាប អកុសលទាំងឡាយផ្សេងៗឆ្ពោះទៅរកភាពដ៏ប្រសើរ ។

αទោះបីកុសលធម៌ទាំងឡាយល្អ មានគុណតម្លៃថ្លៃយ៉ាងណាៗក៏ដោយក៏នៅតែជា **សង្ខតធម៌** មិនទៀង ជាសភាវធម៌ដែលមានការកើតជាធម្មតា ជាធម៌ដែលមានបច្ច័យតាក់តែងឱ្យកើតឡើង មិនមែនជាសន្តិបទ ។

αសង្ខារធម៌ទាំងឡាយ សុទ្ធតែមានលក្ខណៈមិនស្ងប់ដោយសាមញ្ញលក្ខណៈ សូម្បីតែកុសលធម៌ក៏ត្រូវលះបង់ដែរ ចាំបាច់និយាយថ្វីចំពោះអកុសលធម៌ ការលះបង់នូវកុសលធម៌ គឺលះបង់នូវឆន្ទរាគ សេចក្តីត្រេកអរ ការប្រកាន់ក្នុងកុសលធម៌ហ្នឹងឯង **គប្បីរក្សានូវជ័យជំនះដែលបានឈ្នះហើយ ទាំងមិនគប្បីជំពាក់នៅឡើយ** កុសលធម៌ជាធម៌ឈ្នះអកុសល ដូច្នេះត្រូវតែជាបុគ្គលមិនត្រឡប់ចាញ់វិញ ប៉ុន្តែសូម្បីកុសលធម៌ក៏នៅតែចាញ់អនិច្ចតាធម៌ ទើបមិនត្រូវជំពាក់នៅក្នុងកុសលធម៌ ពោលគឺការរំលត់សេចក្តីប្រកាន់មាំក្នុងកុសលធម៌ ឃើញនូវកុសលធម៌គ្រាន់តែជាសង្ខតធម៌មួយបែបតែប៉ុណ្ណោះ ពុំមែនជាព្រះនិព្វានឡើយ ។

៙ដែលឈ្មោះថា **ធម្មជាតិ** គឺអ្វី១ដែលមានការកើតជាធម្មតា ជាសង្ខតធម៌ គឺធម៌ដែលកើតឡើងត្រឹមត្រូវទៅតាមហេតុបច្ច័យ **ធម្មជាតិ** ជាធម៌ត្រឹមត្រូវបំផុត កាលកើតឡើងមិនដែលអត់ហេតុ មិនដែលខុសហេតុ មិនដែលប្រកែកតវ៉ាក្នុងការកើតឡើង និងរលត់ទៅវិញឡើយ ។

៙សង្ខតធម៌ និង អសង្ខតធម៌ ជាអនត្តាដូចគ្នា ខុសគ្នាត្រង់សង្ខតធម៌ជាផលរបស់បច្ច័យ អសង្ខតធម៌មិនមែនជាផលរបស់បច្ច័យ ។

៙**ធម្មជាតិ** ជាធម៌ដែលត្រូវដឹង ជាធម៌ដែលត្រូវត្រាស់ដឹង ការត្រាស់ដឹងនូវធម្មជាតិទើបមិនហួងហែងធម្មជាតិ ការមិនហួងហែងនូវធម្មជាតិទើបមានចិត្តស្ងប់ ចិត្តស្ងប់ក៏នៅតែជាសង្ខតធម៌ ចិត្តស្ងប់ក៏មិនមែនសត្វបុគ្គលយើងគេឡើយ ។

៙យើងអាចផុតចាកអំពីសង្ខារទុក្ខ ព្រោះមិនប្រកាន់សង្ខារថាជាយើង ។

៙រឿងរបស់ជីវិត គឺរឿងរបស់វិញ្ញាណ រឿងរបស់វិញ្ញាណ គឺជាអារម្មណ៍របស់វិញ្ញាណ អារម្មណ៍របស់វិញ្ញាណ គឺអ្វីដែលវិញ្ញាណបានដឹង វិញ្ញាណជាធម្មជាតិ ពុំមែនជាសត្វបុគ្គលទេ មានការដឹងនូវអារម្មណ៍ណា ដោយសារអារម្មណ៍នោះនាំឱ្យកើតឡើង ។

៙ក្នុងគ្រប់ធម្មជាតិទាំងអស់ មិនមានធម្មជាតិណាជាសត្វឡើយ សត្វគ្រាន់តែជាឈ្មោះសំគាល់នៃការប្រជុំរួមរបស់ធម្មជាតិតែប៉ុណ្ណោះ ។

៙ធម្មជាតិ គឺជាជីវិតប្រចាំថ្ងៃ មានចិត្ត មានចេតសិក រូប ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងអស់ហើយក្នុងព្រះអភិ-ធម្មបិដក ។

៙ការសិក្សានូវព្រះអភិធម្ម ដើម្បីឱ្យដឹងប្រភេទរបស់ធម្មជាតិ ហើយមានសម្មាទិដ្ឋិយល់ត្រូវ អស់នូវការហួងហែងបន្តិចម្តង១ តាមលំដាប់នៃបញ្ញា ។

៙បុថុជ្ជន ជាបុគ្គលបញ្ញត្តិអាស្រ័យធម្មជាតិ ដែលប្រជុំរួមគ្រប់កិលេស គ្រប់អកុសលទាំងអស់ ព្រោះមិនមានអរិយ-មគ្គណាមួយ បានកើតមកលះកិលេសអកុសលនោះ១ឡើយ ដូច្នេះមនុស្សតែងតែមានកិលេសជាធម្មតា ព្រោះកិលេស

ជាធម្មជាតិ ។

αដរាបណាមិនទាន់មានបញ្ញាជាន់ខ្ពស់ទេនោះ មនុស្ស មិនអាចបរិសុទ្ធតាមផ្លូវចិត្តឡើយ ពាក្យនេះមិនមែនស្តី បន្ទោស មិនមែនមើលងាយ ប៉ុន្តែជាពាក្យរំលឹកសតិដាស់ តឿនស្មារតីសត្វលោកឱ្យឃើញ**ធម្ម:**ពិត១ រំលត់សេចក្តី ប្រកាន់ថា មានមនុស្ស មានសត្វ មានតួខ្លួន ក្នុងធម្មជាតិដែល កើតឡើង គឺមានតែធម៌ដែលកើតឡើងព្រោះមានហេតុតែ ប៉ុណ្ណោះ ។

αអ្វីដែលកើតឡើង គឺត្រូវតែកើត អ្វីដែលរលត់ គឺត្រូវ តែរលត់ ព្រះអរិយបុគ្គលទាំងឡាយមិនបានងឿងឆ្ងល់ មិន បានសង្ស័យថា ម៉េចអីចឹង ម៉េចបានជាយ៉ាងហ្នឹងឡើយ ។

αព្រះនិព្វានជាអារម្មណ៏រំលត់កិលេស ប្រៀបដូចអ្នក ដើរហាលក្តៅ ស្រេកទឹក ឃ្លានបាយ ពងដៃពងជើងដោយ សារកំដៅថ្ងៃ ស្រាប់តែបានជួបនឹងស្រះទឹកដ៏ធំមួយ មានទឹក ថ្លា មានកំពង់រាបស្មើ ចំរុះដោយផ្កាឈូកជាច្រើនពណ៌ មាន ផ្លែទុំខ្ចី **ស្រះទឹកនេះ គឺជាឈ្មោះនៃព្រះនិព្វាន** ក្នុងសេចក្តីប្រៀបឧបមា ។

# សុត្តនិបាត

# គុហដ្ឋកសូត្រ

αជនជាប់ជំពាក់ក្នុងគុហាគឺរាងកាយ ស្រោបដោយកិលេសច្រើនប្រការ ធ្លាក់ចុះក្នុងកាមគុណ ជាគ្រឿងធ្វើចិត្តឱ្យវង្វេង ជនមានសភាពដូច្នេះ ឈ្មោះថាឆ្ងាយអំពីវិវេក ព្រោះថាកាមទាំងឡាយក្នុងលោក បុគ្គលមិនងាយនឹងលះបង់បានឡើយ ។

αកាមគុណទាំងឡាយមានសេចក្តីប្រាថ្នាជាហេតុ ជាប់ជំពាក់ដោយសេចក្តីត្រេកអរក្នុងភព ស្រាយរួចបានដោយសេចក្តីលំបាក ទាំងដែលអ្នកដទៃមិនអាចស្រាយឱ្យបានឡើយ ពួកជនទាំងឡាយ សង្ឃឹមចំពោះកាមក្នុងអនាគត សោកស្តាយចំពោះកាមក្នុងអតីត លិចលង់ក្នុងកាមជាបច្ចុប្បន្ន ជាសត្វរួចបានដោយកម្រ ។

αសត្វទាំងនោះ ជាប់ជំពាក់វិលវល់ ខ្វល់ខ្វាក់ វង្វេងក្នុងកាមទាំងឡាយ មិនកាន់យកនូវព្រះពុទ្ធវចនៈ តាំងនៅមាំក្នុងធម៌មិនស្មើ ដល់នូវសេចក្តីទុក្ខ តែងខ្សឹក ខ្សួលថា ឱហ្ន៎ អាត្មាអញច្យុតិអំពីអត្តភាពនេះនឹងទៅកើតក្នុងទីណា ។

αព្រោះហេតុនោះឯង បុគ្គលគប្បីសិក្សាត្រៃសិក្ខាក្នុងសាសនានេះ គប្បីដឹងថារបស់អ្វីៗក្នុងលោក ជារបស់មិនស្ងប់ មិនគប្បីប្រព្រឹត្តនូវការមិនស្ងប់ ព្រោះហេតុតែរបស់នោះឡើយ អ្នកប្រាជ្ញទាំងឡាយតែងពោលនូវជីវិតនោះ ថាជារបស់មានប្រមាណតិច ។

αតថាគតឃើញនូវពពួកសត្វនេះ លុះតាមអំណាចនៃសេចក្តីប្រាថ្នាក្នុងភពទាំងឡាយ កំពុងអន្ទះអន្ទែងក្នុងលោក ពួកជនអ្នកថោកថយ សូម្បីខ្សឹកខ្សួលនៅក្នុងមាត់របស់មច្ចុរាជក៏ដោយ ក៏នៅតែមិនប្រាសចាកសេចក្តីប្រាថ្នាចំពោះភពតូចភពធំឡើយ ។

αអ្នកទាំងឡាយ ចូរមើលពពួកជនដែលប្រកាន់ថារបស់នោះៗជារបស់យើងកំពុងអន្ទះអន្ទែង ដូចពួកមច្ឆាជាតិដែលកំពុងអន្ទះអន្ទែងក្នុងទីដែលមានទឹកតិច មានក្រសែទឹក

រីងអស់ហើយដូច្នោះឯង អ្នកប្រាជ្ញបានឃើញទោសនុ៎ះហើយ ក៏មិនមាននូវសេចក្ដីប្រកាន់ថា នុ៎ះជារបស់យើងឡើយ ហើយ ក៏មិនបានធ្វើការជាប់ជំពាក់នៅក្នុងភពទាំងឡាយផងដែរ ។

៙អ្នកប្រាជ្ញកំណត់ដឹងនូវផស្សៈ ហើយលះបង់នូវសេចក្ដីត្រេកអរពេញចិត្តក្នុងផស្សៈទាំងពីរប្រការ គឺផស្សៈដែលកើតហើយ និង ហេតុដែលនាំឱ្យកើតផស្សៈ អ្នកប្រាជ្ញតិះដៀលអាត្មាឯងដោយកម្មណា ក៏មិនបានធ្វើនូវកម្មនោះ ហើយជាអ្នកមិនជាប់នៅក្នុងអារម្មណ៍ដែលបានឃើញ បានឮជាដើម ។

៙អ្នកប្រាជ្ញកំណត់ដឹងនូវកាមសញ្ញា ហើយឆ្លងចាកអន្លង់ មិនជាប់នៅក្នុងអារម្មណ៍ជាគ្រឿងហួងហែង ដកចោលនូវព្រួញពិសគឺកិលេស មិនមានសេចក្ដីប្រមាទ ត្រាច់ទៅទាំងមិនមានសេចក្ដីប្រាថ្នាក្នុងលោកនេះ និង លោកខាងមុខ ។

**ចប់គុហដ្ឋកសូត្រ**

## ៥.សនិទស្សនា ធម្មា

ពួកធម៌គួរដល់ការឃើញគឺ **រូបារម្មណ៍**

៙នៅពេលដែលខឹងក្រោធជាមួយនឹងអ្នកដទៃ គួរតែសម្លាប់សេចក្ដីក្រោធនោះឯង ទើបឈ្មោះថាជាអ្នកឈ្នះ ហើយដេកនៅជាសុខ តាមពិតអ្នកដទៃនោះគ្រាន់តែជានិមិត្តរបស់កិលេសខ្លួនឯងតែប៉ុណ្ណោះ បើយើងសម្លាប់សេចក្ដីក្រោធហើយនោះ តើអ្នកណាមកធ្វើឱ្យយើងដេកមិនលក់ តើមានអ្វីសំរាប់ឱ្យយើងក្រោធទៀតទៅ ។

៙មិនត្រូវធ្វើអត្តឃាតគឺសម្លាប់ខ្លួនឯងទេ តែត្រូវសម្លាប់កិលេសដែលប្រកាន់បញ្ចក្ខន្ធថាជាតួខ្លួនវិញ ទើបបានអស់ទុក្ខ ។

៙សង្ខារទាំងឡាយដែលកើតអំពីហេតុ មានសភាពទ្រុឌទ្រោម ជារបស់ដទៃ មិនមានអ្វីជារបស់ខ្លួនឡើយ គឺធម៌ដែលកើតអំពីហេតុហ្នឹងឯង ដែលមិនមានអ្វីជាខ្លួនឯង និងមិនមានអ្វីជារបស់ខ្លួន ។

៧ទឹកដែលគេចាក់ចោលទៅលើផែនដីស្ងួត រមែងជ្រាបចូលទៅក្នុងដីបាត់អស់ មិនអាចយកមកប្រើការលាងដៃលាងជើង ឬ បរិភោគបានឡើយ យ៉ាងណា អាយុសង្ខាររមែងអស់ទៅ សូន្យទៅ តាមលំដាប់នៃវ័យក៏យ៉ាងនោះ ដែរ មិនគួរមានសេចក្តីប្រកាន់នៅក្នុងសង្ខារទាំងពួងឡើយ បើការពិតវាយ៉ាងនេះទៅហើយនោះ ។

# សុភាថេរី នៅក្នុងជីវកម្ពវ័ន

~៧~៧~៧~៧~៧~

**សុវណ្ណការបុត្ត** ជាអ្នកលេង រារាំងភិក្ខុនីឈ្មោះ **សុភា** កំពុងដើរទៅកាន់ជីវកម្ពវ័ន ជាទីរីករាយ ភិក្ខុនីឈ្មោះ សុភា ក៏បានពោលនឹងសុវណ្ណការបុត្តនោះថា កំហុសដូចម្តេចដែលអាត្មាប្រទូស្តដល់អ្នក បានជាអ្នកឈររាំង អាត្មា នៃអាវុសោ បុរសមិនគួរប៉ះពាល់នូវស្ត្រីជាបព្វជិតទេ **សិក្ខាទាំងឡាយក្នុងសាសនារបស់ព្រះសាស្តា ជាសិក្ខាគួរគោរព ព្រះសុគតបានសំដែងហើយដល់អាត្មា ហេតុដូចម្តេចក៏អ្នកមកឈររាំងអាត្មាដែលជាស្ត្រីមានចំណែកនៃធម៌ដ៏បរិសុទ្ធ មិនមានទីទួលគឺកិលេស ។**

អ្នកជាបុគ្គលមានចិត្តល្អក់ ប្រកបដោយធូលីគឺរាគៈ ហេតុដូចម្តេចក៏អ្នកមកឈររាំងអាត្មា ដែលជាស្ត្រីមានចិត្តថ្លាស្អាត ប្រាសចាកធូលី គឺរាគៈ មិនមានទីទួលគឺកិលេស មាន

ចិត្តផុតស្រឡះហើយ ចាកខន្ធបញ្ចកៈទាំងឡាយ ។

**អ្នកលេងពោលថា** នាងជាស្ត្រីនៅក្រមុំផង មិនអាក្រក់ផង បព្វជ្ជានឹងធ្វើប្រយោជន៍អ្វីដល់នាង ចូរនាងបោះចោលកាសាយចីវរចេញទៅ ហើយចូរមក យើងនឹងបានត្រេកត្រអាលក្នុងព្រៃដែលមានផ្ការីកល្អ សុវណ្ណការបុត្តពោលពាក្យ លួងលោមច្រើនបែបច្រើនយ៉ាងទៀត ។

**ព្រះនាងថេរីពោលថា** ហេតុដូចម្តេចក៏អ្នកមានគំនិតខុស សំឡឹងមើលអាត្មា ព្រោះឃើញនូវអារម្មណ៍ដែលសន្មតថា មានខ្លឹមក្នុងរាងកាយនេះ ដ៏ពេញដោយសាកសពគ្រាន់តែ ការចំរើនរបស់ព្រៃស្មសាន ជារាងកាយបែកធ្លាយជាធម្មតា ។

**អ្នកលេងពោលថា** ភ្នែកទាំងពីររបស់នាងដូចជាភ្នែកកូនម្រឹគញី ឬដូចជាភ្នែកនៃកិន្នរីក្នុងចន្លោះនៃភ្នំ តម្រេកក្នុងកាមរបស់ខ្ញុំ រមែងចំរើនក្រៃលែង ព្រោះឃើញនូវភ្នែករបស់នាង ។ កាមគុណរបស់ខ្ញុំរមែងចំរើនឡើងក្រៃលែង ព្រោះឃើញភ្នែករបស់នាង ដែលប្រៀបដូចត្របកនៃផ្កាឧប្បល ត្រង់មុខប្រាសចាកមន្ទិលប្រាកដស្មើដោយមាស ។ នៃនាងមានរូបស្រស់ស្រោង មានភ្នែកថ្លាស្អាត បើទុកជាយើងទៅកាន់ទីឆ្ងាយ ក៏នៅតែរលឹកឃើញ ម្នាលនាងមានភ្នែកថ្លាដូចភ្នែកកិន្នរី ឥតមានអ្វីមួយជាទីស្រឡាញ់នៃខ្ញុំជាងភ្នែករបស់នាងទេ ។

**ព្រះនាងសុភាថេរីពោលថា** អ្នកប្រាថ្នានូវធីតាជាឱរសរបស់ព្រះពុទ្ធនេះ ឈ្មោះថាប្រាថ្នាដើម្បីដើរទៅតាមផ្លូវខុស ឈ្មោះថាស្វែងរកព្រះច័ន្ទមកធ្វើជាល្បែងលេង ឈ្មោះថាប្រាថ្នាដើម្បីលោតឡើងកាន់ភ្នំសិនេរុ ។ ឥឡូវនេះប្រសិនបើរាគៈគប្បីមានដល់អាត្មាក្នុងអារម្មណ៍ណា អារម្មណ៍នោះ មិនមានក្នុងលោក ព្រមទាំងទេវលោក អាត្មាមិនដឹងថារាគៈនោះជាអ្វីទេ ព្រោះអាត្មាបានដក ចោលនូវរាគៈនោះទាំងឫសទាំងគល់ ដោយអរិយមគ្គហើយ ។

ខន្ធបញ្ចកៈដែលស្ត្រីណា មិនបានពិចារណាឃើញ ឬ ថា

ស្ត្រីណាដែលមិនបានចូលទៅអង្គុយជិតព្រះសាស្ដា អ្នកចូរប្រលោមនូវស្ត្រីប្រាកដដូច្នោះចុះ អ្នកនឹងក្ដៅក្រហាយចិត្តព្រោះអាស្រ័យសុភាភិក្ខុនីនេះ ដែលជាអ្នកដឹងនូវអរិយសច្ចធម៌ ។ ស្មារតីរបស់អាត្មាបានតម្កល់ខ្ជាប់ហើយ ក្នុងបុគ្គលអ្នកជេរ និង អ្នកថ្វាយបង្គំក្នុងសុខ និង ទុក្ខ ចិត្តរបស់អាត្មាមិនជាប់ក្នុងអារម្មណ៍ទាំងអស់នោះ ព្រោះដឹងច្បាស់ថា **សង្ខតារម្មណ៍ជារបស់មិនស្អាត ។ អាត្មាជាសាវិការបស់ព្រះសុគត ជាអ្នកដើរទៅដោយយានគឺអដ្ឋង្គិកមគ្គ** មានសរគឺកិលេសដកចោលហើយ ឥតមានអាសវៈ ជាអ្នកត្រេកអរក្នុងផ្ទះស្ងាត់ ។ អាត្មាបានឃើញរូបយន្តឈើជាគ្រោងថ្មី ដែលតាក់តែងដ៏វិចិត្រ ចងរឹតដោយខ្សែសរសៃទាំងឡាយ និង ឈើកន្លាស់ទាំងឡាយដូចជាគេរាំដោយអាការផ្សេងៗ កាលបើខ្សែសរសៃ និង ឈើកន្លាស់នោះ ដាច់របូតចេញរាត់រាយរលុងរង្គោះបាក់បែកខ្ចាត់ខ្ចាយ កាលបើរូបយន្តរង្គោះដាច់ខ្ចាត់ខ្ចាយហើយ បុគ្គលមិនគប្បីបានរូបយន្តនោះទេ បុគ្គលគប្បីតំកល់ចិត្តក្នុងរូបនោះដូចម្ដេចកើត ។ រាងកាយទាំងឡាយរបស់អាត្មាដូចគ្នានឹងរូបយន្តដែរ បើវៀរចាកពួកធម៌ទាំងឡាយ មានបឋវីធាតុជាដើមហើយរមែងប្រព្រឹត្តទៅមិនបាន រាងកាយបើវៀរចាករូបធម៌ហើយ ប្រព្រឹត្តទៅមិនបានទេ **បុគ្គលគប្បីតំកល់ចិត្តក្នុងរាងកាយនោះដូចម្ដេចកើត ។**

**បុគ្គលឃើញរូបស្ត្រីដែលគេគូរនឹងជញ្ជាំងលាបលនដោយថ្នាំដ៏ស្រស់យ៉ាងណាមិញ អ្នកមានការឃើញវិបរិតក្នុងរូបនោះ ក៏យ៉ាងនោះដែរ** បញ្ញាជារបស់មនុស្សឥតប្រយោជន៍ទេឬ ។ នៃបុគ្គលអន្ធពាល **អ្នកស្ទុះចូលមកជិតនូវអត្តភាពដ៏ទទេ ដែលប្រៀបដូចជាថ្ងៃបណ្ដើរភ្លួន តាំងនៅអំពីខាងមុខ ឬដូចជាយល់សប្តិឃើញដើមឈើមាស ពុំនោះដូចជារូបយន្តគ្រាំគ្រាក្នុងកណ្ដាលនៃជន ។**

ពពុះបាំងស្បែកកណ្ដាលភ្នែក ឬព្រៀកទឹកភ្នែក ឬក៏ពកបាយភ្នែក តែងកើតក្នុងមណ្ឌលនៃភ្នែកនោះ ដូចជាពពុះទឹកល័ក្ខដែលបុគ្គលប្រោះលើកម្រាលចៀមស្ងួត ព្រោះថា សណ្ឋានរបស់ភ្នែក មានពណិផ្សេងៗ ដែលសង្ខារតាក់តែងហើយ ។

នាងសុភាភិក្ខុនី មានចិត្តឥតជាប់ជំពាក់ បានឆ្កៀលភ្នែកជាទីស្រឡាញ់ ហើយក៏ឱ្យដល់បុរសនោះក្នុងពេលនោះដោយពាក្យថា ហ៎អាត្មាឱ្យភ្នែកដល់អ្នក ចូរអ្នកយកភ្នែកនេះទៅចុះ ។ រាគៈរបស់បុរសនោះ ក៏ប្រាសចាកចេញក្នុងខណៈនោះផង បុរសនោះបានញ៉ាំងសុភាភិក្ខុនីឱ្យអត់ទោសក្នុងទីនោះផង ដោយពាក្យថា ម្នាលនាងជាព្រហ្មចារិនី សួស្ដីចូរមានដល់នាង ការប្រព្រឹត្តិអនាចារបែបនេះ នឹងមិនមានដល់ខ្ញុំទេ ។ បើខ្ញុំបៀតបៀនជនដែលគ្មានរាគៈយ៉ាងនេះ ក៏ហាក់ដូចជាខ្ញុំឱបភ្លើងកំពុងឆេះសន្ធោសន្ធៅ ឬចាប់នៅអា-សិរពិស បើដូច្នោះ សូមសួស្ដីកើតមានដល់នាង សូមនាងអត់ទោសដល់ខ្ញុំ ។

ព្រះនាងសុភាភិក្ខុនី លុះរួចអំពីបុរសជាអ្នកលេងនោះហើយ ក៏បានទៅកាន់សំណាក់នៃព្រះសម្មាសម្ពុទ្ធដ៏ប្រសើរ ចក្ខុក៏កើតឡើងដូចដើម ព្រោះបានឃើញនូវមហាបុរិសលក្ខណៈ ដែលកើតអំពីបុណ្យដ៏ប្រសើរ ។

**ចប់សុភាភិក្ខុនី**

# វីតសោកថេរគាថា

៚α៚α៚α៚α៚α៚

ព្រះថេរនេះ ក៏ជាអ្នកមានបុណ្យ បានធ្វើហើយក្នុងព្រះពុទ្ធជាម្ចាស់អង្គមុនៗ សន្សំបុណ្យច្រើនសន្ធឹកសន្ធាប់ទុកក្នុងភពនោះៗ បានកើតក្នុងត្រកូលព្រាហ្មណ៍មួយក្នុងសម័យនៃការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាម **សិទ្ធត្ថ** ដល់នូវការសំរេចក្នុងវិជ្ជាសិល្បសាស្ត្ររបស់ព្រាហ្មណ៍ រួចបានលះបង់នូវកាមគុណទាំងឡាយ បួសជាតាបស មានពួកតាបសដទៃជាច្រើនហែហមរួមជាមួយនៅក្នុងព្រៃ ។

បានស្តាប់ដំណឹងមកថា ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ដឹងក្នុងលោក ក៏មានការរីករាយត្រេកអរក្រៃពេក ហើយក៏មានការត្រិះរិះថា ព្រះពុទ្ធជាម្ចាស់ទាំងឡាយ កម្របានត្រាស់ដឹងនៅក្នុងលោកណាស់ ដូច្នេះយើងគួរចូលគាល់ព្រះពុទ្ធក្នុងពេលនេះឯង ។

ការធ្វើដំណើរទៅគាល់ព្រះសាស្តាព្រមជាមួយបរិស័ទជាច្រើន កាលដែលនៅសល់ផ្លូវមួយយោជន៍កន្លះទៀត នឹងដល់ ក៏បានអស់ជីវិតនៅតាមផ្លូវ ដោយមានសេចក្តីជ្រះថ្លាបញ្ជូនទៅក្នុងព្រះពុទ្ធជាម្ចាស់ បានបដិសន្ធិក្នុងទេវលោក ។

ការត្រាច់រង្គាត់ក្នុងទេវលោក និង មនុស្សលោកទៅមកៗ អស់កាលជាយូរអង្វែង ទីបំផុតកើតជាប្អូនរបស់ព្រះបាទធម្មាសោកនៅក្នុងពុទ្ធកាលនេះ ដែលព្រះសម្មាសម្ពុទ្ធបរិនិព្វានកន្លងទៅបាន ២១៨ឆ្នាំ លោកបានមានព្រះនាមថា **វីតសោក:** ។

វីតសោករាជកុមារ ចំរើនវ័យហើយ បានរៀនវិជ្ជាសិល្បសាស្ត្រ រួមជាមួយខត្តិយកុមារទាំងឡាយដោយការឆ្លាតពូកែ ព្រមទាំងជំនាញនៅក្នុងសុត្តន្តបិដក និង អភិធម្មបិដក ទាំងដែលនៅជាគ្រហស្ថ ដោយអាស្រ័យ **ព្រះគិរិទត្តត្ថេរ** ។

ថ្ងៃមួយបានទទួលកញ្ចក់អំពីដៃនៃជាងកាត់សក់ ក្នុងពេលដាក់ព្រះមស្សុ (កោរពុកមាត់ពុកចង្កា) សំឡឹងមើល

ព្រះវរកាយ ឃើញអវយវៈដែលមានស្បែកជ្រួញ និង សក់ស្កូវជាដើម ក៏បង្កើតការស្លុតព្រះទ័យ ញ៉ាំងចិត្តឱ្យធ្លាក់ចុះក្នុងវិបស្សនាភាវនា បានជាព្រះសោតាបន្នបុគ្គល លើអាសនៈនោះឯង រួចបានបួសក្នុងសំណាក់ព្រះគិរិទត្តត្ថេរ ហើយបានជាព្រះអរហន្តក្នុងកាលមិនជាយូរប៉ុន្មានឡើយ ។

ព្រះថេរៈកាលបានជាព្រះអរហន្តហើយ បានពោលព្រះគាថាដោយសេចក្ដីថា :

**ជាងកោរកាត់សក់ បានចូលមករកយើងដោយគិតថា នឹងកាត់សក់របស់យើង យើងទើប យកកញ្ចក់អំពីជាងកាត់សក់នោះមកឆ្លុះមើលរាងកាយ រាងកាយរបស់យើងនេះ បានប្រាកដជារបស់ទទេ ៗ**

**សេចក្ដីងងឹតគឺអវិជ្ជាក្នុងកាយ ដែលជាឫសគល់នៃការងងឹត បានវិនាសអស់ទៅ កិលេសដូចក្រណាត់សំពត់ចាស់យើងកាត់ចោលហើយ ឥឡូវនេះភពថ្មីមិនមានទៀតឡើយ ៗ**

α**សរីរំ បច្ចវេក្ខិស្ស** សេចក្ដីថា ពិចារណារាងកាយ ដែលជរាគ្របសង្កត់ហើយ ដោយខ្លួនឯងថា រាងកាយរបស់យើងត្រូវជរាគ្របសង្កត់ហើយហ្ន៎ ដោយចំពោះគឺការមើលនិមិត្តលើស្បែកមុខ មានស្បែកជ្រួញជ្រីវជាដើម ។

ក៏កាលពិចារណាយ៉ាងនេះ រាងកាយរបស់យើងក៏ប្រាកដជារបស់សូន្យទទេ ចាកសភាពផ្សេងៗមានសភាពទៀងជាដើម ។

αពន្លឺរបស់បញ្ញាបានកំចាត់បង់នូវអវិជ្ជា កិលេសដូចក្រណាត់សំពត់ចាស់ យើងក៏កាត់បានហើយ គឺកិលេសទាំង-ឡាយដែលមានឈ្មោះថា **ចោរា** ព្រោះដូចពួកចោរដោយការចូលទៅប្លន់យកទ្រព្យ គឺកុសលឬដូចជាសំពត់ចាស់ដាច់-ដាច ដោយសេចក្ដីថា ឥស្សរជនមិនត្រូវការ មានតែការខ្ពើមព្រោះជាសំពត់ដែលគេចោលក្នុងគំនរសំរាម ។

**ចប់ អដ្ឋកថា វីតសោកថេរគាថា**

αសត្វលោកត្រូវជរាគ្របសង្កត់ កាលដែលជរាគ្របសង្កត់ហើយ សត្វលោកត្រូវបាត់បង់នូវវ័យក្មេង បុគ្គលគួរពិចារណាឱ្យឃើញថា ជរានេះ គឺជាចោរកំណាច ។

αសត្វលោកត្រូវព្យាធិរួបរឹត កាលដែលព្យាធិរួបរឹតហើយ សត្វលោកត្រូវបាត់បង់នូវសុខភាពរាងកាយ បុគ្គលគួរពិចារណាឱ្យឃើញថា ព្យាធិនេះ គឺជាចោរកំណាច ។

αសត្វលោកត្រូវមច្ចុកំចាត់ កាលដែលមច្ចុកំចាត់ហើយ សត្វលោកត្រូវបាត់បង់នូវជីវិត បុគ្គលគួរពិចារណាឱ្យឃើញថា មច្ចុនេះគឺជាចោរកំណាច ។

αមនុស្សលោកដោយច្រើនតែងគិតថា សេចក្តីស្លាប់នៅរង់ចាំអំពីខាងមុខ ប៉ុន្តែយើងគួរតែពិចារណានូវព្រះពុទ្ធដីកាក្នុងគម្ពីរ **ធម្មបទ** ទណ្ឌវគ្គទី១០ ព្រះបរមសាស្តាទ្រង់ប្រារព្ធឧបោសថកម្មនៃពួកឧបាសិកាទាំងឡាយ ដែលឧបាសិកាទាំងនោះមានការប្រាថ្នាសម្បត្តិក្នុងភព ព្រះអង្គទ្រង់ត្រាស់ថា **យថា ទណ្ឌេន គោបាលោ គាវោ បាចេតិ គោចរំ ឯវំ ជរា ច មច្ចុ ច អាយុំ បាចេន្តិ បាណិនំ ៗ**

គង្វាលគោ ក្បៀងគោទាំងឡាយទៅកាន់ទីគោចរ (កន្លែងមានស្មៅមានទឹក) ដោយអាជ្ញាគឺដំបង ឬរំពាត់ យ៉ាងណាមិញ ជរា គឺសេចក្តីទ្រុឌទ្រោមគ្រាំគ្រា និង មច្ចុរាជ គឺសេចក្តីស្លាប់ ក៏ក្បៀងទៅនូវអាយុរបស់សត្វទាំងឡាយក៏យ៉ាងនោះឯង ។

ពាក្យដែលថា ជរា និង មច្ចុ ក្បៀងទៅនូវអាយុរបស់សត្វទាំងឡាយ ដោយសេចក្តីថា ជរា និង មច្ចុនៅអំពីខាងក្រោយ ។

αតាមពិត ជរា ព្យាធិ មរណៈ គ្មានអ្វីក្រៅអំពីនាមរូបដែលកំពុងប្រាកដនេះឡើយ កាលដែលនាមរូបរលត់ទៅៗគ្រប់ៗខណៈ នោះគឺបញ្ចក្ខន្ធទំពាស៊ីនូវសត្វលោក តែបើនិយាយដោយបរមត្ថធមិសុទ្ធ គឺបញ្ចក្ខន្ធទំពាស៊ីនូវខ្លួនរបស់វា ។

αពេលវេលារមែងស៊ីនូវពពួកសត្វទាំងអស់ ព្រមទាំង

ខ្លួនឯង ។ ពេលវេលានេះ គឺបញ្ចក្ខន្ធហ្នឹងឯង ដែលថាស៊ី គឺការរលត់ទៅសូន្យទៅនៃខន្ធដែលកើតឡើងនោះ ។

-បុគ្គលណាជាអ្នកអាចស៊ីពេលវេលាបានវិញ ?

គឺព្រះអរហន្តទាំងឡាយ ព្រោះលោកបានដុតតណ្ហាដោយភ្លើងអរហត្តមគ្គ កំចាត់ចោលនូវបដិសន្ធិថ្មី ពេលវេលាក្រោយអំពីចុតិចិត្ត មិនមានសំរាប់លោកទេ ។

αគេមិនអាចសប្បាយរីករាយទៅកើតទេ បើសត្រូវកំពុងតែឡោមព័ទ្ធ ប៉ុន្តែគេត្រូវរកឧបាយដើម្បីគេចចេញអំពីសត្រូវ យ៉ាងណាមិញ បើជីវិតនេះត្រូវខ្មាំងសត្រូវគឺជរា ព្យាធិ មរណះឡោមព័ទ្ធយ៉ាងនេះ តើគួរនៅសប្បាយដោយកាមគុណ ឬក៏ត្រូវរកឧបាយចេញចាកអំពីខ្មាំងសត្រូវវិញ ។

αក្នុង រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ តាមពិតរកសត្វបុគ្គលតួខ្លួនពុំមានឡើយ គឺមានតែ ជរា ព្យាធិ និង មច្ចុតែប៉ុណ្ណោះឯង ។

αបញ្ចក្ខន្ធ គឺជាភូមិចោរកំណាច មានតែការលួងលោមបោកបញ្ឆោត និង ការធ្វើទារុណកម្ម រួចសម្លាប់កាត់ក

## ៦-អនិទស្សនា ធម្មា

ពួកធម៌ដែលមិនអាចឃើញបានដោយចក្ខុវិញ្ញាណ

បានដល់បរមត្ថធម៌ទាំងអស់ វៀរតែវណ្ណៈរូប១ ប៉ុណ្ណោះ។

**αនោះបីចេះស្ទាត់ហើយក៏ដោយ ក្នុងកិច្ចការងារគ្រប់យ៉ាង ត្រូវតែអាស្រ័យការមិនធ្វេសប្រហែស គឺការប្រុងប្រយ័ត្នស្មារតី ទើបសំរេចកិច្ចការបានល្អ ។**

αមនុស្សយើងម្នាក់ៗប្រៀបបីដូចទូរទស្សន៍១ គ្រឿងប៉ុន្តែជាទូរទស្សន៍ដែលមិនមែនមានតែរូប និង សំលេងទេ គឺមានទាំងក្លិន រស ផោដ្ឋព្វ និង ពួកធម៌ទាំងឡាយផ្សេងៗទៀតផង លើកលែងតែសត្វបុគ្គលចេញ ។

αរូបមនុស្សនៅក្នុងទូរទស្សន៍ គ្រាន់ត្រឹមតែជារូបដែលគួរដល់ការឃើញប៉ុណ្ណោះ មិនមានមនុស្សសត្វពិតៗឡើយ យ៉ាងណាមិញ រូបារម្មណ៍គ្រប់យ៉ាង គ្រប់ពេលក៏ដូចគ្នាដែរ ពុំមានសត្វបុគ្គលតួខ្លួននៅក្នុងរូបារម្មណ៍ឡើយ ។

αសំលេងមនុស្សនៅក្នុងទូរទស្សន៍ គ្រាន់ត្រឹមតែជាសំលេងមួយផ្នែកផ្សេងអំពីរូបារម្មណ៍ មនុស្សសត្វពិតៗនៅក្នុងទូរទស្សន៍ជាអ្នកនិយាយពុំមានទេ យ៉ាងណាមិញសំលេងមនុស្សទូទៅធម្មតាៗដែលសន្មតថាមនុស្សម្នាក់ និយាយនោះតាមបរមត្ថពិតឥតមានមនុស្សនិយាយទេ គឺមានចិត្តជាសមុដ្ឋាន និង បឋវីធាតុដែលកើតអំពីចិត្តប៉ះខ្ទប់ជាមួយ កម្មជរូប គឺរូបដែលកើតអំពីកម្ម សទ្ទរូបក៏កើតឡើង ប្រៀបដូចសំលេងស្គរទូង ។

**αសតិមានការរលឹកជាលក្ខណៈ គឺរលឹកដឹងសភាវធម៌ដែលកំពុងប្រាកដមួយលក្ខណៈៗ ទើបឃើញសភាវធម៌មិនមែនតួខ្លួនសត្វបុគ្គលៗ**

αហេតុត្រឹមតែ **ចិត្តុប្បាទ** គឺការកើតឡើងនៃ ចិត្តធម្មជាតិចិត្តរមែងតែងតែនឹកគិតក្នុងរឿងផ្សេងៗ ជួនកាលប្រកបដោយសោមនស្សវេទនា ជួនកាលប្រកបដោយទោមនស្សវេទនា ជួនកាលក៏ព្រងើយៗ ពេលខ្លះចិត្តប្រកបដោយរាគៈ ពេលខ្លះចិត្តប្រកបដោយទោសៈ ពេលខ្លះចិត្តល្អជាកុសល ។ល។ ដើម្បីឱ្យកាន់តែច្បាស់ថាអ្វីទៅដែលជាចិត្តយើងគួរនឹកដល់ពេលសម្រាន្តលក់ វាខុសអំពីពេលដែលមិនលក់នោះយ៉ាងណាខ្លះ នៅពេលសម្រាន្តលក់ មិនមានបានដឹងអារម្មណ៍ណាៗក្នុងលោក៦ឡើយ ដូច្នេះការដឹងហ្នឹងឯង គឺដឹងអារម្មណ៍តាមទ្វារ៦ ឈ្មោះថាចិត្ត សូម្បីកំពុងសម្រាន្តលក់ក៏មានចិត្តដែរ ប៉ុន្តែជាចិត្តផ្សេងអំពីវិថីចិត្តតាមទ្វារទាំង៦ គួរអប់រំសតិរលឹកដឹងរឿយៗចំពោះចិត្តតាមទ្វារទាំង៦ នេះឱ្យបានដឹងច្បាស់បន្តិចម្តងៗថា ត្រឹមតែជាការកើតឡើងនៃចិត្តប៉ុណ្ណោះ **មនុស្សតែងមានចិត្តក្នុងជីវិតប្រចាំថ្ងៃ ប៉ុន្តែចិត្តមិនមែនជាមនុស្ស មិនមែនជាសត្វ មិនមែនជាតួខ្លួនយើងគេឡើយ ។**

# វនសំយុត្ត
# វិវេកសូត្រទី១

α ខ្ញុំបានស្តាប់មកយ៉ាងនេះ ។

សម័យមួយ ភិក្ខុមួយរូបនៅក្នុងដងព្រៃមួយ ក្នុងដែនកោ-សល ។ ក៏ក្នុងសម័យនោះ ភិក្ខុនោះទៅកាន់ទីសម្រាកក្នុងវេលាថ្ងៃ ហើយត្រិះរិះនូវអកុសលវិតក្កៈទាំងឡាយដ៏លាមកដែលអាស្រ័យនឹងបញ្ចកាមគុណ ។

ក្នុងកាលនោះ មានទេវតាដែលអាស្រ័យនៅក្នុងដងព្រៃនោះ ជាអ្នកមានសេចក្តីអនុគ្រោះ ប្រាថ្នានូវប្រយោជន៍ដល់ភិក្ខុនោះ ប្រាថ្នាដើម្បីធ្វើភិក្ខុនោះឱ្យសង្វេគ ក៏ចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ហើយ បានពោលនឹងភិក្ខុនោះដោយគាថាទាំងឡាយថា :

**លោកម្ចាស់** សេចក្តីស្ងាត់ បានជាចូលមកកាន់ ព្រៃ តែចិត្តរបស់លោក នៅតែត្រាច់ទៅក្នុងអារម្មណ៍ខាងក្រៅ លោកចូរជាជននាំចេញនូវឆន្ទរាគៈក្នុងជនដទៃ តអំពីនោះ លោកនឹងបានសេចក្តីសុខ ប្រាសចាករាគៈមិនខាន លោកចូរលះបង់សេចក្តីមិនត្រេកអរក្នុងព្រហ្មចរិយធម៌ ចោលចេញ លោកចូរជាអ្នកមានស្មារតី ។

ខ្ញុំសូមរំលឹកលោក ដែលជាអ្នកមានស្មារតី ព្រោះថា ធូលី គឺកិលេស ដែលបណ្ឌិតហៅថា បាតាលនេះ លំបាកនឹងឆ្លងណាស់ ធូលីគឺកាមកុំនាំលោកទៅឡើយ ដូចសត្វស្លាបដែលប្រឡាក់ខ្លួនដោយអាចម៍ដី ប្រឹងទទះជម្រុះធូលី ដែលប្រឡាក់ខ្លួនឱ្យធ្លាក់ចេញ យ៉ាងណា ភិក្ខុអ្នកមានព្យាយាម មានស្មារតី តែងធ្វើធូលី គឺកិលេសដែលប្រឡាក់ខ្លួនឱ្យធ្លាក់ចេញយ៉ាងនោះឯង ។

αមានភិក្ខុមួយអង្គទៀត នៅក្នុងដងព្រៃនៃដែនកោសលដែរ លោកមានការត្រិះរិះដោយអកុសលវិតក្កៈ គឺ កាមវិតក្កៈ ព្យាបាទវិតក្កៈ វិហឹសាវិតក្កៈ ។

ទេវតាបានពោលចំពោះភិក្ខុនោះថា លោកដែលវិតក្កៈទាំងឡាយទំពាស៊ីបាន ព្រោះមិនយកចិត្តទុកដាក់ដោយ

ឧបាយប្រាជ្ញា ចូរលោកលះបង់ឧបាយមិនមែនជាប្រាជ្ញាចេញ ហើយចូរត្រិះរិះដោយឧបាយប្រាជ្ញាវិញ ប្រារព្ធនូវព្រះសាស្តា ព្រះធម៌ និង ព្រះសង្ឃ ជាអ្នកប្រព្រឹត្តសីល រមែងបាននូវបាមោជ្ជៈ បីតិ សុខៈ ឥតសង្ស័យ បើលោកមានបាមោជ្ជៈច្រើនជាងនេះទៅទៀត និងធ្វើនូវទីបំផុតទុក្ខបាន ។

ฯបើពុទ្ធបរិស័ទរលឹកដល់ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ គង់ខ្លាស់បាប ខ្ពើមបាបពុំខាន ព្រោះព្រះពុទ្ធជាបុគ្គលស្អាតបរិសុទ្ធ ព្រះធម៌មានគុណចម្លងសត្វចេញចាកទុក្ខបាន សាវ័ករបស់ព្រះពុទ្ធជាបុគ្គលស្ងប់ទុក្ខ រុងរឿង ។

ម្យ៉ាងទៀតបុគ្គលដែលបានដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីរលឹក គួរធ្វើឱ្យពេញលេញក្នុងសីល ហើយនៅដោយបីតិ សុខៈ ក្នុងសីលរបស់ខ្លួន ព្រោះបានពិចារណាឃើញសីលមានតម្លៃជាងទ្រព្យសម្បត្តិក្នុងលោក ។

# បុគ្គលបុច្ឆាសូត្រទី១៤

ฯ ฯ ฯ ฯ ฯ

សម័យមួយ ភិក្ខុមួយរូបនៅក្នុងដងព្រៃមួយ ក្នុងដែនកោសល ។ ក៏សម័យនោះឯង ភិក្ខុនោះត្រឡប់មកពីបិណ្ឌបាត ធ្វើភត្តកិច្ចស្រេចហើយ ក្នុងវេលាក្រោយភត្ត ក៏ចុះកាន់ស្រះបោក្ខរណី រួចហិតផ្កាឈូក ។

គ្រានោះឯង ទេវតាដែលនៅអាស្រ័យក្នុងដងព្រៃនោះ ជាអ្នកអនុគ្រោះ ប្រាថ្នានូវប្រយោជន៍ដល់ភិក្ខុនោះ ចង់ធ្វើភិក្ខុនោះឱ្យសង្វេគ ទើបចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ហើយ ក៏ពោលគាថានឹងភិក្ខុនោះថា :

លោកហិតផ្កា ដែលកើតក្នុងទឹកនុ៎ះ ដែលគេមិនបានឱ្យបពិត្រលោកអ្នកនិរទុក្ខ ការហិតនុ៎ះ ជាអង្គមួយនៃការលួចលោកឈ្មោះថា ជាអ្នកលួចក្លិន ។

ភិក្ខុនោះតបថា អាត្មាមិនបាននាំទៅ មិនបានកាច់ទេគ្រាន់តែហិតផ្កាដែលកើតក្នុងទឹក អំពីចម្ងាយទេតើ ចុះហេតុ

ដូចម្ដេចបានជាអ្នកនិយាយថា អាត្មាលួចក្លិន ។

**ក្នុងកាលនោះ មានតាបសម្នាក់ចុះជីកគាស់ក្រអៅ-ឈូក កាច់ផ្កាឈូក ភិក្ខុពោលតទៅទៀតថា)**

ចុះបុរសដែលមានអំពើផ្ដេសផ្ដាស ជីកគាស់ក្រអៅឈូក កាច់ផ្កាឈូកយ៉ាងនេះ ហេតុអ្វីក៏អ្នកមិនថាឱ្យបុរសនុះផង ។

ទេវតាតបថា បុរសដែលល្មោភផ្ដេសផ្ដាស ជាអ្នកប្រឡាក់ដោយកិលេសហួសកំណត់ ពាក្យរបស់ខ្ញុំមិនមានក្នុងបុរសនោះទេ ខ្ញុំគួរនិយាយតែនឹងលោកម្នាក់ ព្រោះបុគ្គលដែលឥតមានទីទួល ពោលគឺកិលេសជាអ្នកស្វែងរកសេចក្ដីស្អាត អស់កាលជានិច្ច សូម្បីមានបាបប៉ុនចុងសក់ ក៏ប្រាកដដូចជាប៉ុនមេឃ ។

ភិក្ខុនោះតបថា ម្នាលទេវតា អ្នកស្គាល់អាត្មាមែន អ្នកអនុគ្រោះអាត្មាមែន ម្នាលទេវតា កាលណាបើអ្នកឃើ-ញអាត្មាធ្វើដូច្នេះ អ្នកគប្បីនិយាយឱ្យអាត្មាទៀតចុះ ។

ទេវតាតបថា ខ្ញុំមិនបានចិញ្ចឹមលោកទេ មិនមែនគ្រាន់បើជាងលោកទេ លោកគប្បីទៅកាន់សុគតិដោយកម្មណា បពិត្រភិក្ខុ លោកត្រូវដឹងកម្មនោះដោយខ្លួនលោកចុះ ។

គ្រានោះឯង ភិក្ខុនោះ លុះទេវតានោះ ធ្វើឱ្យសង្វេគហើយ ក៏ដល់នូវសេចក្ដីសង្វេគ ។

**ចប់បទុមបុប្ផសូត្រ**

ᨁបុគ្គលត្រូវតែមានស្មារតី ដឹងនូវទោសកំហុសរបស់ខ្លួនឯង ទោះបីធំឬតូច ហើយប្រញាប់លះបង់ចោល ឬខំព្យាយាមកែលម្អ ព្រោះថា អ្នកដទៃមិនងាយបានដឹងរឿងរ៉ាវសព្វគ្រប់របស់យើងទេ ជួនកាលបានដឹងដែរ ប៉ុន្តែ មិនហ៊ានប្រាប់ជួនកាលទៀតនោះ ថែមទាំងពោលសរសើរនូវទោសកំហុសរបស់យើងទៀតផង ។

ᨁការមាននូវលោភៈ ជាប់ជំពាក់ក្នុងរូប សំលេង ក្លិន រស ផោដ្ឋព្វ បុគ្គលក្នុងលោកកម្របានឃើញតាមពិតថាជាទោស ថាជាបាបអកុសលដែលគួរខ្លាច ព្រោះមិនមានការអប់រំនូវសតិ ឬដោយការវង្វេងភ្លេចសតិ តាមពិតលោភៈនេះ វានាំមកនូវបញ្ហាកង្វល់ក្នុងបច្ចុប្បន្នផង វាជាអរិយសច្ចៈទី២ គឺហេតុដែលនាំឱ្យកើតទុក្ខក្នុងវដ្តៈផង ។

ᨁសព្វបើគ្រាន់តែហិតក្លិនផ្កា ក៏គង់ទេវតាពោល ទោស ហើយប្រាប់ថា បុគ្គលអ្នកស្វែងរកសេចក្តីស្អាត អស់កាលជានិច្ច សូម្បីមានបាបប៉ុនចុងសក់ ក៏ប្រាកដដូចជាប៉ុនមេឃ ចុះបើខ្ញុំឯណេះវិញ មានបាបប៉ុនមេឃ ឃើញប៉ុនចុងសក់ ជួនកាលស្រវាំងភ្នែក ខ្ញុំរកមើលមិនឃើញផង តើវាយ៉ាងម៉េចទៅខ្ញុំហ្នឹង បើបាបច្រើនម្លឹង១ សណ្តោងយកទៅស្ថានសួគ៌រួចដែរឬអត់ ឬក៏ត្រូវទប់ខ្លួនមិនជាប់ ដោយសារបាបធ្ងន់ពេកវាទាញទៅក្រោមទេដឹង **(ខ្ញុំ=ខ្ញុំតណ្ហា)** ។

ᨁការមើលឃើញបាបល្អិត១តូច១ដោយសារកម្លាំងរបស់សតិប្បដ្ឋាន ការដឹងទោសថាជាទោសពិត សូម្បីតូច ល្អិតដោយសេចក្តីមិនប្រមាទ ប្រៀបបីដូចរាជបុរសចាប់ចោរបាន។

ᨁសតិប្បដ្ឋានជាផ្លូវតែមួយគត់ នាំទៅរកការត្រាស់ដឹង និង ការរួចផុតចាកទុក្ខទាំងពួង ។

ᨁយើងតែងឃាត់អ្នកដទៃ មិនឱ្យថេីបផ្កា ព្រោះថាសំរាប់ថ្វាយព្រះ ឬផ្កានៅនឹងដេីម ដោយអាងថា សំរាប់ថ្វាយទេវតា ប៉ុន្តែទេវតាចង្អុលបង្ហាញទោសនៃការហិតក្លិនផ្កាឈូកដល់ភិក្ខុ ព្រោះឃើញដល់លោភៈ ជាទុក្ខសមុទយៈ

គឺហេតុនាំឱ្យកើតទុក្ខ ជាការរំលឹកដាស់តឿនឱ្យមានសតិថ្នាក់សតិប្បដ្ឋាន ។

αក្នុងលោកនេះបើមិនមានបុគ្គលអ្នកត្រាស់ដឹងសច្ច-ធម៌ទេនោះ តើអ្នកណាអាចសំដែងប្រាប់បានថា លោភៈជាហេតុនាំឱ្យកើតទុក្ខ មានជាតិទុក្ខជាដើម ។

αមិនចំពោះតែការហិតក្លិនផ្កាឈូកប៉ុណ្ណោះទេ ឱ្យតែតណ្ហាកើតឡើង ឈ្មោះថាជាចោរដោយបរមត្ថ ព្រោះអ្វីៗក្នុងលោក សុទ្ធតែមិនទៀង ជាទុក្ខ ជាផលរបស់ហេតុ មិនមែនរបស់ខ្លួន ប៉ុន្តែតណ្ហាតែងតែប្រកាន់ថា នុះជារបស់យើង នេះឯងឈ្មោះថាចោរដោយបរមត្ថ ត្រូវទទួលទារុណកម្មដោយកងទុក្ខ ១២កង ជាប់ក្នុងទ្រុងមច្ចុរាជ ។

## គួរពិចារណាអំពីអកុសលធម៌

គ្រប់គ្នាស្គាល់ឈ្មោះអកុសល គឺធម៌ដែលមិនមែនកុសល មិនត្រូវការអកុសល តែក៏ធ្លាក់នូវក្នុងអំណាចរបស់អកុសល ព្រោះអកុសលស្ថិតនៅជាមួយចិត្តសន្តាន អស់កាលជាអង្វែងមកហើយ ។

សត្វទាំងឡាយបានដល់នូវសេចក្តីទុក្ខកន្លងមកហើយក្តី កំពុងតែមានទុក្ខក្នុងបច្ចុប្បន្ននេះក្តី ត្រូវបានទទួលទុក្ខក្នុងកាលខាងមុខទៀតក្តី ក៏ព្រោះតែអកុសល ។

ដរាបណាដែលសត្វទាំងឡាយ នៅមិនឃើញទោសរបស់អកុសល សត្វទាំងឡាយរមែងតែងតែធ្លាក់ចុះក្នុងអន្លង់នៃសេចក្តីទុក្ខ ព្រោះតែអកុសល ដរាបនោះដែរ ។

ដោយហេតុនេះឯង រឿងរបស់អកុសលទើបជារឿងដែលគួរសិក្សា និង ពិចារណាយ៉ាងពិតប្រាកដ ព្រោះថា អកុ-សលនោះ មានទាំងគ្រោតគ្រាត ធ្វើទុច្ចរិតតាមផ្លូវកាយ តាមផ្លូវវាចាជាដើម មានទាំងកណ្តាលៗដោយការពេញចិត្ត ក្នុងវត្ថុកាម ការថ្នាំងថ្នាក់អាក់អន់ចិត្ត ការច្រណែនជាដើម ដែលអាចមានអកុសលកណ្តាល និង គ្រោតគ្រាតទៅបាន ក៏ព្រោះមានអកុសលប្រភេទម្យ៉ាងទៀតគឺ អនុស័យកិលេស ដែលជាអកុសលថ្នាក់ល្អិត ជាប់តគ្នាក្នុងសន្តានចិត្ត រហូតទល់គ្នានិងខណៈនៃអរិយមគ្គកើតឡើង ទើបបានរលត់អស់ដាច់ផុតអំពីសន្តាន ។

បើព្រះដ៏មានព្រះភាគមិនបានត្រាស់ដឹងក្នុងលោកទេ យើងមិនអាចបានដឹងឡើយថា មានអកុសលថ្នាក់ល្អិតៗ ដែលត្រូវលះបង់ដោយការចំរើនសតិប្បដ្ឋានវិបស្សនា ហើយសត្វទាំងឡាយទាំងពួង ក៏ពុំអាចរួចផុតចាកទុក្ខក្នុងវដ្តសង្សារបានឡើយ ។

ព្រោះអាស្រ័យពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះ-សម្មាសម្ពុទ្ធជាម្ចាស់ យើងទើបបានដឹងថា អកុសលថ្នាក់ល្អិតៗ នោះ មានពិតប្រាកដ ហើយចាំបាច់ត្រូវកំចាត់បង់ទៀតផង ទើបបានអស់ទុក្ខទាំងពួង ។

រឿងរបស់ **លោភ** ជារឿងនៃអកុសលពិតៗ សភាពរបស់លោភៈ គឺសេចក្តីប្រាថ្នា ការចង់បាន សេចក្តីត្រូវការ សេចក្តីត្រេកអរ ការពេញចិត្ត ការជាប់ជំពាក់ចិត្ត គឺជាសភាវធម៌ពិតមួយបែប ជាបរមត្ថធម៌ មិនមែនសត្វ ។

តណ្ហា គឺលោភចេតសិក ត្រេកអរប្រាថ្នាក្នុងរូបារម្មណ៍ ក្នុងសំលេង ក្នុងក្លិន រស ផោដ្ឋព្វ និង ក្នុងធម្មារម្មណ៍ **ស្ទឹងស្មើដោយតណ្ហាមិនមាន** ដោយសេចក្តីថា ស្ទឹងនោះសូម្បីធំប៉ុណ្ណាក៏ដោយ ក៏មិនស្មើស្ទឹងតណ្ហាដែរ តណ្ហាហូរទៅរកអារម្មណ៍ក្នុងលោក មានសន្ទុះលឿនរហ័សខ្លាំងក្លា ហូររហូតក្នុងវដ្តសង្សារ ហូរកាត់តាមកាមភព ឋានមនុស្ស ឋានទេវតា ហូរធ្លាយដល់ព្រហ្មលោក ព្រហ្មមានរូប ព្រហ្មអត់រូប ហូរក្នុងសន្តានរបស់បុថុជ្ជនឆ្លងកាត់សោតាបត្តិមគ្គ សកទាគាមិមគ្គ ជ្រាបតាមទំនប់អនាគាមិមគ្គ ទាល់តែដល់អរហត្តមគ្គ ទើបបានរីងស្ងួតអស់ទៅពុំមានសល់ ។

សេចក្តីប្រាថ្នា មិនអាចនឹងធ្វើឱ្យពេញបានឡើយ ត្រូវការរបស់នេះហើយ រមែងត្រូវការរបស់នោះទៀតជានិច្ចរឿយៗ រហូតសង្សារវដ្ត ព្រោះដូច្នោះ សេចក្តីប្រាថ្នា សេចក្តីត្រូវការរបស់សត្វទាំងឡាយ ទើបធំជាងមហាសមុទ្រ មិនចេះរីង មិនចេះស្រក ទៅដោយភ្លើងឆេះកប្បឡើយ មានតែភ្លើងអរហត្តមគ្គប៉ុណ្ណោះ ដែលអាចដុតតណ្ហាឱ្យឆេះអស់បាន ។

តណ្ហាជាតួហេតុនាំឱ្យកើតទុក្ខ ដូចដែលទ្រង់ត្រាស់តបនឹងសំនួររបស់ទេវតាដែលទូលសួរថា **លោកមានអ្វីឃ្នាំ**

**ជាគ្រឿងចងទុក** ព្រះដ៏មានព្រះភាគត្រាស់តបថា **លោកមានសេចក្តីត្រេកត្រអាលជាគ្រឿងចងទុក** (នន្ទិ សម្ពន្ធនោ លោកោ) សេចក្តីរីករាយភ្លើតភ្លើននេះ ក៏ជាឈ្មោះលោភៈ ជាទុក្ខសមុទយៈហ្នឹងឯង ជាចំណងដ៏មាំបំផុតដែលជាគ្រឿងចងរបស់មច្ចុរាជ បើមិនមានកាំបិតអរហត្តមគ្គទេនោះ ពុំអាចកាត់នូវចំណងអត់រូបនេះបានឡើយ ។

## ៧-សម្បជិយា ធម្មា

ពួកធម៌គួរដល់ការប៉ះខ្ទប់ បានដល់បសាទរូប៥ និងគោចររូប៧ គឺជារូបគ្រោតគ្រាតសរុបទៅមាន ១២រូប ។

-ចក្ខុវិញ្ញាណកើតឡើងព្រោះចក្ខុប៉ះខ្ទប់នឹងរូបារម្មណ៍។

-សោតវិញ្ញាណកើតឡើង ព្រោះសោតៈប៉ះខ្ទប់នឹងសទ្ទារម្មណ៍ ។

-ឃានវិញ្ញាណកើតឡើង ព្រោះឃានៈប៉ះខ្ទប់នឹងគន្ធារម្មណ៍ ។

-ជិវ្ហាវិញ្ញាណកើតឡើង ព្រោះជិវ្ហាប៉ះខ្ទប់នឹងរសារម្មណ៍ ។

-កាយវិញ្ញាណកើតឡើង ព្រោះកាយប៉ះខ្ទប់នឹងផោដ្ឋព្វារម្មណ៍ ៖

៙ការប៉ះខ្ទប់នេះអាស្រ័យដោយសារមានបសាទរូប ៥ គឺៈ ចក្ខុបសាទ១ សោតបសាទ១ ឃានបសាទ១ ជិវ្ហាបសាទ១ និង កាយបសាទ ១ ។

αមិនអាចឃើញចក្ខុគឺភ្នែកមិនទៀងបានទេ បើមិនសិក្សាសង្កេតពិនិត្យរឿយៗ ក្នុងពេលដែលកំពុងប៉ះខ្ទប់នឹងរូបារម្មណ៍ ព្រោះភ្នែកពុំមែនជារូបអាចមើលឃើញបានទេ ប៉ុន្តែជាសភាវធម៌ម្យ៉ាង ដែលអាចប៉ះខ្ទប់នឹងវណ្ណរូប គឺរូបារម្មណ៍បាន រួចហើយក៏កន្លងផុតទៅជាអតីតធម៌ ។

α អ្វីទៅដែលជាត្រចៀក ?

គឺសភាវធម៌ម្យ៉ាងដែលប៉ះខ្ទប់នឹងសំលេង រួចក៏រលត់បាត់ទៅវិញភ្លាម សោតបសាទរូបមិនទៀង មិនមែនជាសត្វបុគ្គល ។

ការឮ គឺសោតវិញ្ញាណ មិនមែនជាត្រចៀក មិនមែនជាសំលេង ប៉ុន្តែសភាវធម៌ទាំងបីមានជាប្រក្រតីធម្មតា ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងនូវសភាវធម៌ប្រក្រតីធម្មតា ឱ្យជាទីតាំងនៃការបដិបត្តិរំលត់តណ្ហា មានះ ទិដ្ឋិ សភាវធម៌ជាប្រក្រតីធម្មតាៗក្នុងជីវិតប្រក្រតីប្រចាំថ្ងៃ ព្រះសាស្តាទ្រង់ត្រាស់ក្នុងមហាសតិប្បដ្ឋានសូត្រ សភាវធម៌នៅក្នុងមហាសតិប្បដ្ឋានសូត្រ ជាសភាវធម្មតា ដែលគ្រប់គ្នាតែងមាន ទាំងមនុស្ស ទាំងទេវតា ទាំងព្រះឥន្ទ្រ ទាំងព្រះព្រហ្ម ទាំងការសិក្សារលឹកពិចារណាទៀតសោត ក៏សិក្សាចំពោះតែសភាវធម៌ណា ដែលកើតឡើងកំពុងប្រាកដ សេចក្តីសំខាន់គឺសតិបញ្ញា ត្រង់ធម៌ដែលជាអារម្មណ៍អ្វីក៏ ដោយជាកុសល ឬជាអកុសល ឬជាអព្យាកតៈ ដោយពុំចាំបាច់ស្វែងរកក្នុងទីណាៗដទៃអំពីប្រក្រតីពិតៗនៃជីវិត ឡើយ ។

αចិត្តកើតឡើងដឹងនូវអារម្មណ៍ណា ក៏ព្រាត់ចាកនូវអារម្មណ៍នោះ ដោយឥតបានយកអារម្មណ៍ក្នុងលោកទៅជាមួយឡើយ ។

## សំយុត្តនិកាយ សឡាយតនវគ្គ អនិច្ចវគ្គទី១

ម្នាលភិក្ខុទាំងឡាយ រូបទាំងឡាយមិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះបុគ្គលត្រូវយល់ដោយដោយប្រាជ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់

អញ នុះមិនមែនជាអញ នុះមិនមែនជាខ្លួនរបស់អញទេ ។

αព្រះអង្គទ្រង់ត្រាស់សំដែងនូវរូបារម្មណ៍ ជាអារម្មណ៍របស់សតិ-វិបស្សនា ដោយសេចក្តីថា បុគ្គលរស់នៅប្រក្រតីធម្មតា ធ្វើកិច្ចការងារធម្មតាៗរបស់បព្វជិត ឬគ្រហស្ថ ប៉ុន្តែមានការមិនប្រមាទ គឺមិនប្រហែសធ្វេស មិនស្មិទ្ធស្នាល ដោយការប្រកាន់មាំ សតិរលឹកសិក្សានូវសភាវធម៌ដែលកំពុងប្រាកដ រូបារម្មណ៍គ្រាន់តែជាសភាវធម៌ម្យ៉ាងដែលចក្ខុវិញ្ញាណបានឃើញប៉ុណ្ណោះ ជាសភាវធម៌មិនទៀង មិនមានអ្វីសំខាន់ក្នុងរូបារម្មណ៍ឡើយ ។

សំលេង ក្លិន រស ផោដ្ឋព្វៈ និង ធម្មារម្មណ៍ ទាំងឡាយ មិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខរបស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះ បុគ្គលត្រូវយល់ដោយប្រាជ្ញាដ៏ប្រពៃ តាមពិតយ៉ាងនេះថា នុះមិនមែនរបស់អញ នុះមិនមែនជាអញ នុះមិនមែនជាខ្លួនរបស់អញទេ ។

ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័កជាអ្នកចេះដឹងឃើញយ៉ាងនេះ ក៏នឿយណាយនឹងរូបទាំងឡាយផង នឿយណាយនឹងសំលេងទាំងឡាយផង នឿយណាយនឹង ក្លិន រស ផោដ្ឋព្វ ធម្មារម្មណ៍ទាំងឡាយផង កាលបើនឿយណាយរមែងប្រាសចាកតម្រេក ព្រោះប្រាសចាក តម្រេកចិត្តក៏ផុតស្រឡះចាកអាសវៈ ។

កាលបើចិត្តផុតស្រឡះចាកអាសវៈហើយ ញាណក៏កើតឡើងថា ចិត្តផុតស្រឡះហើយ អរិយសាវ័កនោះក៏ដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយ អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចអាត្មាអញក៏បានធ្វើរួចហើយ មគ្គភាវនាដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

αជីវិតធម្មតាៗ មានសភាវធម៌យ៉ាងណាៗ សុទ្ធតែជាសតិប្បដ្ឋានទាំងអស់ ។

αជីវិតសត្វលោករស់នៅសព្វថ្ងៃ អាស្រ័យមានចិត្តវិបស្សនាឃើញចិត្តក្នុងបច្ចុប្បន្ន កើតឡើងហើយក៏រលត់ទៅវិញ ទើបមិនប្រកាន់ចិត្តថាជាសត្វ បុគ្គលតួខ្លួនឡើយ សម

ដូចព្រះពុទ្ធតម្រាស់ត្រាស់ក្នុងសឡាយតនវគ្គថា ម្នាលភិក្ខុទាំងឡាយ ចិត្តជាអតីតៈ និង ចិត្តជាអនាគត ជាអនត្តាទៅហើយ ចាំបាច់និយាយថ្វីចំពោះចិត្តជាបច្ចុប្បន្ន ។

ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័កជាអ្នកចេះដឹង ឃើញយ៉ាងនេះ ជាអ្នកមិនអាឡោះអាល័យចំពោះចិត្តជាអតីតៈ មិនត្រេកអរចំពោះចិត្តជាអនាគត ជាអ្នកប្រតិបត្តិដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរំលត់នូវចិត្តជាបច្ចុប្បន្ន ។

αពាក្យថារំលត់ចិត្តជាបច្ចុប្បន្ន គឺរំលត់សេចក្តីប្រកាន់មាំ រំលត់ឆន្ទរាគៈក្នុងចិត្តដែលកំពុងប្រាកដ ។

αចិត្តជាបច្ចុប្បន្ននេះ មុននឹងកើតឡើងក៏មិនមានតាំងនៅក្នុងទីណា កាលដែលបែកធ្លាយទៅ កន្លងទៅ ក៏មិនទៅតាំងនៅក្នុងទីណាដែរ គួរដែរឬដែលប្រកាន់នូវចិត្តកំពុងប្រាកដថាជាយើង ថាជាខ្លួនរបស់យើង ។

# សំយុត្តនិកាយ សឡាយតនវគ្គ
# បឋមបណ្ណាសកៈ

## *(១)_ ខ្ញុំបានស្តាប់មកយ៉ាងនេះ ។*

សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភ្នែកមិនទៀង (ប៉ះខ្ទប់នឹងវណ្ណរូបរួចហើយ ក៏កន្លងទៅ បែកធ្លាយ ពុំតាំងនៅ) របស់ណាមិនទៀង របស់នោះជាទុក្ខ (ទ្រាំតាំងនៅដដែលមិនបាន) របស់ណាជាទុក្ខ របស់នោះជាអនត្តា (ពុំស្តាប់បង្គាប់ ឬ ហាមឃាត់មិនបាន) របស់ណាជាអនត្តា របស់នោះបុគ្គលត្រូវយល់ដោយប្រាជ្ញាដ៏ប្រពៃ តាមពិតយ៉ាងនេះថា **នេតំ មម** នុ៎ះមិនមែនរបស់អញ **នេ សោហ–**

**មស្តិ** នុះមិនមែនជាអញ **នមេសោអត្តាតិ** នុះមិនមែនជាខ្លួនរបស់អញឡើយ ។ ត្រចៀកមិនទៀង (ប៉ះខ្ទប់នឹងសំលេងរួចហើយ ក៏កន្លងទៅ បែកធ្លាយពុំតាំងនៅ) ។ ច្រមុះមិនទៀង ។ អណ្តាតមិនទៀង ។ កាយមិន ទៀង ។

៤ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ គឺជា សភាវៈមានលក្ខណៈនៅត្រង់ប៉ះខ្ទប់ នឹងសភាវៈដែលជាគូនឹងគ្នា គឺភ្នែកប៉ះនឹងរូប ត្រចៀកប៉ះនឹងសំលេង ច្រមុះប៉ះនឹងក្លិន អណ្តាតប៉ះនឹងរស កាយប៉ះនឹងផោដ្ឋព្វៈ **ការប៉ះខ្ទប់ហ្នឹងតែម្តងជាគូសភាវធម៌ ប៉ះហើយកន្លងទៅគឺកើតរលត់ ៗ**

ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ គឺជាសភាវធម៌យ៉ាងសាមញ្ញធម្មតា មាននៅក្នុងជីវិតប្រចាំថ្ងៃគ្រប់ៗគ្នា **គឺជាទីតាំងនៃការចារកំពូល គឺ អប់រំចំរើនវិបស្សនា** មិនមែនគ្រាន់តែពិចារណាថាភ្នែកមិនទៀង ត្រចៀកមិនទៀង ជាដើមនោះទេ តែសិក្សាពិនិត្យចំពោះលក្ខណៈនៃការប៉ះខ្ទប់រឿយៗ រហូតទាល់តែលក្ខណៈនៃបរមត្ថធម៌ដែលជាភ្នែក ឬ ត្រចៀក ច្រមុះ អណ្តាត កាយ ប្រាកដច្បាស់ដល់សតិវិបស្សនា ។

ចិត្តមិនទៀង (មានហើយរលត់បាត់ទៅវិញ ចិត្តដទៃកើតបន្ត ដូចនេះរហូត) របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះបុគ្គលត្រូវយល់ដោយប្រាជ្ញាដ៏ប្រពៃ តាមពិតយ៉ាងនេះថា នុះមិនមែនរបស់អញ (ព្រោះមិនទៀង មានតែការអស់ទៅប៉ុណ្ណោះ) នុះមិនមែនជាអញ (ព្រោះជាទុក្ខ ជាបរ-មត្ថធម៌បែកធ្លាយ) នុះមិនមែនជាខ្លួនរបស់អញឡើយ(ព្រោះជាអនត្តា សភាវធម៌ដែលកើតអំពីបច្ច័យ មិនមានអំណាចខ្លួនឯង អស់ទៅ សូន្យទៅ រកខ្លួន ឯងមិនមាន) ។

៤សភាវធម៌គ្រប់យ៉ាងដែលកើតឡើងហើយ ដែលមានបច្ច័យតាក់តែងហើយ រកតែខ្លួនឯងមិនមានផង កាលដែលបែកធ្លាយ រលត់ អស់ទៅ សូន្យទៅ ពុំមានអ្វីនៅសល់ឡើយ ចាំបាច់និយាយថ្វីថា មានសត្វ ។

ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័ក ជាអ្នកចេះដឹងឃើញយ៉ាងនេះ ក៏នឿយណាយនឹងភ្នែកផង នឿយណាយនឹងត្រចៀកផង នឿយណាយនឹងច្រមុះផង នឿយណាយនឹងអណ្តាតផង នឿយណាយនឹងកាយផង នឿយណាយនឹងចិត្តផង កាលបើនឿយណាយ រមែងប្រាសចាកតម្រេក ព្រោះតែប្រាសចាកតម្រេកចិត្តក៏ផុតស្រឡះចាក អាសវៈ ។

α ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងអំពីចិត្តធម្មតា១ ថាមិនទៀងជាទុក្ខ និង ជាអនត្តា **បើបញ្ញាបានដឹងចិត្តធម្មតា១ថាមិនមែនជាសត្វ បុគ្គល តួខ្លួន ហើយ គួរបើដែរឬដែលនៅតាក់តែងនូវចិត្តដទៃដើម្បីឱ្យបានជាអារម្មណ៍របស់វិបស្សនា១**

ព្រះអរិយសាវ័ក មានការចំរើននូវសមាធិ ដំកល់ចិត្តនឹងស្ងប់ គឺជាវិហារធម៌របស់លោកតែប៉ុណ្ណោះ ដូចជា ពុទ្ធានុស្សតិ ធម្មានុស្សតិ សង្ឃានុស្សតិ សីលានុស្សតិ ចាគា នុស្សតិ ទេវានុស្សតិ ឧបសមានុស្សតិជាដើម គឺលោកមិនមែនចំរើនចិត្តស្ងប់ដើម្បីឱ្យជាអារម្មណ៍របស់វិបស្សនាឡើយ ប៉ុន្តែបើចិត្តស្ងប់នោះកើតឡើង ក៏មិនអាចហាមសតិកុំឱ្យរលឹកដឹងនូវចិត្តស្ងប់នោះដែរ ព្រោះនេះជាប្រក្រតីនៃការ មានសតិរលឹកសិក្សាជាទូទៅគ្រប់តែសភាវធម៌ ដោយមិនរើសឬចោះចំពោះតែម្យ៉ាង១ទេ ។

α**ក្នុងមហាសតិប្បដ្ឋានសូត្រ ព្រះភគវាពុំបានសំដែងថា ត្រូវសាងអ្វីមួយដើម្បីឱ្យបានជាអារម្មណ៍របស់សតិទេ តែទ្រង់ត្រាស់ថាដឹងច្បាស់នូវធម៌ ដែលកើត ដែលរលត់ជាប្រក្រតី គ្រប់ឥរិយាបថទាំងបួន ។**

αនៅក្នុងចិត្តានុបស្សនាសតិប្បដ្ឋាន ព្រះអង្គត្រាស់ថា ទោះចិត្តប្រកបដោយរាគៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ទោះចិត្តប្រកបដោយទោសៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយទោសៈ ទោះចិត្តប្រកបដោយមោហៈ ក៏ ដឹងច្បាស់ថា ចិត្តប្រកបដាយមោហៈ **(តើចាំបាច់រៀបចំម្ទូរចំចាំ**

**ឬខំប្រឹងធ្វើចិត្តដូចនេះ ដើម្បីឱ្យជាអារម្មណ៍របស់សតិវិបស្សនាដែរឬទេ?)** ។

αទោះចិត្តប្រាសចាក រាគៈ ទោសៈ មោហៈ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាករាគៈ ទោសៈ មោហៈ ។ ចិត្តទាំងអស់នេះគ្រប់គ្នាតែងមាន ធម្មតាៗដូចជា ចិត្តឃើញ ចិត្តឮ ចិត្តដឹងក្លិន ចិត្តដឹងរស ចិត្តដឹងផោដ្ឋព្វ ចិត្តជាកុសលថ្នាក់ទាន ចិត្តជាកុសលថ្នាក់សីល ចិត្តជាកុសលថ្នាក់ភាវនា ។ល។

សរុបមកទោះជាបុគ្គលម្នាក់ៗ កំពុងមានចិត្តអ្វីកើតឡើងក៏ដោយ ចិត្តនោះឯងហើយដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា មិនទៀង ជាទុក្ខ និង ជាអនត្តា សតិរលឹកដឹងទាន់នូវចិត្តនោះៗ ក៏មិនប្រកាន់ដោយតណ្ហាថា នុះជារបស់យើង មិនប្រកាន់ដោយមានៈថា នុះជាយើង មិនប្រកាន់ដោយទិដ្ឋិថា នុះជាខ្លួនរបស់យើងឡើយ ការបដិបត្តិយ៉ាងនេះរឿយៗឈ្មោះថាមានប្រក្រតីចំរើននូវសតិប្បដ្ឋាន ។

α គោចររូប ៧ ដែលគួរដល់ការប៉ះខ្ទប់នឹងបសាទរូប **សម្បដិឃធម្មា** បានដល់ រូប សំលេង ក្លិន រស ផោដ្ឋព្វៈ (ដី ភ្លើង ខ្យល់ គឺផោដ្ឋព្វៈ) មានតួនាទីត្រឹមតែជាអារម្មណ៍របស់វិញ្ញាណតាមទ្វារនីមួយៗតែប៉ុណ្ណោះ ប៉ុន្តែទោះជាវិញ្ញាណដឹងយ៉ាងម៉េចក៏ដោយ ក៏វិញ្ញាណពុំអាចចាប់យកអារម្មណ៍ទាំងនោះមកជារបស់ខ្លួនបានឡើយ ថែមទាំងវិញ្ញាណខ្លួនឯងហ្នឹងត្រូវស្លាប់បាត់ទៅយ៉ាងឆាប់ទៀតផងគឺ **ខណិកមរណៈ** ។

αអារម្មណ៍ក្នុងលោក មិនអាចបានទៅជារបស់កម្មសិទ្ធិនៃអ្នកណាៗឡើយ ពីព្រោះសត្វលោកដែលអាចដឹងអ្វីៗបានក៏ព្រោះតែមានវិញ្ញាណជាធាតុដឹងប៉ុណ្ណោះ ហើយវិញ្ញាណក៏គ្មាននូវសមត្ថភាពអ្វី ដើម្បីចាប់យករបស់ក្នុងលោកឡើយ មិនទាំងមានសមត្ថភាពការពារខ្លួនឯងកុំឱ្យសូន្យទៅវិញផង ។

αអារម្មណ៍ក្នុងលោកប្រៀបបីដូចជាវត្ថុអ្វីមួយដែលគេបានឃើញនៅក្នុងពេលយល់សប្តិ **ដោយសេចក្តីថា មិនអាចយកបាន** ឬប្រៀបបីដូចជារូបថតនៃអ្នកស្លាប់បាត់ហើយ គឺគ្រាន់តែជាស្រមោលប៉ុណ្ណោះ ។

## ៨-អប្បដិយា ធម្មា

ពួកធមិ មិនគួរដល់ការប៉ះខ្ទប់បានដល់បរមត្ថធមិទាំងឡាយក្រៅអំពី ឱឡារិករូប ១២ ចេញ គឺសុខុមរូប ១៦ ចិត្ត ១២១ ចេតសិក ៥២ និព្វាន ។

αបុគ្គលមិនអាចបានអ្វីៗមកជារបស់ខ្លួនដោយពិតនោះទេ ព្រោះដែលដឹងថា អ្វីៗជារបស់យើង ក៏គឺការកើតឡើងនៃតណ្ហា ដែលប្រកាន់ថា **ឯតំ មម** នុះជារបស់យើង ដូច្នេះនៅពេលដែលគិតថា យើងមាននូវរបស់នេះ ឬយើងបាននូវរបស់នោះ តាមពិតគឺកំពុងតែបាននូវរបស់ដ៏អាក្រក់មួយក្រៃលែងជាងអ្វីៗទាំងអស់ បានដល់តណ្ហា បើមិនបាននូវតណ្ហាទេនោះ តើបានអ្វីមកប្រកាន់ថា នុះជារបស់យើងរាល់ៗថ្ងៃនេះ ។

αកាលបើ **អមតធមិ** មានប្រយោជន៏អ្វីដោយរបស់ក្តៅផ្សា ៥យ៉ាងដែលគប្បីបរិភោគលេបចូលនោះ ត្បិតតម្រេកក្នុងកាមទាំងឡាយ ក្តៅផ្សាក្រៃពេក គឺក្តៅផ្សាដោយការស្វែងរក១ ក្តៅផ្សាដោយការហួងហែង១ ក្តៅផ្សាដោយការរក្សាទូទៅ១ ក្តៅផ្សាដោយការបរិភោគលៃលកបែងចែក១ ក្តៅផ្សាដោយផលវិបាកនៃការបរិភោគកាមគុណ ១ ។

αកាលបើនេក្ខម្មៈជាធមិដែលមិនមានសត្រូវ មាន តើប្រយោជន៏អ្វី ដោយកាមទាំងឡាយ ដែលមានសត្រូវច្រើន ព្រោះថាបុគ្គលណានៅរួមរស់ជាមួយវត្ថុកាម កិលេសកាម បុគ្គលនោះរមែងមានសត្រូវចោមរោម ធ្វើនូវសេចក្តីអន្តរាយទាំងខាងក្រៅ ទាំងខាងក្នុង គឺកិលេសជាសត្រូវខាងក្នុង ចោរលួចចោរប្លន់ ភ្លើងឆេះ ទឹកលិចជាដើម ជាសត្រូវខាងក្រៅ ។

αកាលបើព្រះនិព្វានមាន តើមានប្រយោជន៏អ្វី ដោយកាមទាំងឡាយ ដែលជាគ្រឿងសម្លាប់ ជាគ្រឿងចង ព្រោះថាសត្វលោកត្រូវស្លាប់ដោយសារបរិភោគកាមគុណ ដូចគេបរិភោគថ្នាំពិស ទោះជាការសម្លាប់ខ្លួនឯងក្តី ត្រូវអ្នកដទៃសម្លាប់ក្តី ស្លាប់ក្នុងជាតិមុនក្តី ជាតិនេះក្តី ជាតិក្រោយក្តី ឬទោះបីស្លាប់ដោយប្រការណាៗក្តី សុទ្ធតែព្រោះកាមជា

ហេតុទាំងអស់ ព្រោះកាមជាទុក្ខសមុទយៈ គឺហេតុដែលនាំឱ្យកើតទុក្ខ ម្យ៉ាងទៀតកាមជាចំណងដ៏មាំស្វិត ក្នុងការដែលចងសត្វលោកទុកក្នុងកន្លែងធ្វើទារុណកម្ម ចំណែកព្រះនិព្វាន ជាទីដែលមិនមានការចង មិនមានការសម្លាប់ បរមសុខជានិច្ច មិនមានការបៀតបៀនដោយប្រការណាមួយឡើយ ដូច្នេះ បុគ្គលគួរឃើញទោសរបស់កាម ហើយលះបង់នូវការស្វែងរកកាមចោលចេញ វិលត្រឡប់មកស្វែងរកនូវព្រះនិព្វានវិញ ។

αគប់ស្មៅដែលភ្លើងកំពុងឆេះ តែងឆេះនូវបុគ្គលអ្នកកាន់មិនលែងចេញ ព្រោះថាកាមទាំងឡាយ ប្រៀបដូចជាគប់ភ្លើង តែងឆេះនូវពួកសត្វ ដែលមិនលែងចេញ ។

αសូមកុំលះបង់ នូវសេចក្តីសុខដ៏ធំទូលាយ ព្រោះហេតុតែសុខបន្តិចបន្តួចនៅក្នុងកាមទាំងឡាយឡើយ សូមកុំក្តៅក្រហាយស្តាយក្នុងកាលជាខាងក្រោយ **ដូចត្រីលេបនុយជាមួយផ្លែសន្ទូច** ។

α សូមកុំច្រាស់ច្រាល់ ព្រោះតែកាមទាំងឡាយ ដូចសុនខ ដែលគេចងជាប់នឹងបង្គោល សត្វទាំងឡាយត្រូវកិលេសកាមធ្វើឱ្យមានការស្រេកឃ្លានដោយឥតមានការអៀនខ្មាស់ ដូចក្មេងចណ្ឌាល ។

αបើមនុស្សលោកប្រកបខ្លួននៅក្នុងកាម នឹងរងទុក្ខមិនមានប្រមាណផង រងនូវទោមនស្សក្នុងចិត្តដ៏ច្រើនផង សូមមនុស្សលោក លះបង់កាមទាំងឡាយ ជារបស់មិនទៀងចោលចេញ ។

αកាលបើព្រះនិព្វានជាបរមធម៌ មិនចេះចាស់ មានតើប្រយោជន៍អ្វីដោយកាមទាំងឡាយ ជារបស់ចាស់ កំណើតទាំងអស់ក្នុងភពទាំងពួង សុទ្ធតែត្រូវមរណៈ និង ព្យាធិរឹបជាន់ញាំញី ។

ព្រះនិព្វាននេះមិនចាស់ មិនស្លាប់ មិនមានសោកសៅ មិនមានសត្រូវ មិនចង្អៀត មិនមានកំហុសភ្លាំងភ្លាត់ មិនមានភ័យ មិនក្តៅរោលរាល ព្រោះព្រះនិព្វានផុតចាកនូវបញ្ចក្ខន្ធ ។

អមតនិព្វាននេះ ព្រះអរិយទាំងឡាយ មានព្រះពុទ្ធជាដើម ច្រើនព្រះអង្គណាស់ ដែលបានសំរេចហើយ ដល់ហើយ

មិនតែប៉ុណ្ណោះទេ ព្រះនិព្វាននេះ គេគប្បីបានក្នុងកាលសព្វថ្ងៃនេះ បុគ្គលណាមាននូវសេចក្ដីព្យាយាម ដោយការយកចិត្តទុកដាក់ ចំរើនសតិប្បដ្ឋាន បុគ្គលនោះ រមែងបាននូវព្រះនិព្វាន ប៉ុន្តែបើបុគ្គលមានសេចក្ដីប្រមាទ ធ្វេសប្រហែស រមែងនៅឆ្ងាយអំពីព្រះនិព្វានដោយពិត ។

៙សរីរៈគឺរូបកាយរបស់មនុស្ស ដូចដង្កូវ ជាកាយ ស្អុយ មិនស្អាត មានក្លិនគួរឱ្យខ្លាចលំបាកទ្រាំនេះ ពោលចំពោះដែលនៅរស់ មិនទាន់ស្លាប់ ។ រូបកាយគឺជា ការុងស្បែក ពេញដោយសាកសព និង ពេញដោយរបស់ មិនស្អាត តែងហូរចេញមកសព្វកាល ។ កាយដែលប្រកបដោយមហាភូតរូប៤ នេះ គឺជាខ្ទមឆ្អឹង ដែលឆ្អឹងទាំងប៉ុន្មាន ត្រូវបានចងរឹតទៅដោយសរសៃ បូកលាបដោយសាច់ និង ឈាម ជារបស់គួរខ្ពើមក្រៃពេក ជាលំនៅនៃហ្វូងដង្កូវ ជាចំណីអាហាររបស់សត្វទាំងឡាយផ្សេងៗ បើគេចោលនៅ ក្នុងព្រៃស្មសាន ជាសាកសពហើមប៉ោង រួចហើយបែកធ្លាយ តើមានអ្នកណាព្រមយកនូវសាកសពនេះមករួមនៅក្នុងក្រុមគ្រួសារជាមួយដែរឬទេ ?

៙កាយដែលវិញ្ញាណប្រាសចេញហើយ គេតែងចោល ឬ ដុតនៅក្នុងព្រៃស្មសាន ជាធាតុមិនដឹង ដូចអង្កត់អុស ពួកញាតិមានការខ្ពើមខ្លាច មិនអាចទុកដាក់ឱ្យនៅលើផ្ទះសម្បែងឡើយ ។ មាតាបិតារបស់ខ្លួន ចោលសាកសពនោះ ឱ្យជាចំណីសត្វដទៃក្នុងព្រៃស្មសាន ខ្ពើមរអើម ងូតទឹកលាងខ្លួន ចំណង់បើសាធារណជន នឹងមិនខ្ពើមរអើមដូចម្ដេចកើត ។ សត្វទាំងឡាយតែងជ្រុលជ្រុបក្នុងគ្រោងកាយ ជាសាកសពឥតខ្លឹម-សារ ដែលកម្មបានផ្សំផ្គុំ ដោយឆ្អឹងនឹងសរសៃ ជាកាយស្អុយពេញទៅដោយទឹកមាត់ ទឹកភ្នែក ទឹកសម្បោរ នឹងឧច្ចារៈជាដើម ។ បើបុគ្គលពន្លាត់ នូវរាងកាយនេះ ធ្វើអាការខាងក្នុងនៃកាយឱ្យត្រឡប់មក ជាខាងក្រៅវិញ សូម្បីមាតារបស់ខ្លួន ក៏ខ្ពើមរអើម អត់ទ្រាំនឹងក្លិនពុំបាន ។

៙បណ្ឌិតទាំងឡាយ បានពោលដោយបញ្ញាថា ខន្ធ ធាតុ អាយតនៈ ដែលបច្ច័យតាក់តែង មានជាតិជា ឬសគល់ នាំមកនូវទុក្ខ មិនជាទីពេញចិត្ត តើប្រយោជន៍អ្វីដោយការស្ដី

ដណ្ដឹងរៀបការ ភរិយាស្វាមី ។

αលំពែងបីរយដែលសំលៀងថ្មីៗ គប្បីធ្លាក់ចុះលើកាយរាល់ៗថ្ងៃ ប្រសិនបើការអស់ទៅនៃទុក្ខ គប្បីបានដោយការលំបាកយ៉ាងនេះ គឺលំបាកដោយការត្រូវលំពែងរាល់ថ្ងៃអស់រយឆ្នាំជាការប្រសើរ ព្រោះថា ការដែលមិនបានត្រាស់ដឹងអរិយសច្ចធម៌នៃបុគ្គលម្នាក់ ក៏ជាអ្នកបានទទួលនូវគំនរទុក្ខធំក្នុងសង្សារវដ្ដ ក្រៃលែងជាងការត្រូវដោយលំពែងបីរយក្នុងមួយថ្ងៃអស់មួយរយឆ្នាំទៅទៀត ។

αយើងឮសួរថា ត្រូវលំពែងបីរយក្នុងមួយថ្ងៃ យើងសែនតក់ស្លុតភ័យខ្លាច ប៉ុន្តែតាមពិត ការមិនត្រាស់ដឹងអរិយ-សច្ចៈ ការនៅក្នុងសេចក្ដីប្រកាន់បញ្ចក្ខន្ធដោយសក្កាយទិដ្ឋិលើសក្រៃលែងជាងការត្រូវដោយលំពែងបីរយក្នុងមួយថ្ងៃៗអស់រយនៃឆ្នាំទៅទៀត ដូច្នេះ បញ្ចក្ខន្ធជាអាវុធដ៏សាហាវក្រៃលែង ក្នុងការបៀតបៀនសត្វលោក ។

αបុគ្គលណាដឹងព្រះតម្រាស់របស់ព្រះសាស្ដា ដែលសំដែងដល់សង្សារវដ្ដ មិនមានទីបំផុតខាងដើម និង ទីបំផុតខាងចុង បុគ្គលណាក៏ពុំអាចដឹងបានដែរនូវទីបំផុត នៃសង្សារ-វដ្ដ ដែលពោរពេញទៅដោយទុក្ខ មានទុក្ខដែលកើតអំពីការកាប់សម្លាប់ជាដើម ព្រោះមានជាតិជាឫសគល់ បុគ្គលដែលបានដឹងយ៉ាងនេះ នោះ គប្បីព្រមទទួលនូវទុក្ខលំបាកដោយការឈឺចាប់ក្នុងការចាក់ទៅដោយលំពែង ដូចដែលបានពោលហើយចុះ បើសិនជាទុក្ខក្នុងវដ្ដ នឹងគប្បីអស់ទៅដោយវិធីយ៉ាងនេះ ។

## ៩-រូបិនោ ធម្មា

### ពួកធម៌ជារូប បានដល់រូបបរមត្ថ ២៨

αរូបនេះជាសភាវៈចាស់ជរាគ្រាំគ្រា រូបជាសំបុកនៃរោគ ។ ការកើតឡើងនៃរូប គឺជាការកើតឡើងនៃរោគទាំងឡាយ ការមានប្រាកដនៃរូប គឺជាការមានប្រាកដនៃ ជរានិង មរណៈ ។ រូបមានជម្ងឺ រូបមានរោគ ជម្ងឺក្តី រោគក្តីមិនមែនសភាវៈដទៃគឺតួរូបក្ខន្ធហ្នឹងតែម្តង ។ ស្រឡាញ់រូបគឺស្រឡាញ់រោគ បើខ្លាចរោគ ក៏ត្រូវខ្លាចរូប ។ រូបឈឺសោះម៉េចបានជាគិតថាខ្លួនជាអ្នកឈឺ គ្រាន់តែនិយាយថាខ្លួនឈឺទៅបានហើយ ប៉ុន្តែដោយបរមត្ថត្រូវឃើញថា **រូបឈឺ** ។

αកាយដែលប្រកបដោយមហាភូតរូប៤ ជារបស់បែកធ្លាយ ពោរពេញដោយរបស់មិនស្អាត មានក្លិនស្អុយ ពុំមែនជាសត្វបុគ្គលឡើយ ហើយក៏ពុំមែនមានសត្វបុគ្គលអាស្រ័យនៅក្នុងរូបកាយដែរ រូបកាយនេះកាលដែលវិញ្ញាណប្រាសទៅហើយ ពោលគឺចុតិចិត្តមកដល់ វិញ្ញាណរលត់ទៅ មិនមានចិត្តអាស្រ័យនៅក្នុងរូបកាយ សេចក្តីដឹងខ្លួនថា អញពុំមាននៅក្នុងសាកសពឡើយ ។

αបើបុគ្គលណាមានបញ្ញា ពិចារណាឃើញនូវរូបកាយរបស់ខ្លួនឯង ដែលនៅរស់នេះ ថាជាធាតុមិនដឹង ដូចជាសាកសពដែរ គឺបានចែកដាច់ចេញអំពីនាមធម៌ សាកសពនោះយ៉ាងណា សរីរៈនេះក៏យ៉ាងនោះដែរ បុគ្គលនោះឈ្មោះថាបានចំរើននូវរូបកម្មដ្ឋាន ។

αបុគ្គលដែលស្លាប់ចាកអំពីលោកនេះទៅ ពុំមាននៅក្នុងលោកនេះយ៉ាងណា អ្នកដែលបានចំរើននូវរូបកម្មដ្ឋាន ក៏ពុំមាននៅក្នុងលោកនេះយ៉ាងនោះដែរ ថែមទាំងពុំមាននៅក្នុងលោកដទៃទៀតផង ព្រោះឃើញដោយបញ្ញា តាមពិតនូវវិញ្ញាណដែលដោយឡែកអំពីរូបកាយនោះ ត្រឹមតែវិញ្ញាណប៉ុណ្ណោះ ។

αសូមពុទ្ធបរិស័ទ កុំប្រមាទ កុំបណ្តែតបណ្តោយបញ្ញាក្នុងការពិចារណានូវធាតុដី ទឹក ភ្លើង ខ្យល់ ។

# សសម្ភារបឋវី

ធាតុណាជាខាងក្នុង ដែលសន្ទតថាខ្លួន ជារបស់រឹង ជារបស់គ្រោតគ្រាត ជាឧបាទិន្នករូប គឺរូបដែលកម្មជាអ្នក សាងបានដល់ សក់ទាំងឡាយ រោមទាំងឡាយ ក្រចកទាំង ឡាយ ធ្មេញទាំងឡាយ ស្បែក សាច់ សរសៃទាំងឡាយ ឆ្អឹងទាំងឡាយ ខួរក្នុងឆ្អឹង តម្រងនោម បេះដូង ថ្លើម លំពែង ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ លលាដ៏ក្បាល ខួរក្នុងក្បាល នេះហៅថា បឋវី ធាតុខាងក្នុង ។ បុគ្គលគួរឃើញនូវគ្រប់អាការៈដែលជា សសម្ភារបឋវី មាន សក់ទាំងឡាយនោះថា មិនមែនជាសត្វឡើយ គឺរកអ្វីជាខ្លួន សត្វ ខ្លួនបុគ្គលនៅក្នុងកាយ ពុំមាន ។

**αវិញ្ញាណដែលកើតតាមទ្វារទាំង៦គាល ដែលកើតឡើងហើយ ក៏ត្រូវរលត់ផុតទៅ ពេលគឺវិញ្ញាណរលត់ វិញ្ញាណក៏ជាអនត្តា ពុំមែនជាសត្វបុគ្គលឡើយ ។**

# សសម្ភារអាបោ

ធាតុណាជាខាងក្នុង ដែលសន្ទតថាខ្លួន ជាទឹករាវ ជាឧបាទិន្នករូប គឺរូបដែលកម្មបានតាក់តែង បានដល់ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសំបោរ ទឹករំអិល ទឹកមូត្រ នេះហៅថាអាបោធាតុខាងក្នុង ។ សសម្ភារអាបោទាំងអស់នេះ មិនមែនជាមនុស្សឬសត្វឡើយ គ្រាន់តែជាធាតុតែប៉ុណ្ណោះ គឺសត្វបុគ្គលនៅក្នុងរូបកាយពុំមានទេ ។

αអាការៈទាំងអស់ ជាធាតុដី ២១ និង ជាធាតុទឹក ១២ អាការៈណាមួយក៏ដោយសុទ្ធតែជាធាតុ មិនមែនជាសត្វបុគ្គលតួខ្លួនឡើយ ហើយក៏មិនគួរប្រកាន់ថាជារបស់ខ្លួនដែរ ព្រោះថាវិញ្ញាណមានការកើតឡើងហើយ តែងតែរលត់ទៅវិញ វិញ្ញាណក៏មិនមែនជាខ្លួន ដូច្នេះតើបានអ្វីដើម្បីធ្វើជាម្ចាស់លើរូបកាយ ។

αរូបកាយជារបស់មិនស្អាត មានក្លិនស្អុយ ដោយអាស្រ័យសសម្ភារបឋវី និង សសម្ភារអាបោ ។

# សសម្ភារតេជោ

ធាតុណាជាខាងក្នុង ដែលសន្មតថាខ្លួន ជាភ្លើង ក្តៅ ជាឧបាទិន្នករូបគឺរូបដែលមានកម្មជាអ្នកសាង បានដល់ :

- តេជោធាតុដែលញ៉ាំងកាយឱ្យក្តៅសព្វ ១
- តេជោធាតុដែលញ៉ាំងកាយឱ្យគ្រាំគ្រា ១
- តេជោធាតុដែលដុតកាយឱ្យក្រហល់ក្រហាយ ១
- តេជោធាតុសំរាប់ដុតភោជន អាហារបរិភោគ

ដែលលេបចូលទៅឱ្យរលាយ ១ នេះហៅថា តេជោធាតុជាខាងក្នុង គ្រាន់តែជាធាតុពិត។ ពុំមែនជាមនុស្ស ឬសត្វ ឡើយ ក្នុងកាយសូន្យចាកសត្វ ។

# សសម្ភារវាយោ

ធាតុណាជាខាងក្នុង ដែលសន្មតថាខ្លួនជាខ្យល់ តឹង ញ័រ តាក់តែងដោយកម្ម មានវិញ្ញាណជាទីអាស្រ័យ ជាឧបាទិន្នករូប បានដល់ខ្យល់បក់ឡើងលើ ១ ខ្យល់បក់ចុះក្រោម ១ ខ្យល់បក់ក្នុងផ្ទៃ ១ ខ្យល់បក់ក្នុងពោះវៀន ១ ខ្យល់បក់សព្វសរីរាង្គកាយ ១ ខ្យល់ដកដង្ហើមចូល-ចេញ ១ នេះហៅថា វាយោធាតុខាងក្នុង ។

$\alpha$ ដី ទឹក ភ្លើង ខ្យល់ ជាខាងក្រៅ ធំ ច្រើន ខ្លាំង គគ្រឹកគគ្រេងយ៉ាងណាក្តី ក៏គង់អស់ទៅ សូន្យទៅ ចុះបើកាយនេះដែលតាំងនៅដោយដីបន្តិចបន្តួច ទឹកបន្តិចបន្តួច ភ្លើងបន្តិចបន្តួច ខ្យល់បន្តិចបន្តួច យ៉ាងនេះ នឹងមិនអស់ទៅ សូន្យទៅដូចម្តេចបាន ។ បុគ្គលតាំងនៅដោយកម្មដ្ឋានរឿយ។ ក៏រមែងមានចិត្តគ្រាកចេញអំពីកាយដែលប្រកបដោយមហាភូតរូប៤ នេះ ព្រោះមិនប្រកបដោយសត្វ បុគ្គល។

# ១០.អរូបិនោ ធម្មា

## ធម៌ទាំងឡាយ ជាអរូបធម៌

## បានដល់ចិត្ត និង ចេតសិកទាំងអស់ព្រមទាំងនិព្វាន

αអាកាសទទេជាទីវាល ដែលអាស្រ័យគ្រឿងឈើខ្លះ អាស្រ័យវល្លិ៍សំរាប់ចងខ្លះ អាស្រ័យដីសំរាប់លាបខ្លះ អាស្រ័យស្បូវប្រក់ខ្លះ ផ្គុំជាមួយគ្នាហើយ ក៏រាប់ហៅថាផ្ទះបាន យ៉ាងណាមិញ អាកាសដែលអាស្រ័យឆ្អឹងខ្លះ អាស្រ័យសរសៃខ្លះ អាស្រ័យសាច់ខ្លះ អាស្រ័យស្បែកខ្លះ រួបរួមជាមួយគ្នាហើយ ទើបហៅថាជារូបកាយបានដូច្នោះឯង **នគរឆ្អឹងដែលសាងដោយកម្ម ឆ្អឹងនោះត្រូវបានចងរឹតនៅដោយសរសៃទាំងឡាយ មិនឫកលាបដោយសាច់ និង ឈាម ស្រោបពាសដោយស្បែក ពេញដោយរបស់មិនស្អាត មានក្លិនស្អុយ** ***ជាទីធ្លាក់ចុះនៃ ជរា ព្យាធិ និង មរណៈ ព្រមទាំងភ្លើងរាគៈ ទោសៈ មោហៈ ។***

χ ចក្ខុវិញ្ញាណ កើតឡើងព្រោះអាស្រ័យចក្ខុប៉ះនឹងរូប ។ ចក្ខុមិនទៀង រូបមិនទៀង ចក្ខុវិញ្ញាណមិនទៀង សតិរលឹករឿយៗចំពោះការកើតឡើង និងការរលត់ទៅវិញនៃរបស់ដែលមិនទៀងទាំងនោះ ចំពោះទ្វារត្រចៀក ទ្វារច្រមុះ ទ្វារអណ្តាត ទ្វារកាយ និង ទ្វារចិត្ត ក៏មានសភាវធម៌ពិតៗ កើតឡើងហើយ ក៏រលត់បាត់ទៅវិញ **វិញ្ញាណកើតឡើងតាមទ្វារទាំង៦ ព្រោះអាស្រ័យអាយតនៈក្នុង និងគ្រាប៉ះខ្ទប់គ្នា វិញ្ញាណជាអនត្តា ។**

αបើវិញ្ញាណរលត់អស់អំពីរូបកាយ រូបកាយក៏ជាសាកសព សេចក្តីដឹងខ្លួនថាអញ មិនមានក្នុងសាកសពឡើយ ទោះជារូបអ្វីក៏ដោយ ដូចជារូបមនុស្សយើងដែលនៅរស់នេះ ក៏ជាធាតុមិនដឹង ដូចជាសាកសពដែរ ប៉ុន្តែខុសប្លែកត្រង់មនុស្សរស់គឺមានវិញ្ញាណ មានការសោយអារម្មណ៍ មានការចាំអារម្មណ៍ មានការនឹកគិតផ្សេងៗ ពេលគឺ

កាយដែលប្រកបដោយមហាភូតរូប ប្រៀបបីដូចជាសាលាសំណាក់មួយនៅតាមផ្លូវ មានទ្វារ ៦ ប៉ុន្តែពុំមានម្ចាស់នៅចាំទទួលរាក់ទាក់អ្នកដំណើរដែលចូលទៅសំរាកឡើយ ។

កាយដែលប្រកបដោយមហាភូតរូប ៤ នេះ មាន ទ្វារ ៦ គឺទ្វារភ្នែក ទ្វារត្រចៀក ទ្វារច្រមុះ ទ្វារអណ្តាត ទ្វារកាយ និង ទ្វារចិត្ត ។ វេទនាកើតឡើងព្រោះផស្សៈតាមទ្វារជាបច្ច័យ សត្វបុគ្គលអ្នកទទួលវេទនាពុំមានឡើយ វេ-ទនាកើតហើយរលត់ទៅវិញជាធម្មតា ប្រៀបបីដូចសាលាសំណាក់មានទ្វារ ៦ ប៉ុន្តែអត់មានអ្នកនៅចាំទទួលភ្ញៀវ ភ្ញៀវគឺជាអ្នកដំណើរចូលហើយក៏ចេញវិញ ចូលហើយចេញវិញ រហូតទាល់តែសាលាសំណាក់នោះ ពុកផុយបាក់បែកខ្ទេចខ្ទី សំណាក់លែងបានតទៅទៀត យ៉ាងណាមិញ បើវេ-ទនារលត់អស់ ពុំមានសល់នៅវេទនាណាមួយហើយ សេចក្តីដឹងខ្លួនថាអញក្នុងរូបក្ខន្ធសុទ្ធពុំមានឡើយ ព្រោះហេតុដូច្នេះបុគ្គលមិនគួរត្រិះរិះថា ខ្លួនជាអ្នកទទួលនូវវេទនាឡើ-យ

មនុស្សរស់មានវេទនា សញ្ញា សង្ខារ វិញ្ញាណ ព្រោះមានផស្សៈតាមទ្វារទាំង ៦ ជាបច្ច័យ នាមក្ខន្ធទាំង ៤នេះ ដាច់ដោយឡែកអំពីរូបក្ខន្ធ ព្រោះរូបជាធាតុមិនដឹង ឯនាមវិញជាធាតុដឹងគឺដឹងនូវអារម្មណ៍ ហើយក៏រលត់បាត់ទៅវិញ ទោះបីរូបក៏កើតរលត់ៗ មិនតាំងនៅ មិនឋិតថេរ ក្នុងលោកនេះ គឺខន្ធលោកសុទ្ធតែជារបស់ផ្សំផ្គុំ ដោយហេតុ ដោយបច្ច័យ រួចហើយរមែងបែកធ្លាយ ។

## អំពីវេទនាខន្ធ

χ សុខវេទនា (សុខកាយសប្បាយចិត្ត) ១ ទុក្ខ វេទនា (ទុក្ខកាយមិនសប្បាយចិត្ត) ១ និង វេទនាមិន សុខមិនទុក្ខស្មើៗ ១ ។ វេទនាទាំង ៣ សុទ្ធតែមិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ និង ជាអនត្តា ។ វេទនាទាំង ៣ តែងកើតផ្លាស់ប្តូរគ្នាម្តងមួយៗព្រោះផស្សៈជាបច្ច័យ ។

ទាំងមិនគួរត្រិះរិះថា វេទនាជាតួខ្លួនដែរ ព្រោះវេទនាជាសភាវៈមិនទៀង តែងអស់ទៅ សូន្យទៅ ។

χ វេទនាប្រៀបដូចកំដៅភ្លើងអុសពីរដុំ ដែលផ្ទុំចូលគ្នា គឺព្រោះផស្សៈជាបច្ច័យទើបវេទនាកើតឡើង ផស្សៈអាស្រ័យអាយតនៈ ៦ ជាខាងក្នុងទើបកើតឡើង ចក្ខុមិនទៀង រូបមិនទៀង ចក្ខុវិញ្ញាណមិនទៀង ចក្ខុសម្ផស្សមិនទៀង វេទនាជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើងព្រោះចក្ខុសម្ផស្សជាឧបនិស្សយប្បច្ច័យ មានអ្វីនឹងទៀងទៅកើត ។

សោតៈមិនទៀង សំលេងមិនទៀង សោតវិញ្ញាណមិនទៀង សោតសម្ផស្សមិនទៀង ការសោយអារម្មណ៍ជាសុខ ជាទុក្ខ ឬ មិនទុក្ខមិនសុខ ក៏មិនទៀង កើតឡើងដោយសោតសម្ផស្សជាបច្ច័យ ហើយក៏ត្រូវអស់ទៅ សូន្យទៅ ពុំមានឋិតនៅឡើយ ។

ឃានៈក៏មិនទៀង ក្លិនក៏មិនទៀង ឃានវិញ្ញាណក៏មិនទៀង ឃានសម្ផស្សក៏មិនទៀង វេទនាគឺការសោយអារម្មណ៍ណា ដែលកើតឡើងអំពីឃានសម្ផស្សជាបច្ច័យ វេទនានោះមានអ្វីនឹងទៀងទាត់ ។

ជីវ្ហាក្តី រសក្តី ជីវ្ហាវិញ្ញាណដែលកើតឡើងដោយជីវ្ហាប៉ះនិងរសក្តី ជីវ្ហាសម្ផស្សក្តី ទាំងអស់នេះសុទ្ធតែមិនទៀង ជារបស់តែងបែកធ្លាយជាធម្មតា វេទនាជាធម្មជាតិសោយនូវអារម្មណ៍ កើតឡើងអាស្រ័យរបស់ដែលមិនទៀងជាបច្ច័យយ៉ាងនេះ វេទនាក៏មិនទៀង ។

វេទនាកើតឡើង តាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី សុទ្ធតែមិនទៀងទាត់ មានការរលត់ទៅវិញ បាត់ទៅវិញជា ធម្មតា ។

χ ***វេទនាមិនទៀង សញ្ញាក៏មិនទៀង សង្ខារក៏មិនទៀង វិញ្ញាណក៏មិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ ពុំមែនសត្វបុគ្គលតួខ្លួនយើង គេឡើយ ៕***

## អំពីសញ្ញាខន្ធ

χ ក្នុងរដូវក្ដៅខ្លាំង ហើយនៅកណ្ដាលវាល មានថ្ងៃបណ្ដើរកូនព្រិចៗ មើលអំពីចម្ងាយទៅ ហាក់ដូចជាមានវាលទឹកធំល្វឹងល្វើយ ប៉ុន្ដែតាមពិតដល់ដើរទៅជិត វាមិនមានអ្វីដូចដែលបានឃើញអំពីចម្ងាយឡើយ យ៉ាងណាមិញ សញ្ញាការសំគាល់ ឬការចាំបាន ទោះបីបានចាំនូវរឿងរ៉ាវរបស់រូប សំលេង ក្លិន រស ផោដ្ឋព្វ ថាជាមាស ប្រាក់ ទ្រព្យសម្បត្តិយ៉ាងណាៗក្ដី អ្វីៗទាំងអស់ដែលសញ្ញាចាំនោះពុំមានឡើយ គឺមានតែសញ្ញាប៉ុណ្ណោះ ដែលកំពុងប្រាកដយ៉ាងនោះដែរ ។

χ ការចាំរឿង អតីតកាល ការចាំនេះគឺសញ្ញាក្នុងបច្ចុប្បន្ន កំពុងប្រាកដ សតិរលឹកត្រង់លក្ខណៈនៃការចាំ មិនមែនសត្វបុគ្គលតួខ្លួនឡើយ ។ មិនគួរអាល័យខន្ធក្នុងអតីតៈទេ ព្រោះខន្ធណាដែលកន្លងទៅហើយ ខន្ធនោះគឺជាទុក្ខ ចំណែកក្នុងអនាគតកាល ក៏មិនមានអ្វីដែលគួរឱ្យសង្ឃឹមដែរ អនាគតមិនមែនជាទីពឹង អនាគតធមិគឺខន្ធ ៥ មិនមែនជាព្រះនិព្វាន បញ្ចក្ខន្ធជាបច្ចុប្បន្នមិនទៀង នាំមកនូវបញ្ហាជាប់តាមរាប់មិនអស់ព្រោះតែរូប និង ព្រោះផស្សៈជាបច្ច័យ វេទនា សញ្ញា សង្ខារ វិញ្ញាណកើតមាន ជាអនត្តា បុគ្គលមានបញ្ញា ឃើញស្វាត់ក្នុងផស្សៈ គឺស្វាត់សូន្យចាក សត្វចាកបុគ្គល ឃើញតែវេទនា សញ្ញា សង្ខារ វិញ្ញាណ តែប៉ុណ្ណោះ ដែលដឹងអារម្មណ៍តាមទ្វារទាំង ៦ ដឹងរួចភ្លាម ក៏រលត់សូន្យអស់ពុំមាននៅសល់ក្នុងលោកឡើយ លោក សូន្យ ។

χ ការមានសតិរលឹករឿយៗ រមែងចែកនូវខន្ធ ៥ ផ្សេងៗអំពីគ្នា បញ្ញាឃើញច្បាស់នូវខន្ធនីមួយៗ មិនមែនជាសត្វ គ្រាន់តែជាធាតុដែលមានបច្ច័យផ្សំផ្គុំតែប៉ុណ្ណោះ ។

χ ការមានសតិរលឹករឿយៗ រមែងចែកនូវអាយត នៈ ១២ ផ្សេងៗអំពីគ្នា បញ្ញាឃើញច្បាស់នូវអាយតនៈ នីមួយៗ មិនមែនជាសត្វបុគ្គលតួខ្លួនឡើយ គ្រាន់តែជាធាតុ

ដែលមានបច្ច័យតាក់តែងឱ្យកើតឡើង ហើយរលត់ទៅវិញតែប៉ុណ្ណោះ ។

χ ការមានសតិរលឹករឿយៗ រមែងចែកនូវធាតុ ១៨ ផ្សេងៗអំពីគ្នា បញ្ញាឃើញច្បាស់នូវធាតុនីមួយៗ មិនមែនជាសត្វបុគ្គលតួខ្លួនយើង គេឡើយ ។

χ បញ្ញាត្រាស់ដឹងនូវអរិយសច្ចធម៌ គឺជាបរមត្ថប្រយោជន៍ អរិយសច្ចៈ ៤ យ៉ាងក៏ជាអនត្តា ហើយក៏ជាសតិប្បដ្ឋាន គឺជាទីតាំងនៃសតិរលឹកទៀតផង ។

χ សតិផ្ទាក់សតិប្បដ្ឋាន ជាគុណជាតិដ៏ប្រសើរ ខ្ពង់ខ្ពស់ រមែងចែកនូវសភាវៈធម៌ ឬបរមត្ថធម៌ឱ្យបញ្ញាឃើញផ្សេងៗអំពីគ្នា ប្រៀបបីដូចការភ្ជួរស្រែដោយផាលនង្គ័លដូច្នោះឯង ។

χ នាមរូបប្រៀបបីដូចជាស្រែ នាមរូបជាទីតាំងនៃការងារ ដែលគ្រប់គ្នាតែងមាន ប៉ុន្តែសូមឱ្យតែយើងម្នាក់ៗស្តាប់នូវព្រះធម៌ក្នុងព្រះពុទ្ធសាសនា ដើម្បីរៀនឱ្យចេះធ្វើស្រែក្នុងវដ្តសង្សារ ដែលមានព្រះនិព្វានជាផល គឺការចំរើនសតិប្បដ្ឋាន ។

# អំពីសង្ខារធម៌

ពួកចេតសិក ដែលតាក់តែងចិត្ត វៀរវេទនា និង សញ្ញាចេញ ហៅថាសង្ខារក្ខន្ធ ។

ធម្មតាដែលឈ្មោះថាចិត្ត ព្រោះវិចិត្រដោយសម្បយុត្តធម៌ គឺចេតសិកដែលកើតរលត់ជាមួយ និងដែលឈ្មោះថាចិត្ត ព្រោះវិចិត្រដោយអារម្មណ៍ គឺអារម្មណ៍របស់ចិត្តនោះឯង ។

សទ្ធាជាចេតសិកល្អ រមែងតាក់តែងចិត្តឱ្យចិត្តល្អ ស្អាតផូរផង់ប្រាសចាកមន្ទិលសៅហ្មង បើសទ្ធាជាកុសលក៏តាក់តែងចិត្តឱ្យជាកុសលពិតៗ ។

ចិត្តជាកុសល ត្រូវបានចេតសិកល្អៗដែលកើតរួមជាមួយតាក់តែង រមែងរលត់ទៅវិញ មិនទៀងទាត់ មិនឋិតថេរយឺនយូរឡើយ សតិរលឹកឃើញជាប្រក្រតីរឿយៗ នូវការកើតឡើង និង ការរលត់ទៅវិញនៃសភាវធម៌ពិតៗ រកសត្វបុគ្គលតួខ្លួនពុំមាន ប្រៀបបីដូចជាការបកស្រទបចេករកខ្លឹមពុំមានយ៉ាងនោះដែរ ។

បើបីតិតាក់តែងចិត្ត ចិត្តក៏ប្រកបដោយសោមនស្សវេទនា បើបញ្ញាតាក់តែងចិត្ត ចិត្តក៏ប្រកបដោយបញ្ញាគឺញាណសម្បយុត្ត បើអកុសលចេតសិក តាក់តែងចិត្ត ចិត្តក៏ជាអកុសលពិត ទើបហៅថាសង្ខារក្ខន្ធ សូម្បីវេទនា និង សញ្ញា ក៏តាក់តែងចិត្តដែរ ប៉ុន្តែជាខន្ធផ្សេងអំពីសង្ខារក្ខន្ធ ព្រោះវេទនាជាតួសោយអារម្មណ៍ គឺជាតួត្រេកអរ រីករាយក្នុងអារម្មណ៍ ឯសញ្ញាជាតួឧបត្ថម្ភនូវវេទនាឱ្យប្រណីត ។

χ ជីវិតពិតជាទុក្ខ ព្រោះប្រកបដោយឧបាទានក្ខន្ធ ទុក្ខការមានជីវិតបានរួចអំពីឧបាទានក្ខន្ធ ៥ សូម្បីតែមួយភ្លែតក៏ប្រសើរពន់ពេកណាស់ ។

χ ការរួចអំពីខន្ធ គឺការមិនប្រកាន់ខន្ធ ។

χ លោកសូន្យគឺលោកធាតុ មានចក្ខុធាតុ រូបធាតុ ចក្ខុវិញ្ញាណធាតុជាដើម រហូតដល់មនោធាតុ ធម្មធាតុ មនោវិញ្ញាណធាតុ គឺជាលោកស្ងាត់ចាកសត្វបុគ្គលគួរដល់ការហ្វឹកហាត់ អប់រំសតិ-បញ្ញា គឺមិនត្រូវស្វែងរកលោកបញ្ញត្តិ សំរាប់ហ្វឹកហាត់អប់រំសតិ-បញ្ញាឡើយ ព្រោះសតិ-ប្បដ្ឋាន-វិបស្សនា គឺជាការធ្វើដំណើរចេញចាកលោក មានចក្ខុលោក និង រូបលោកជាដើម ទើបបានដល់ទីបំផុតទុក្ខគឺព្រះនិព្វាន ។

χ ការធ្វើដំណើរក្នុងលោកចក្រវាឡ ពិតជាមិនអាចដល់ទីបំផុតឡើយ ។

## អំពីវិញ្ញាណក្ខន្ធ

χ ក្នុងជីវិតប្រចាំថ្ងៃ គ្រប់គ្នាតែងតែមាននូវរបស់ពិតម្យ៉ាងគឺវិញ្ញាណ វិញ្ញាណពុំមែនព្រលឹង ឬអត្តាតួខ្លួន ឡើយ វិញ្ញាណជាអនត្តា ។

ចក្ខុវិញ្ញាណជាអនត្តា សោតវិញ្ញាណជាអនត្តា ឃានវិញ្ញាណជាអនត្តា កាយវិញ្ញាណជាអនត្តា មនោវិញ្ញាណជាអនត្តា ។

វត្ថុរូប ៦ ជានិស្សយប្បច្ច័យនៃវិញ្ញាណ គឺចក្ខុវត្ថុជាទីអាស្រ័យនៃចក្ខុវិញ្ញាណ សោតវត្ថុជានិស្សយប្បច្ច័យនៃសោតវិញ្ញាណ ឃានវត្ថុជាទីកើតនៃឃានវិញ្ញាណ ជីវ្ហាវត្ថុជាទីអាស្រ័យនៃជីវ្ហាវិញ្ញាណ កាយវត្ថុជាទីអាស្រ័យនៃកាយវិញ្ញាណ ហទយវត្ថុជាទីអាស្រ័យនៃមនោវិញ្ញាណ វិញ្ញាណមិនទៀង ជាទុក្ខ ជាអនត្តា ពុំមែនជាសត្វបុគ្គលតួខ្លួនយើងគេឡើយ ។

វិញ្ញាណអាស្រ័យចក្ខុ ទើបហៅថាចក្ខុវិញ្ញាណ ចក្ខុមិនទៀង វិញ្ញាណបើមិនអាស្រ័យចក្ខុគឺភ្នែកហើយ រមែងជាចក្ខុវិញ្ញាណពុំបានឡើយ ។

វិញ្ញាណអាស្រ័យសោតៈ ទើបហៅថាសោតវិញ្ញាណ សោតៈមិនទៀង វិញ្ញាណបើមិនអាស្រ័យសោតៈគឺត្រចៀកហើយ រមែងជាសោតវិញ្ញាណពុំបានឡើយ ។

វិញ្ញាណអាស្រ័យឃានៈ ទើបហៅថាឃានវិញ្ញាណ ឃានៈមិនទៀង វិញ្ញាណបើមិនអាស្រ័យឃានៈ គឺច្រមុះហើយ រមែងជាឃានវិញ្ញាណពុំបានឡើយ ។

វិញ្ញាណអាស្រ័យជីវ្ហា ទើបហៅថាជីវ្ហាវិញ្ញាណ ជីវ្ហាមិនទៀង វិញ្ញាណបើមិនអាស្រ័យជីវ្ហាគឺអណ្តាតហើយ រមែងជាជីវ្ហាវិញ្ញាណពុំបានឡើយ ។

វិញ្ញាណអាស្រ័យកាយ ទើបហៅថាកាយវិញ្ញាណ កាយមិនទៀង វិញ្ញាណបើមិនបានអាស្រ័យកាយ គឺបសាទកាយហើយ រមែងជាកាយវិញ្ញាណពុំបានឡើយ ។

វិញ្ញាណអាស្រ័យមនោ (ភវង្គៈដែលជាអនន្តរប្បច្ច័យដល់មនោទ្វារាវជ្ជនៈ) ហៅថាមនោវិញ្ញាណ មនោគឺភវង្គចិត្តមិនទៀង វិញ្ញាណបើមិនបានអាស្រ័យមនោហើយ រមែងជាមនោវិញ្ញាណតាមមនោទ្វារពុំបានឡើយ ។

χ នៅពេលសំរាន្តលង់លក់ សូម្បីមិនមាននូវចក្ខុវិញ្ញាណ ក៏មានចក្ខុ និង វណ្ណរូបដែរ ព្រោះជាបរមត្ថធម៌ ទោះជាវិថីចិត្តមិនមានក៏ដោយ រូបបរមត្ថផ្សេងៗ មានកម្ម

ជាបច្ច័យ ឬឧតុជាបច្ច័យជាដើម ក៏រមែងតែងតែមានជាធម្មតា ប៉ុន្តែចំពោះរឿងរ៉ាវបញ្ញត្តិដែលមិនមែនជាបរមត្ថ ធម៌ គឺទាល់តែមនោវិញ្ញាណក្នុងមនោទ្វារកើតឡើងនឹក គិតដល់អារម្មណ៍បញ្ញត្តិនោះ ព្រោះហេតុដូចនេះ បញ្ញត្តិមិនមានសភាវៈអ្វីសូម្បីតិចតួចដោយខ្លួនឯងឡើយ ។

χ នៅពេលដឹងរឿងរ៉ាវរបស់អ្នកដទៃ គួរមានសតិរលឹកដឹងនូវមនោវិញ្ញាណដែលកើតឡើង មិនទៀង ជាទុក្ខ ជាអនត្តា មានការអស់ទៅ សូន្យទៅជាធម្មតា ចំណែករឿងបញ្ញត្តិ ដែលជាអារម្មណ៍របស់មនោវិញ្ញាណនោះ មិនមានសាមញ្ញលក្ខណៈគឺ អនិច្ចំ ទុក្ខំ អនត្តាឡើយ ព្រោះមិនមាននូវសភាវលក្ខណៈ ។

χ បើកុំតែមានវិញ្ញាណកើតឡើងដឹងអារម្មណ៍តាមទ្វារទាំង ៦ តើមានរឿងរ៉ាវរបស់ខ្លួនឯង និង អ្នកដទៃមកអំពីណា ។

## ១១. លោកិយា ធម្មា

ពួកធម៌ជាលោកិយ បានដល់លោកិយចិត្ត ៨១ ចេតសិកសម្បយុត្ត ៥២ រូប ២៨ ។

χ ពួកធម៌ជាលោកិយ សុទ្ធតែជាអារម្មណ៍របស់កិលេសបានទាំងអស់ ឈ្មោះថា ឧបាទានក្ខន្ធគឺ ខន្ធណាដែលអាចជាអារម្មណ៍របស់ឧបាទានបាន ឧបាទានក្ខន្ធមាន ៥ ។

χ រូប សំលេង ក្លិន រស ផោដ្ឋព្វៈ ជាកាមារម្មណ៍មានពិសដ៏ខ្លាំងក្លា ប៉ុន្តែថា វាមានចំណុចខ្សោយនៅត្រង់មិនទៀង នេះគឺជាទោសរបស់វត្ថុកាមគុណ បុគ្គលអប់រំបញ្ញាឃើញការកើតឡើងហើយ រលត់ទៅវិញនៃ រូប សំលេង ក្លិន រស ផោដ្ឋព្វ រឿយៗ ឈ្មោះថាឃើញចំណុចខ្សោយរបស់កាមារម្មណ៍នោះ ដែលថាចំណុចខ្សោយ ព្រោះវាមិនអាចញ៉ាំងកាមច្ឆន្ទៈឱ្យកើតឡើងបានទេ ដោយសារបានឃើញទោសរបស់វាពិតៗ ។

χ កាមារម្មណ៍នេះ បុគ្គលអាចផ្លាស់ប្តូរអំពីអារម្មណ៍របស់លោភៈ ឱ្យមកជាសតិប្បដ្ឋាន គឺជាអារម្មណ៍របស់សតិ-វិបស្សនា សំរេចនូវកិច្ចការដ៏ប្រសើរ ដែលជាបរមត្ថប្រយោជន៏ ។

χ ដើម្បីបណ្តេញបង់នូវកិលេស គឺត្រូវតែចាប់យកនូវលោកិយធម៌ ដែលប្រក្រតីធម្មតា តែងតែជាអារម្មណ៍របស់តណ្ហា មានៈ ទិដ្ឋិ ឱ្យបានមកជាសតិប្បដ្ឋាន គឺជាទីតាំងនៃការរលឹកដឹងរឿយៗវិញ ព្រោះថាសត្រូវនៅក្នុងទីតាំង ណាកន្លែងណា ដើម្បីសម្លាប់នូវខ្មាំងសត្រូវនោះ ក៏ត្រូវតែលើកកងទ័ពចូលទៅកាន់ទីនោះ វាយបំបែកហ្វូងខ្មាំង សម្លាប់មេរបស់វា គឺអវិជ្ជា ។

## សេចក្តីឧបមាអំពីនីវរណៈ

### ស្រង់ចាក សាមញ្ញផលសូត្រ

χ **កាមច្ឆន្ទៈ** - ឧបមាដូចការជំពាក់បំណុលអ្នក ដទៃ អ្នកជំពាក់គេ មានទុក្ខច្រើនប្រការ យ៉ាងណាអ្នកពេញចិត្តនៅក្នុងវត្ថុកាម ក៏រមែងរហេមរហាមក្នុងការស្វែងរកជាដើម យ៉ាងនោះដែរ ។

χ តាមពិតសង្ខារធម៌គ្រប់យ៉ាង សុទ្ធតែមិនទៀងមានការទ្រុឌទ្រោម អស់ទៅ សូន្យទៅ កាមគុណ ៥ប្រការក៏យ៉ាងនោះដែរ ប៉ុន្តែដែលសត្វលោកតែងតែត្រេកអររីករាយ មកអំពីការប្រកាន់នូវរឿងបញ្ញត្តិ ដែលរឿងបញ្ញត្តិនោះមិនមានការកើត ការរលត់ដូចសភាវធម៌ឡើយ និងម្យ៉ាងទៀតព្រោះមិនបានឃើញការកើតការរលត់នៃនាម រូប តណ្ហាក៏ប្រកាន់ថា នុះជារបស់យើង ។

χ នៅពេលណាដែលមានបញ្ញាបានឃើញសភាវធម៌មិនទៀង លែងប្រកាន់ថា នុះជារបស់យើង នៅពេលនោះ ទើបជាក់ច្បាស់ក្នុងចិត្តថា កាមច្ឆន្ទៈ ជាការជំពាក់បំណុលគេ សត្វលោកក្រជានិច្ច ខ្វះកន្លះជានិច្ចព្រោះតណ្ហា ***តណ្ហាជាម្ចាស់បំណុល*** សត្វលោកទោះជាខំប្រឹងស្វែងរកវត្ថុបំណងបានច្រើនប៉ុណ្ណាៗ ក៏បានត្រឹមតែចុងការតែ

ប៉ុណ្ណោះ គឺសងដើមពុំបានរួចឡើយ ព្រោះតណ្ហានៅតែថានុះរបស់អញៗជានិច្ច (តណ្ហាមិនមែនជាខ្លួនយើងឡើយ គឺជាចៅហ្វាយឥតមេត្តា) ។

χ តាមពិតសត្វលោកទាល់តែស្វែងរកទ្រព្យបញ្ញាទើបអាចសងបំណុលតណ្ហាឱ្យរួចទៅបាន ការមិនមានកាមច្ឆន្ទៈ គឺរួចបំណុល រមែងនៅដោយ បីតិសោមនស្ស ។

χ ការស្តាប់ព្រះធម៌ ចំរើនបញ្ញា គឺរួមចំណែកក្នុងការងារស្វែងរកទ្រព្យសម្បត្តិរបស់សត្វលោក ហើយជាសំ-ខាន់អស្ចារ្យនោះ គឺធ្វើឱ្យបាននូវទ្រព្យសម្បត្តិចេះគ្រប់ចេះគ្រាន់ ។

χ សព្វថ្ងៃសត្វលោកទាមទារការគ្រប់ការគ្រាន់ការឆ្អែតការល្មម ដូច្នេះសូមកុំចោល ឬរំលងនូវដុំពេជ្រ គឺបញ្ញា ដែលជាវត្ថុមានតម្លៃ ហើយទៅសន្សំនូវសំរាមគឺកាមគុណ ដែលជាវត្ថុមិនមានតម្លៃនោះឱ្យសោះ ។

χ **ព្យាបាទ** - ឧបមាដូចការមាននូវរោគ ជម្ងឺគ្រុនល្វីងមាត់បាយមិនឆ្ងាញ់ជាដើម ។

χ បុគ្គលមានចិត្តប្រៀបដូចជាដំបៅ ពេលមានអ្វីប៉ះត្រូវក៏ហូរឈាម ឬហូរទឹករងៃ ឬក៏ខ្ទុះចេញមក យ៉ាងណាការខឹងក្រោធក៏ដូច្នោះឯង គឺមានការប៉ះនឹងពាក្យស្តីថារបស់អ្នកដទៃសូម្បីតែបន្តិចបន្តួច ក៏ហូរចេញនូវរបស់ស្មោកគ្រោកគឺកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត នេះពិតជាមនុស្សមានចិត្តប្រៀបដូចដំបៅស្អុយ ។

χ បុគ្គលខឹងក្រោធដោយអត់ធន់នឹងពាក្យទូន្មានមិនបាន ក៏អាចលាចាកសិក្ខាបទ មិនបានបរិភោគនូវអត្ថរសធម្មរសនៃព្រះធម៌ឡើយ ។

χ ការកើតមកនៃបុគ្គលម្នាក់ៗ ជាការប្រជុំរួមនៃឧបាទានក្ខន្ធ ៥ គឺជាការកើតឡើងនៃទុក្ខ តាមពិតបុគ្គលម្នាក់ៗ មិនមែនជាទីតាំងនៃការស្អប់ខ្ពើម ខឹងក្រោធ ព្យា-បាទបៀតបៀននោះទេ តែគួរជាទីតាំងនៃមេត្តាការអនុ-គ្រោះប្រយោជន៏ និង ករុណាជាដើម ។

χ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងនូវព្រះធមិ ដោយព្រះទ័យករុណា គឺព្រះទ័យអាណិតអាសូរសត្វលោក ដើម្បីជួយស្រោចស្រង់សត្វលោកឱ្យរួចផុតចាកទុក្ខទាំងពួង

χ សត្វលោកមានសុទ្ធតែធាតុទុក្ខប្រជុំរួមជាខន្ធ៥ ប៉ុន្តែពុំបានដឹងនូវទុក្ខតាមពិត ទើបរីករាយនៅក្នុងទុក្ខ ជាប់នៅជាមួយទុក្ខដោយសារចំណង ***ឆន្ទរាគៈ*** ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ពន្យល់ឱ្យសត្វលោកកំណត់ដឹងនូវទុក្ខពិតៗ កាលកំណត់ដឹងនូវទុក្ខហើយ ទើបនឿយណាយនឹងខន្ធ ៥ ជាទុក្ខ កាលដែលនឿយណាយ ក៏ប្រាសចាកតម្រេក កាលដែលប្រាសចាកតម្រេក ចិត្តក៏ផុតស្រឡះអំពីខន្ធ ៥ ***ការកំចាត់ឆន្ទរាគៈ គឺ ព្រះនិព្វាន*** ។

χ សត្វលោកគឺជាបុគ្គលដែលគួរជួយស្រោចស្រង់តែម្យ៉ាង ។

χ គួរមានមេត្រីភាពដល់គ្នានិងគ្នា ព្រោះសត្វលោកនៅក្នុងទ្រុងរបស់មច្ចុរាជទាំងអស់គ្នា គួរជួយគ្នាដើម្បីរត់ចេញអំពីទ្រុងមច្ចុ ដែលជាគុកធំ ពោរពេញដោយមហាទារុណកម្ម សោកខ្សឹកខ្សួល ។

χ មិនគួរយកឈ្នះអ្នកដទៃដោយការព្យាបាទបៀតបៀនទេ ប៉ុន្តែគួរយកឈ្នះអ្នកដទៃនិងខ្លួនឯងដោយការបំពេញសេចក្តីល្អបរិសុទ្ធ ។

χ មានតែសេចក្តីល្អ អំពើល្អប៉ុណ្ណោះទេ ដែលអាចឈ្នះខ្លួនឯងនិងអ្នកដទៃបានពិតៗ គឺឈ្នះសេចក្តីក្រោធបានដោយការមិនក្រោធ ឈ្នះសេចក្តីអាក្រក់បាន ដោយអំពើល្អ ឈ្នះសេចក្តីកំណាញ់បាន ដោយការឱ្យទាន ឈ្នះពាក្យសំដីមិនពិត ដោយការនិយាយពាក្យពិត ។

**ថីនមិទ្ធៈ** -ខ្ជិលច្រអូស ងោកងុយ មានសេចក្តីឧប-មាដូចជាប់គុក ព្រោះអ្នកជាប់គុក មិនអាចប្រកបនូវកិច្ច-ការសន្សំទ្រព្យសម្បត្តិ និង ការសប្បាយរីករាយក្នុងពិធីបុណ្យប្រចាំនគរ ដោយការជួបជុំក្រុមគ្រួសារញាតិមិត្តបងប្អូនបានឡើយ យ៉ាងណាមិញ បុគ្គលត្រូវ ថីនមិទ្ធៈគ្រប សង្កត់ នៅពេលស្តាប់ធមិជាដើម ក៏មិនអាចបានដឹងសេចក្តី នៃធមិ

មិនបានបីតិក្នុងការស្តាប់ធម៌ មិនបាននូវផលដ៏ ប្រសើរឡើយ ។

χ បុគ្គលគួរព្យាយាមកំចាត់បង់ថីនមិទ្ធៈ ដោយហ្វឹកហាត់រឿយៗគឺ :

- កំណត់ដឹងអាហារភោជនដែលត្រូវបរិភោគឱ្យបាន

smrmü .

- ពិចារណានូវការផ្លាស់ប្តូរឥរិយាបថបួន និង ការកំរើកកាយ ។

- មនសិការៈទៅរកពន្លឺ ដាស់តឿនចិត្តឱ្យភ្លឺស្វាងពិចារណាធម៌ ។

- នៅក្នុងទីវាលស្រឡះរឿយៗ ខ្យល់អាកាសល្អ ថែទាំសុខភាព ប្រយ័ត្នប្រយែងកុំឱ្យអស់កម្លាំងកាយឥតប្រយោជន៍ ត្រូវរៀបចំខ្លួនឯងឱ្យជាភាជន៍សំរាប់ទទួលយកនូវព្រះសទ្ធម្ម ដែលកម្រកើតមានក្នុងលោក ។

- សេពគប់មិត្តសប្បុរស មិត្តជួយរំលឹកដាស់តឿនមិត្តដែលជាទីប្រឹក្សាល្អ ។

- ពេលជួបជុំគ្នា ត្រូវហ្វឹកហាត់និយាយតែពាក្យមានប្រយោជន៍ ពាក្យដែលគួរនិយាយ កាលពោលទៅហើយរមែងស្ងប់រម្ងាប់ចិត្តទាំងខ្លួនឯងអ្នកនិយាយទាំងអ្នកស្តាប់ ។

**ឧទ្ធច្ចកុក្កុច្ចៈ**- រវើរវាយរាយមាយ ក្តៅក្រហាយស្តាយក្រោយ ឧបមាដូចខ្ញុំបំរើគេ (ទាសៈ) ខ្ញុំបំរើគេមិនមានសេរីភាពខ្លួនឯង ទោះជាពេលដែលពពួកជនកំពុងរីក-រាយ ក្នុងបុណ្យប្រចាំឆ្នាំ ក៏ត្រូវចៅហ្វាយហៅប្រើសព្វគ្រប់កិច្ចការដែរ យ៉ាងណាមិញ ការរាយមាយរវើរវាយក្តី ការក្តៅក្រហាយស្តាយក្រោយក្តី រមែងញ៉ាំងចិត្តឱ្យរវល់ រសាប់រសល់ ខ្វាយខ្វល់ រហូតដល់នៅមិនស្ងៀមតាមផ្លូវកាយ សូម្បីភិក្ខុនៅក្នុងព្រៃ ក៏ពុំបាននូវរសនៃវិវេក ព្រោះខុសនឹងវិន័យ ឬ សង្ស័យក្នុងវិន័យជាដើម ។

χ បុគ្គលគួរសិក្សារៀនសូត្រច្រើន ឬត្រូវតែជាអ្នកទ្រទ្រង់ធម៌ ទ្រទ្រង់ព្រះវិន័យ ព្យាយាមសន្ទនា ឬសាកសួរនូវធម៌តាមកាល និង សេពគប់ចំពោះបុគ្គលសប្បុរស

និយាយពាក្យពីរោះ ពាក្យមានប្រយោជន៏ ប្រយ័ត្នពាក្យដែលនាំឱ្យក្តៅក្រហាយស្តាយក្រោយ ។

**វិចិកិច្ឆា** - ការសង្ស័យ ឧបមាបីដូចផ្លូវឆ្ងាយដាច់ស្រយាល ផ្លូវមានភ័យ ផ្លូវមានចោរ ផ្លូវមានសត្វសាហាវ ផ្លូវអត់ទឹកអត់បាយ ផ្លូវឆ្ងាយទាំងអស់នេះ គឺជាផ្លូវនៃសេចក្តីអន្តរាយ របស់អ្នកដំណើរ យ៉ាងណាមិញ វិចិកិច្ឆាការសង្ស័យក្នុងអរិយសច្ចៈ ឬសង្ស័យនៅក្នុងព្រះរតនត្រ័យ ឬសង្ស័យក្នុងនាមរូប ជាផ្លូវនៃសេចក្តីអន្តរាយចំពោះការបានសម្រេចមគ្គផល ដូច្នេះបុគ្គលត្រូវសិក្សារៀនសូត្រទ្រទ្រង់ធម៌វិន័យ និង បដិបត្តិអប់រំចំរើនវិបស្សនា រហូតមានសទ្ធា ជឿការត្រាស់ដឹងរបស់ព្រះតថាគត អរហន្តសម្មា សម្ពុទ្ធ ។

## ១២- លោកុត្តរា ធម្មា

**ធម៌ទាំងឡាយជាលោកុត្តរបានដល់ - លោកុត្តរកុសលចិត្ត ៤០ ចេតសិកសម្បយុត្ត ៣៦ និព្វាន ។**

χ ដំណើរដើរចេញអំពីខន្ធដោយបញ្ញា ការកំចាត់ឆន្ទរាគៈ គឺសេចក្តីត្រេកអរពេញចិត្តចំពោះ ឧបាទានក្ខន្ធ ៥ ជាព្រះនិព្វាន ។

χ និព្វានបើពោលដោយបរមត្ថ មានតែមួយគត់គឺ ***អសង្ខតធាតុ*** គឺធាតុដែលមិនមានបច្ច័យតាក់តែង ប៉ុន្តែបើពោលជាប់ដោយបុគ្គលបញ្ញត្តិត្រូវមាន ២ យ៉ាងគឺ :

### I- សឧបាទិសេសនិព្វាន

បញ្ញត្តិខន្ធជាបច្ចុប្បន្នថា ជាបុគ្គលបានដល់នូវព្រះនិព្វាន ពីព្រោះការរំលត់កិលេសដោយអរិយមគ្គ តួខ្លួនពុំមានក្នុងខន្ធ ៥ សេចក្តីកង្វល់នឹងខ្លួនពុំមានក្នុងលោក ឈ្មោះថាបុគ្គលបានដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន (សូមកុំច្រឡំថាខន្ធ៥ បច្ចុប្បន្នជាសឧបាទិសេសនិព្វាន) ។

χ បុគ្គលពុំមែនស្លាប់ទៅកាន់លោកដទៃ ប៉ុន្តែមានបញ្ញាលោកុត្តរជាផ្លូវ បុគ្គលបានអាស្រ័យផ្លូវនោះទៅដល់ព្រះនិព្វានមួយរំពេច ។

χ កាលដែលបុគ្គលមិននៅក្នុងលោកនេះ ព្រោះរំលត់កិលេសមានសក្កាយទិដ្ឋិជាដើម មិនមានក្នុងលោក ដទៃ ព្រោះមិនទាន់ចុតិចិត្ត គឺនៅរស់ក្នុងបច្ចុប្បន្ន ជីវិត បច្ចុប្បន្នជាការប្រព្រឹត្តទៅនៃខន្ធ បញ្ញត្តិថាជាបុគ្គល ។

χ មនុស្សមិនទាន់ស្លាប់ មិនអាចទៅកើតជាទេវតា ឬព្រហ្មបានទេ ប៉ុន្តែមនុស្សមិនទាន់ស្លាប់អាចទៅព្រះនិព្វានបាន ព្រោះផ្លូវទៅព្រះនិព្វានគឺ អរិយមគ្គ ពុំមែនចុតិចិត្តទេ ចំពោះអរិយមគ្គកើតមាន គឺកើតមានចំពោះបុគ្គលដែលនៅរស់ ដូច្នេះទើបមាន ***សឧបាទិសេសនិព្វាន*** ។

## II- អនុបាទិសេសនិព្វាន

បញ្ញត្តិខន្ធបញ្ចកៈដែលបែកធ្លាយ ដោយអាស្រ័យអំណាចចុតិចិត្ត ជាចិត្តចុងក្រោយបង្អស់ក្នុងសង្សារវដ្ត មិនមានភពថ្មីតទៅទៀត ថាជាការបរិនិព្វាន ដែលជាប្រយោជន៍ចុងក្រោយបំផុតរបស់ការប្រព្រឹត្តិព្រហ្មចរិយធម៌ ។

χ **និយ្យានត្ថោ** - អរិយមគ្គប្រកបដោយអង្គ ៨ ប្រការ មានអត្ថថានាំសត្វទៅកាន់ព្រះនិព្វានដែលជាទីបំផុតទុក្ខ បានដល់ព្រះនិព្វានពីរយ៉ាងនេះឯង ។

χ **អប្បដិសន្ធិ** - ការមិនបដិសន្ធិ គឺជាតួព្រះនិព្វាន មិនមែនទាល់តែរំលត់ខន្ធ ៥ ដោយចុតិចិត្តរបស់ព្រះអរហន្តទៅ ទើបបានដល់នូវអប្បដិសន្ធិ គឺព្រះនិព្វាននោះទេ សូម្បីបញ្ចក្ខន្ធនៅជាបច្ចុប្បន្ន មិនទាន់បែកធ្លាយក៏ដោយ ក៏បុគ្គលរលត់កិលេសបាននូវព្រះនិព្វាន ដែលមិនមានបដិសន្ធិហើយស្រេច ព្រោះថាបុគ្គលរំលត់កិលេស ដោយអរិយមគ្គ គឺជាអ្នកមិននៅក្នុងលោកនេះ ហើយគឺជាអ្នកទៅកាន់ទីដែលមិនបដិសន្ធិ ឯចំណែកបញ្ចក្ខន្ធរបស់មិនទៀង ជាទុក្ខ មានសភាពសូន្យចាកខ្លឹម ជាអនត្តា ជាធម្មតារមែងតែងតែបែកធ្លាយ ។

**សំនួរ** : ព្រះអរហន្តក្រោយអំពីអស់ជីវិតទៅ តើដូចម្តេច ?

**ចម្លើយ** : រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាមិនទៀងជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា របស់នោះជាអនត្តា ។

យើងមិនអាចឆ្លើយថា ព្រះអរហន្ត ក្រោយអំពីអស់ជីវិតទៅ យ៉ាងម៉េចៗបានឡើយ ព្រោះយើងឃើញនូវបញ្ចក្ខន្ធក្នុងបច្ចុប្បន្នតាមពិត រកព្រះអរហន្តពុំមានឡើយ រកសត្វរកបុគ្គលក៏ពុំមានដែរ ឃើញតែបញ្ចក្ខន្ធ មានការកើតឡើង ហើយរលត់ទៅវិញជាធម្មតាតែប៉ុណ្ណោះ.

χ ***តិណកដ្ឋសមំ លោកំ យទា បញ្ញាយ បស្សតិ ន អញ្ញំ បត្ថយេ កិញ្ចិ អញ្ញត្រ អប្បដិសន្ធិយាតិ*** ។

ក្នុងកាលណា បុគ្គលពិចារណាឃើញលោក (ខន្ធលោក) ទុកស្មើដោយស្មៅឬកំណាត់ឈើដោយបញ្ញាដ៏ប្រពៃតាមពិត ក្នុងកាលនោះ បុគ្គលរមែងមិនមានសេចក្តី ប្រាថ្នារបស់ដទៃណាមួយសូម្បីបន្តិចបន្តួចឡើយ មានតែមិនបដិ សន្ធិ គឺព្រះនិព្វានតែម្យ៉ាងប៉ុណ្ណោះ ។

χ បញ្ញានាំសត្វលោកទៅកាន់ទីដែលមិនបដិសន្ធិ គឺបញ្ញាជាលោកុត្តរ ព្រោះឆ្លងផុតចាកលោកនៃវដ្តសង្សារ ។

χ បញ្ញារំលត់កិលេស ពិតជានាំសត្វឱ្យបានដល់ព្រះនិព្វាន ព្រោះថា ការរំលត់កិលេស ឬការអស់ទៅនៃតណ្ហាជាឈ្មោះនៃព្រះនិព្វាន ។

χ ***តណ្ហក្ខយោ ហិ រាធ និព្វានន្តិ***

ម្នាលរាធ ព្រោះថា ការអស់ទៅនៃតណ្ហា ជាឈ្មោះនៃព្រះនិព្វាន **(ខន្ធវារវគ្គ រាធសំយុត្ត)** ។

χ មគ្គជាលោកុត្តរកំចាត់តណ្ហា ឈ្មោះថាផ្លូវទៅព្រះនិព្វាន ដែលសត្វលោកធ្វើដំណើរតាមផ្លូវនេះ រមែងរួចផុតចាកទុក្ខទាំងពួង ។

χ ការមិនបដិសន្ធិគឺព្រះនិព្វាន ឯចំណែកសត្វលោកដែលមិនទាន់ស្លាប់ គឺនៅកំពុងរស់ក្នុងលោកនេះ ក៏មិនមានបដិសន្ធិក្នុងលោកដទៃណា១ដែរ ប៉ុន្តែមិនមែនជាអ្នកបានដល់ព្រះនិព្វាន ព្រោះជាអ្នកជាប់នៅក្នុងលោកនេះ ។

អរិយសាវ័កនឿយណាយក្នុងខន្ធ ៥ហើយ ក៏ប្រាសចាកសេចក្តីត្រេកអរនឹងខន្ធ ជាអ្នកមិននៅក្នុងលោកនេះ មិនទៅកាន់លោកដទៃ ប៉ុន្តែទៅកាន់អប្បដិសន្ធិ រីឯ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនទៀង ជាទុក្ខ និង ជាអនត្តា មានការគ្រាំគ្រា ទ្រុឌទ្រោម បែកធ្លាយ អស់ទៅសូន្យទៅជាធម្មតា ។

## ១៣. កេនចិ វិញ្ញេយ្យា ធម្មា

***ធម៌ទាំងឡាយ អាចដឹងបានដោយចិត្តពួកខ្លះ***

## ១៤. កេនចិ ន វិញ្ញេយ្យា ធម្មា

**ធម៌ទាំងឡាយ មិនអាចដឹងបានដោយចិត្តពួកខ្លះ**

χ **រូបារម្មណ៍** អាចដឹងបានដោយចក្ខុវិញ្ញាណធាតុ មនោធាតុ និង មនោវិញ្ញាណធាតុ ប៉ុន្តែមិនអាចដឹងបានដោយ សោតវិញ្ញាណ ឃានវិញ្ញាណ ជីវ្ហាវិញ្ញាណ និង កាយវិញ្ញាណ ។

χ **សទ្ទារម្មណ៍** អាចដឹងបានដោយសោតវិញ្ញាណធាតុ មនោធាតុ និង មនោវិញ្ញាណធាតុ ប៉ុន្តែមិនអាចដឹងបានដោយវិញ្ញាណធាតុ ៤ ទៀតឡើយ ។

χ **គន្ធារម្មណ៍** អាចដឹងបានដោយ ឃានវិញ្ញាណ ធាតុ មនោធាតុ និង មនោវិញ្ញាណធាតុ ប៉ុន្តែមិនអាចដឹងបានដោយវិញ្ញាណធាតុ ៤ ទៀតឡើយ ។

χ **រសារម្មណ៍** អាចដឹងបានដោយ ជីវ្ហាវិញ្ញាណ ធាតុ មនោធាតុ និង មនោវិញ្ញាណធាតុ ប៉ុន្តែមិនអាចដឹងបានដោយវិញ្ញាណធាតុ ៤ ទៀតឡើយ ។

χ **ផោដ្ឋព្វារម្មណ៍** អាចដឹងបានដោយ កាយវិញ្ញាណធាតុ មនោធាតុ និង មនោវិញ្ញាណធាតុ ប៉ុន្តែ មិនអាចដឹងបានដោយចក្ខុវិញ្ញាណធាតុ សោតវិញ្ញាណធាតុ ឃានវិញ្ញាណធាតុ និង ជីវ្ហាវិញ្ញាណធាតុឡើយ ។

χ **ធម្មារម្មណ៍** អាចដឹងបានដោយមនោវិញ្ញាណធាតុតែម្យ៉ាង មិនអាចដឹងបានដោយវិញ្ញាណធាតុ ៦ ទៀតឡើយ ។

χ សូម្បីមនោវិញ្ញាណធាតុ ខ្លះអាចដឹងពួកធម៌នេះ ខ្លះទៀតអាចដឹងពួកធម៌នោះ មិនអាចដឹងពួកធម៌ទាំងអស់ជាអារម្មណ៍បានទេ ហើយមនោវិញ្ញាណធាតុខ្លះទៀត ក៏អាចដឹងធម៌ទាំងអស់បាន ។

χ សរុបសេចក្តីមកគឺ ក្នុងធម៌ជាបរមត្ថទាំង ៤ (**ចិ ចេ រូ និ**) មិនមានបរមត្ថធម៌ណាដែលអាចដឹងបានដោយចិត្ត ១២១ ដួងទេ ដឹងបានដោយចិត្តខ្លះតែ ប៉ុណ្ណោះ ចិត្តខ្លះទៀតដឹងបរមត្ថធម៌ដទៃ ។

χ **គោចររូប ៧** អាចដឹងបានដោយមនោវិញ្ញាណធាតុខ្លះ មនោវិញ្ញាណធាតុខ្លះទៀត មិនដឹងគោចររូបឡើយ ។

χ **និព្វាន** ដឹងបានដោយមនោវិញ្ញាណខ្លះ ដឹងមិនបានដោយមនោវិញ្ញាណខ្លះ ។

χ **ជាធម្មតា** ពុទ្ធបរិស័ទតែងប្រាថ្នាចង់ឃើញព្រះនិព្វាន តែសូមរលឹកដឹងរឿយៗចំពោះសភាវធម៌ជាប្រក្រតីក្នុងជីវិតប្រចាំថ្ងៃ ចក្ខុវិញ្ញាណឃើញរូបារម្មណ៍ ពុំមែនសត្វបុគ្គលតួខ្លួនជាអ្នកឃើញ យ៉ាងណា ការឃើញព្រះនិព្វាន ក៏ឃើញដោយមនោវិញ្ញាណធាតុប្រកបដោយបញ្ញា ពុំមែនសត្វបុគ្គលតួខ្លួនជាអ្នកឃើញក៏យ៉ាងនោះដែរ ដូច្នេះការ

សំខាន់គឺមិនមែនចង់ដឹងអ្វីៗដែលមិនមែនជាសភាវធម៌ កំពុងប្រាកដនោះទេ គឺសំខាន់នៅត្រង់រលឹកដឹងរូបធម៌ នាមធម៌ ដែលកើតព្រោះហេតុបច្ច័យ កំពុងប្រាកដ ហើយចាក់ធ្លុះនូវលក្ខណៈជាអនត្តាក្នុងសភាវធម៌នោះៗ បានដល់ទីបំផុតទុក្ខក្នុងបច្ចុប្បន្ន ។

# ពាក្យគួរចងចាំ ចុងក្រោយ

— ផ្លូវដំណើរក្នុងភពក្តី សម្បត្តិក្នុងលោកក្តី ពូជពង្សវង្សត្រកូលក្តី ទាំងអស់នេះ មិនមែនជាទីក្សេមក្សាន្ត ផុតទុក្ខផុតភ័យឡើយ ។

បញ្ញាដ៏ឧត្តម ឃើញរូបមិនមែនខ្លួន វេទនាមិនមែនខ្លួន សញ្ញាមិនមែនខ្លួន សង្ខារមិនមែនខ្លួន វិញ្ញា-ណមិនមែនខ្លួន ឃើញខន្ធទាំង៥ អស់ទៅ សូន្យទៅ មិនមែនរបស់ខ្លួន ការរំលត់សេចក្តីប្រកាន់គឺជាព្រះនិព្វាន ក្សេមក្សាន្ត ផុតចាកទុក្ខភ័យទាំងពួង ទីនោះស្ងប់ពិត ទីនោះប្រណីតពិត ព្រោះផុតចាកខន្ធ ។

ជំនួយសតិភាគទី៣ " ចប់ "

ទីរលឹកឆ្នាំសិក្សាទី៩

ភ្នំពេញ_ព_ស ២៥៤១

# ពាក្យប្រារព្ធ

សៀវភៅ ជំនួយសតិភាគ៣នេះ ខ្ញុំព្រះករុណាខ្ញុំបាទ បានសរសេរបន្តិចម្តងៗ ស្រង់យកចំណុចសំខាន់ៗ អំពីធម៌ ដែលបានសម្តែងក្នុង ព-ស ២៥៤១ ឆ្នាំសិក្សាទី៩នៅភ្នំពេញ ព្រមទាំងចម្លងព្រះត្រៃបិដកនិងអត្ថកថា ដើម្បីជាគោលបន្តិចៗដូចជា ចូឡន្តរទុកៈ ជាដើមផង ។

ធម្មទានដ៏ប្រសើរ បានសម្រេចដោយសារអ្នកសំ-ដែងផង អ្នកស្តាប់ផង អ្នកជួយខ្នះខ្នែងឧបត្ថម្ភផង និងអ្នកគាំទ្រផង អ្នកទាំងអស់នេះជាអ្នកមាននូវសទ្ធា និងបញ្ញា ឈ្មោះថាមានជីវិតដ៏ប្រសើរ ។

ក្នុងសៀវភៅនេះ គង់តែមានខុសនូវអក្សរសរសេរជាពុំខាន ព្រោះហេតុនេះ សូមព្រះករុណាម្ចាស់ និងញាតិញោមមេត្តាអភ័យទោស ជួយកែតម្រូវដោយកុសលចេតនាហើយសូមកាន់យកនូវសេចក្តីនៃធម៌ជាគ្រឿងពិចារណា និងបដិបត្តិតាមសមគួរដល់ហេតុផលផងចុះ ។

ខ្ញុំព្រះករុណា ខ្ញុំបាទសូមអនុមោទនានូវកុសលចេ-តនាក្នុងការបដិបត្តិតាមធម៌ តាមវិន័យរបស់ព្រះគុណម្ចាស់គ្រប់ព្រះអង្គ និងញាតិញោមពុទ្ធបរិស័ទ ម្យ៉ាងទៀតខ្ញុំបាទសូមអនុមោទនានូវកុសលចេតនារបស់អ្នកដែលបានបរិច្ចាគប្រាក់ដោយកម្លាំងរបស់សទ្ធាពិតៗ និងកុសលកម្មក្នុងការជួយចាត់ចែងគ្រប់យ៉ាង ដូចជាជួយធ្វើពុម្ពអក្សរដោយម៉ាស៊ីនកុំព្យូទ័រ និងជួយចាត់ចែងបោះពុម្ពជាដើម ដើម្បីឱ្យបានទាន់ពេលបិទវគ្គសិក្សានៅឆ្នាំទី៩នេះ ។

សូមពុទ្ធបរិស័ទបានសម្រេចនូវបញ្ញាដ៏ឧត្តម បានដល់នូវការរំលត់សេចក្តីប្រកាន់បញ្ចក្ខន្ធ ធ្វើដំណើរចេញចាកខន្ធ ទៅកាន់បរមសុខ កុំបីខានឡើយ ។

១៥កើតខែផល្គុន ព-ស ២៥៤១

ខ្ញុំព្រះករុណា ខ្ញុំបាទ ប៊ុត សាវង្ស

# សូមអនុមោទនា
# ចំពោះលោកអ្នកបរិច្ចាគប្រាក់បោះពុម្ព

១-លោក ជូ គឹមសែ និងភរិយា ១.៤០០ក្បាល

២-ឧបាសិកា ញ៉ឹក ប៊ុនថា និង

ឧបាសិកា ម៉ែន សុភារី

រួមទាំងភាគ១ និង ភាគ២ផង ៨១០ក្បាល

៣-ឧបាសិកា អ៊ាប ប៊ុនស៊ត ២៧០ក្បាល

៤-ឧបាសិកា សាំ ហឿង ៣៦០ក្បាល

៥-ឧបាសិកា អ៊ាង វ៉ិច ២៧០ក្បាល

៦-ឧបាសិកា ស៊ីវ ខេង ២៧០ក្បាល

៧-ឧបាសិកា សាម៉ុល-គឹមធន់ ២៧០ក្បាល

៨-ឧបាសក ផាង-ថាន និង

ឧបាសិកា ង៉ែត សារឿន ២៧០ក្បាល

៩-លោក វ៉ន-ចឹក និងភរិយា ព្រមទាំងបុត្រនៅ

សហរដ្ឋអាមេរិក ១០០USD

១០-លោក យូស៊ាង ងួនលី និងភរិយា ព្រមទាំង

កូនចៅ នៅសហរដ្ឋអាមេរិក ៧៥០USD

១១-លោក ឆាយ អ៊ីវសៀង និងភរិយា ព្រមទាំង

កូនចៅនៅសហរដ្ឋអាមេរិក ១.៥០០USD

— ពុទ្ធបរិស័ទចិត្តបុណ្យជាច្រើននាក់ទៀត ។

— សទ្ធារៀបចំរចនាអក្សរម៉ាស៊ីនកុំព្យូទ័រ

ដោយនាង : **ជា សុណាវី**

**យុន សុនីម៉ា**

## បោះពុម្ពលើកទី១ ចំនួន
## ១៣៥០០ក្បាល

# មាតិកាធម៌

ល,រ ឈ្មោះធម៌ ទំព័រ

១- សប្បច្ចយា ធម្មា ........................................... ១

២- អប្បច្ចយា ធម្មា ........................................... ១២

៣- សង្ខតា ធម្មា ........................................... ២៩

៤- អសង្ខតា ធម្មា ........................................... ៦៩

៥- សនិទស្សនា ធម្មា ........................................... ៨២

៦- អនិទស្សនា ធម្មា ........................................... ៩៧

៧- សប្បដិឃា ធម្មា ........................................... ១១៣

៨- អប្បដិឃា ធម្មា ........................................... ១២៦

៩- រូបិនោ ធម្មា ........................................... ១៣៤

១០- អរូបិនោ ធម្មា ........................................... ១៤០

១១- លោកិយា ធម្មា ........................................... ១៥៥

១២- លោកុត្តរា ធម្មា ........................................... ១៦៥

១៣- កេនចិ វិញ្ញេយ្យា ធម្មា ........................................... ១៧១

១៤- កេនចិ ន វិញ្ញេយ្យា ធម្មា ........................................... ១៧១